■ អង្គការការីតាសជួយសប្បុរសធម៌និងការអភិវឌ្ឍ ជនក្រីក្រនិងអ្នកខ្វះខាត ជាង៣០ឆ្នាំមកហើយ <ទំព័រ៖៦

■ ២០២២ ឬ ២០២៣ អ្នករស់នៅជាយរាជធានីភ្នំពេញ នឹងមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ <ទំព័រ៖៩


កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ
# the messenger

ខែ វិច្ឆិកា | ឆ្នាំ ២០២០ | លេខទី ១៣៣

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

November, 2020 | #133


## អបអរសាទរ ព្រះគ្រីស្តយាងមក



គ្រីស្តបរិស័ទនាំគ្នាប្រារព្ធ “រដូវអបអរសាទរព្រះគ្រីស្តយាងមក”

ក្នុងរដូវអបអរសាទរព្រះគ្រីស្តយាងមកនេះ គឺក្នុងរយៈពេល៤អាទិត្យមុនបុណ្យព្រះយេស៊ូប្រសូត គ្រីស្តបរិស័ទបង្ហាញជំនឿរបស់ខ្លួនចំពោះព្រះគ្រីស្ត ដែលបានសង្គ្រោះមនុស្សលោក រួចហើយលាតសន្ធឹងការសង្គ្រោះរបស់ព្រះអង្គ រហូតដល់ពេលព្រះអង្គយាងមកនៅគ្រាចុងក្រោយបំផុត។

ទំព័រ៖១៧-១៩

■ យុវជនហាត់ល្ខោនស្បែកធំ ដោយមិនគិតលើកម្រៃ ព្រោះតែក្តីស្រឡាញ់

ទំព័រ៖១២



■ លោកអភិបាល អូលីវីយេ ស្នើឱ្យគ្រីស្តបរិស័ទត្រៀមខ្លួនជានិច្ច

ទំព័រ៖១៥

■ ព្រះសហគមន៍ពាក់ស្នែងជាវត្តមានរបស់ព្រះយេស៊ូក្នុងទីដាច់ស្រយាល

ទំព័រ៖១៦



## ជំងឺកូវីដ១៩ ប៉ះពាល់ដល់វិស័យធំៗជាច្រើន ប៉ុន្តែសម្រាប់កសិកម្មមិនរងសំពាធឡើយ

ទំព័រ៖១០-១១



# ប្រុងស្មារតីជានិច្ច និងរៀបចំផ្លូវ ទទួលព្រះអម្ចាស់!

បងប្អូនជាទីស្រលាញ់ ជាធម្មតា ក្នុងពេលវេលានេះ គ្រប់គ្នាតែងតែប្រុងប្រៀប និងត្រៀមរៀបចំអបអរសាទរបុណ្យព្រះយេស៊ូ ប្រសូតយ៉ាងអរសប្បាយ។ ជាទូទៅនៅតាមដងផ្លូវ ភោជនីយដ្ឋាន ទីសាធារណៈនានា គឺរៀបចំតុបតែងលំអ ដោយភ្លើងពណ៌យ៉ាងស្រស់ប្រណិត នៅក្នុងទីក្រុង។ ប៉ុន្តែឆ្នាំនេះ ពេលវេលាដូចគ្នា គឺហាក់ដូចជាកំរិតព្រំដែនមួយ នាំឱ្យម្នាក់ៗហាក់មិនច្បាស់ក្នុងចិត្ត ដោយសារតែមេរោគឆ្លង កូវីដ ១៩ ។

ការរៀបចំបុណ្យហាក់នៅមិនច្បាស់លាស់ កំរិតចំនួនមនុស្សក្នុងការជួបជុំ ក្នុងការប្រាស្រ័យទាក់ទងគ្នា។ ម្នាក់ៗស្ទាក់ស្ទើរក្នុងចិត្ត មានការប្រុងប្រយ័ត្នជាប់ជានិច្ច ព្រោះបង្ការ និងការពារការឆ្លងជំងឺនៃមេរោគថ្មីនេះ។ ព្រះយេស៊ូ ក្រុមទេវទូត ហោរាចារ្យ ពួកគង្វាល ប្រហែលត្រូវពាក់ម៉ាស និងបាញ់អាល់កុលជាប់ជានិច្ចដែរហើយក្នុងឆ្នាំនេះ។

សម្រាប់ព្រះសហគមន៍កាតូលិក ក្នុងរដូវរង់ចាំ គឺបានរំលឹក និងណែនាំឱ្យគ្រីស្តបរិស័ទរិះគិត និងរៀបចំខ្លួន ក្នុងរយៈពេលបួនសប្តាហ៍ មុនបុណ្យព្រះយេស៊ូប្រសូត គឺ ចូរប្រុងស្មារតី! ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់! ខ្ញុំជាសម្លេង ! និងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់!

*ចូរប្រុងស្មារតីជានិច្ច ដើម្បីរៀបចំផ្លូវទទួលព្រះអម្ចាស់ដែលយាងមក ! តើព្រះអម្ចាស់បានយាងមកដល់ហើយឬនៅ? ព្រះយេស៊ូបានប្រសូតម្តងហើយជាស្ងួមច។ តើយើងរង់ចាំអ្វី? ហេតុអ្វីត្រូវប្រុងស្មារតី? តើខ្ញុំត្រូវរៀបចំផ្លូវយ៉ាងដូចម្តេច? តើជាសម្លេងយ៉ាងដូចម្តេចអំពីព្រះអម្ចាស់? តើខ្ញុំជាអ្នកបម្រើយ៉ាងដូចម្តេច?*

បងប្អូនបានដឹង បានឮ និងបានទទួល ឆ្លងកាត់ព្រឹត្តិការណ៍នានា ក្នុងពិភពលោកយើងសព្វថ្ងៃ ក្នុងបរិបទនៃការរីករាលដាលនៃជំងឺឆ្លងកូវីដ ១៩ ។ ពេលខ្លះម្នាក់មិនបានប្រុងស្មារតី ប្រុងប្រយ័ត្ន គោរពតាមវិធាន មួយចំនួនរបស់ក្រសួងសុខាភិបាល ក្នុងការប្រយុទ្ធប្រឆាំង នឹងកូវីដ១៩ នាំឱ្យមានការឆ្លងមេរោគ ចូលក្នុងខ្លួន និងបានចំលងដល់បងប្អូនកូនចៅនៅជុំវិញខ្លួន។ ហេតុនេះត្រូវប្រុងស្មារតីជានិច្ច ក្នុងការរស់នៅប្រចាំថ្ងៃ ការធ្វេសប្រហែសមួយគ្រានាំឱ្យមានកង្វល់ក្នុងជីវិត និងអ្នកដទៃ។

ដូចគ្នាដែរ ចំពោះព្រះអម្ចាស់ ព្រះអង្គបានយាងមកហើយ តែជីវិតរបស់យើងត្រូវប្រយ័ត្ន ត្រៀមខ្លួនជានិច្ច មិនដឹងថាពេលវេលានៃជីវិតរបស់យើងម្នាក់ក្នុងលោកីយ៍នេះនឹងរលត់ទៅនៅពេលណានោះទេ។

ម្នាក់ៗមិនចង់បានឡើយការលំបាក ទុក្ខសោក ឬទុក្ខព្រួយ។ យើងត្រូវការអំណរសប្បាយ សុភមង្គល សុខភាពល្អ មានជីវភាពធូរធា ជាដើម។ល។ ជាការពិត ក្នុងរដូវរង់ចាំនេះ យើងរង់ចាំព្រះយេស៊ូយាងមក ក្នុងជីវិតប្រចាំថ្ងៃរបស់យើង ក្នុងព្រឹត្តិការណ៍នានា។ យើងរង់ចាំប្រកបដោយសេចក្តីសង្ឃឹមជានិច្ច និងអំណរសប្បាយ។

ក្នុងគម្ពីរព្រះជាម្ចាស់បានចាត់ឱ្យលោកយ៉ូហានបាទីស្ទឱ្យមកមុនដើម្បីប្រកាសឱ្យយើងម្នាក់ៗ រៀបចំចិត្តគំនិត កែប្រែរបៀបរស់នៅ បកមករកព្រះអម្ចាស់វិញ ប្រកបដោយសេចក្តីស្រលាញ់ ការគោរពស្រលាញ់ បម្រើគ្នាទៅវិញទៅមក ដោយចិត្តសប្បុរស យកចិត្តទុកដាក់ស្តាប់ព្រះបន្ទូល អធិដ្ឋាននៅជាប់ក្នុងមាគ៌ារបស់ព្រះអង្គ។

ម្យ៉ាងទៀត អំណោយទាន ដែលយើងបានទទួលពីព្រះជាម្ចាស់ ក្នុងជីវិតរបស់យើងផ្ទាល់ មិនទុកសម្រាប់តែខ្លួនឯងទេ គឺដើម្បីចែករំលែកជាមួយបងប្អូនឯទៀតៗ ឱ្យបានទទួលអំណរសប្បាយ និង សេចក្តីសង្ឃឹម និងបានទទួលព្រះយេស៊ូផ្ទាល់ដូចយើងដែរ។ គ្រីស្តបរិស័ទត្រូវធ្វើជាសាក្សីអំពីព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រា របស់ព្រះជាម្ចាស់ ដែលជាសេក្តីស្រលាញ់ដ៏ពិតប្រាកដ។

ចូរយើងប្រុងស្មារតីជានិច្ច ដោយស្តាប់ព្រះបន្ទូលព្រះជាម្ចាស់ ដែលស្រលាញ់យើងយ៉ាងលើសលប់។ ចូរយើងព្យាយាមអធិដ្ឋានដើម្បីនៅជិតស្និទ្ធជាមួយព្រះយេស៊ូជានិច្ច។ បងប្អូនរួមជំនឿ ចូរយើងស្រលាញ់បងប្អូនឯទៀតៗ ដោយបម្រើ សម្តែងមេត្តាករុណា។ ជាងនេះទៀតចូរទទួលស្គាល់នូវអំណោយទាននានាក្នុងជីវិតរបស់យើង ដែលព្រះជាម្ចាស់បានប្រទានឱ្យ និងចែករំលែកជាមួយបងប្អូនដោយចិត្តសប្បុរស៕

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក



# មេគណបក្សបីរួមគ្នាមកជា «សម្ពន្ធភាពអ្នកប្រជាធិបតេយ្យខ្មែរ» ដើម្បីសន្តិភាពនៅកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

គណបក្សចំនួន៣បានប្រកាសចង «សម្ពន្ធភាពអ្នកប្រជាធិបតេយ្យខ្មែរ» (The Alliance of Khmer Democrats) ជាមួយគ្នាកាលពីពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០២០កន្លងមកនេះ ក្នុងគោលដៅដើម្បីថែរក្សាសន្តិភាពនៅកម្ពុជា និងលុបបំបាត់ការលាបពណ៌គ្នាផងដែរ។

គណបក្សទាំងនោះមាន គណបក្សខ្មែររួបរួមជាតិដែលមានលោក ញឹក ប៊ុនឆៃ ជាប្រធាន, គណបក្សសំបុកឃ្មុំ សង្គមប្រជាធិបតេយ្យរបស់លោក ម៉ម សូណង់ដូ ជាប្រធាន និងគណបក្សខ្មែរតែមួយ ដែលមានលោក កែម រិទ្ធិសិត ជាប្រធាន។

សម្ពន្ធភាពអ្នកប្រជាធិបតេយ្យខ្មែរ បានសម្រេចតែងតាំងលោក ម៉ម សូណង់ដូ ជាប្រធាន លោក ញឹក ប៊ុនឆៃ ជាអនុប្រធាន និងលោក គុជ លី ជាអគ្គលេខាធិការ។

លោកម៉ម សូណង់ដូ បានមានប្រសាសន៍នៅក្នុងសន្និសីទសារព័ត៌មានមួយកាលពីថ្ងៃទី ២៥ ខែវិច្ឆិកាថា គោលបំណងនៃការបង្កើតសម្ពន្ធភាពអ្នកប្រជាធិបតេយ្យខ្មែរ គឺដើម្បីបណ្តុះគំនិតជាតិនិយមគំរូថ្មីមួយដើម្បីយុវជនខ្មែរបន្តវេន ដោយគ្មានវប្បធម៌លាបពណ៌ និងគ្មានវប្បធម៌ក្តិចត្រួយឡើយ។

លោកបានបន្តថា គណបក្សទាំងបីនេះ នឹងធ្វើកិច្ចសហប្រតិបត្តិការសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ ។

ជាមួយគ្នានោះដែរ លោកម៉ម សូណង់ដូក៏បានធ្វើការកោតសរសើរចំពោះសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន ដោយលោកចាត់ទុកសម្តេចហ៊ុន សែន ជាវីរៈបុរសក្នុងការកសាងសន្តិភាព ប៉ុន្តែលោកចង់ឱ្យសម្តេចលុបបំបាត់នូវអំពើពុករលួយនៅក្នុងសង្គមខ្មែរ ដែលកំពុងផុសផុល។

លោកបានថ្លែងថា៖ «សន្តិភាពល្អហើយ គ្មានអ្នកណាល្អជាងសម្តេចតេជោ តែសម្តេចត្រូវលុបបំបាត់ឱ្យអស់ អំពើពុករលួយដើម្បីកសាងជាតិ»។

ឯលោក ញឹក ប៊ុនឆៃ ដែលជាប្រធានគណបក្សខ្មែររួបរួមជាតិ និងត្រូវបានជ្រើសតាំងជាគណបក្សខ្មែររួបរួមជាតិ បានលើកឡើងផងដែរថា គណបក្សរបស់លោកបានគិតគូរ និងចងនូវសម្ពន្ធភាពនេះគឺដើម្បីស្តារឡើងវិញជាបណ្តើរៗនូវអ្វីដែលកន្លងមកមានការបាត់បង់ខ្លាំង ហើយហាក់ដូចជាងាកខ្លាំងពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឃ្លាតឆ្ងាយពីប្រជាធិបតេយ្យសេរីពហុបក្ស ការអនុវត្តសិទ្ធិមនុស្សក្តី និងសេរីភាពរបស់ប្រជាពលរដ្ឋក្តី គឺ [យើង]នឹងខិតខំស្តារបន្តិចម្តងៗឱ្យមានការល្អប្រសើរឡើងវិញ៕

# កម្ពុជាជាប់លេខ១នៅអាស៊ី និងលេខ៣ក្នុងពិភពលោក ដែលមានស្ថានភាពគ្រប់គ្រងកូវីដ១៩បានល្អ

*អត្ថបទ៖ អមរិន្ទ ដានុត*

យោងតាមរបាយការណ៍ Le Bureau de Prospective Economique ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ១នៅអាស៊ី និងជាប់ចំណាត់ថ្នាក់លេខ៣ក្នុងពិភពលោកថាជាប្រទេសដែលមានស្ថានភាពគ្រប់គ្រងជំងឺកូវីដ១៩។

នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង CDC បានបង្ហោះនៅលើបណ្តាញសង្គមនៅថ្ងៃសុក្រ ទី២០ ខែវិច្ឆិកា ឆ្នាំ២០២០នេះថា៖ «កម្ពុជា ជាប់ចំណាត់ថ្នាក់លេខ៣ក្នុងពិភពលោក (ក្នុងចំណោម១៦៦ប្រទេស) និងលេខ១ នៅអាស៊ី ជាប្រទេសដែលមានស្ថានភាពគ្រប់គ្រងជម្ងឺកូវីដ១៩ និងផលប៉ះពាល់ពីជម្ងឺបានល្អជាងគេ»។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាលបានសរសេរអត្ថបទមួយដោយលើកឡើងថានៅក្នុងបរិបទនៃការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ កម្ពុជា បានឆ្លងកាត់នូវដំណាក់កាលស្មុគស្មាញដែលមាន ហានិភ័យខ្ពស់នៃការចម្លងវីរុសកូវីដ១៩ ប្រកបដោយការទទួលខុសត្រូវខ្ពស់ និងការគ្រប់គ្រងសភាពការណ៍បានល្អប្រសើរចំនួន៤ព្រឹត្តិការណ៍ធំ។

វិញ្ញាសារឬព្រឹត្តិការណ៍ធំៗទាំងនោះមាន ព្រឹត្តិការណ៍នៃការវិលត្រឡប់របស់បងប្អូនពលករកម្ពុជា ចូលមកក្នុងប្រទេសនៅពេល ដែលកំពុងតែមានការរាតត្បាតខ្លាំង នៅបណ្តាប្រទេសក្នុងតំបន់ និងនៅលើសាកលលោក, ព្រឹត្តិការណ៍នាវាខ្នាតយក្ស MS Westerdam ចូលចតនៅកំពង់ផែខេត្តព្រះសីហនុ, ការគ្រប់គ្រងអ្នកដំណើរមកពីក្រៅប្រទេស ក្នុងពេលដែលមានការគិតគូរ ដោយយកចិត្តទុកដាក់ក្នុងការសម្រួលឱ្យបងប្អូនខ្មែរ ដែលជាប់គាំងនៅក្រៅប្រទេស អាចបានវិលត្រឡប់មកកាន់ផ្ទះរបស់ខ្លួនវិញ និងតម្រូវការនៃអ្នកដំណើរផ្សេងៗទៀត ចូលមកកាន់កម្ពុជា និងព្រឹត្តិការណ៍៣វិច្ឆិកា កន្លងទៅនេះ។

លោកស្រីថា កម្ពុជា ពិតជាមានសំណាងដ៏ធំធេង មិនអាចវាស់វែងបានឡើយ ដែលមានប្រមុខដឹកនាំប្រទេស ដែលមានសមត្ថភាពអច្ឆិរយៈ ប្រកបដោយបេះដូងមនុស្សធម៌ពិតៗ មានទស្សនវិស្ស័យត្រឹមត្រូវ ភាពម៉ឺងម៉ាត់ប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃ ព្រមទាំងការគោរពស្រឡាញ់ និងការយកចិត្តទុកដាក់ជាទីបំផុត លើសុខភាពប្រជាជនទូទៅ ដែលធ្វើឱ្យប្រទេសកម្ពុជាមិនទាន់មានការចម្លងវីរុសកូវីដ១៩ ចូលក្នុងសហគមន៍ និងមិនទាន់មានអ្នកស្លាប់ ដោយសារជំងឺមួយនេះ រហូតមកទល់ពេលនេះនៅឡើយ៕

# ជំនឿជុំវិញ ក្រដាសប្រាក់ ២ដុល្លារសហរដ្ឋអាមេរិក



*ក្រដាសប្រាក់២ដុល្លារ ដែលត្រូវបានបោះពុម្ព និងប្រើប្រាស់ដំបូងបំផុតក្នុងឆ្នាំ១៨៦២។ **រូបភាព៖ វីគីភីឌៀ***

នៅកម្ពុជា តើក្រដាស ប្រាក់២ដុល្លារពិតជានាំមកនូវសំណាងល្អមែនឬ? សម្រាប់មនុស្សមួយចំនួនគឺពិតជាដូច្នោះមែន។ បន្ទាប់ពីចេញពីរៀន វាសនា អាយុ១៦ឆ្នាំ ជាសិស្សវិទ្យាល័យ បានដកក្រដាសប្រាក់ដុល្លារថ្មីរបស់ខ្លួនអួតបង្ហាញមិត្តភក្តិ ដោយមោទនភាព ដោយបញ្ចេញស្នាមញញឹមស្របនឹងវាចារថា៖ «តើមានអ្នកណាមានលុយនេះទេ?»។

គ្មាននរណាម្នាក់ឆ្លើយតបនឹងសំណួរនេះសោះ។ នោះគឺដោយសារតែ ២ ដុល្លារ ជាប្រភេទក្រដាសប្រាក់កម្រនឹងមានណាស់។ វាសនា ទើបនឹងទទួលបានប្រាក់នេះពីម្តាយមីងរបស់គេ ដែលរស់នៅឯសហរដ្ឋអាមេរិក។ «ខ្ញុំសុំឱ្យគាត់ផ្ញើលុយនេះមកឱ្យខ្ញុំព្រោះថានៅទីនេះ កម្ររកបានណាស់»។

មិនមែនតែវាសនាម្នាក់ទេ ដែលស្វែងរកក្រដាសប្រាក់នេះមកទុកនោះ។ អាជីវករផ្សេងៗក៏និយមរកក្រដាសប្រាក់នោះមកទុកដូចគ្នាដែរ។

រស្មី ជាថៅកែហាងកាហ្វេ អ៊ីនធឺណេតមួយកន្លែងនៅក្រុងភ្នំពេញពន្យល់ប្រាប់ពីមូលហេតុថា អាជីវករនិយមយកក្រដាសប្រាក់នោះបិទនៅមុខតូបដើម្បីនាំ «លាភ»ចូល។

លោកមានប្រសាសន៍ថា៖ «ខ្ញុំយកក្រដាសប្រាក់ដែលមានសរសេរមន្តគាថានេះ បិទជាប់នឹងទ្វារកញ្ចក់។ វាអាចទាក់ទាញភ្ញៀវ និងការពារការរកស៊ីរបស់ខ្ញុំកុំឱ្យជួបបញ្ហា»។

ព្រះសង្ឃក៏មានជាប់ពាក់ព័ន្ធនៅក្នុងជំនឿនេះផងដែរ។ ជាញឹកញាប់ ពុទ្ធបរិស័ទដែលមានជំនឿបានសុំឱ្យព្រះសង្ឃសូត្របាលីមន្តគាថា និងចារជាយ័ន្តនៅលើក្រដាសប្រាក់នោះ។

មូលហេតុផ្សេងទៀតនៃការនិយមរក្សាក្រដាសប្រាក់២ដុល្លារនោះ ក៏ដោយសារតែសោភ័ណភាពផងដែរ។ សម្រាប់ប្រជាពលរដ្ឋកម្ពុជាមួយចំនួនប្រាក់២ដុល្លារ ជាក្រដាសប្រាក់ស្អាតជាងគេក្នុងចំណោមក្រដាសប្រាក់ដុល្លារទាំងអស់។

ស្រីលក្ខណ៍ ម្ចាស់តូបកាសែតមួយកន្លែងនៅក្នុងរាជធានីភ្នំពេញចូលចិត្តទុកក្រដាសប្រាក់នេះណាស់ ព្រោះថា វាមានរូបមន្ត្រីសំខាន់ៗទាំងអស់ក្នុងរដ្ឋាភិបាលអាមេរិកជំនាន់ចាស់។

វីរៈ អាយុ២៥ឆ្នាំ បានចំណាយប្រាក់ ២ ម៉ឺនរៀល ដើម្បីទិញក្រដាស២ដុល្លារនោះសម្រាប់ធ្វើជាអំណោយជូនគូដណ្តឹងរបស់ខ្លួនក្នុងថ្ងៃបុណ្យនៃក្តីស្រឡាញ់។

យុវជនរូបនេះរៀបរាប់ថា៖ «ក្រដាសលុយហ្នឹង កម្រមានណាស់។ ដូច្នេះ ខ្ញុំសង្ឃឹមថាមិត្តស្រីខ្ញុំនឹងយល់ពីជម្រៅចិត្តស្នេហ៍របស់ខ្ញុំដែលមានចំពោះនាងតែម្នាក់គត់»។ កន្លងមកមនុស្សមួយចំនួនចំណាយប្រាក់រហូតដល់២០ដុល្លារ ដើម្បីទិញក្រដាសប្រាក់២ដុល្លារនោះ។ វីរៈ វាយតម្លៃថា៖ «ខ្ញុំសំណាងហើយដែលទិញវាបានមិនសូវថ្លៃនោះ»។

នៅលើទំព័រអ៊ីនធឺណេត ក្រដាសប្រាក់២ដុល្លារប្រភេទឆ្នាំ ១៩៧៦ លក់ក្នុងតម្លៃរហូតដល់ទៅជាង៦០ដុល្លារ។ ចំណែកក្រដាសប្រាក់ដែលទើបបោះពុម្ពថ្មី លក់ក្នុងតម្លៃ៥ដុល្លារ។




*ក្រដាសប្រាក់២ដុល្លារចាប់តាំងពីឆ្នាំ១៨៦២ រហូតមកដល់ ឆ្នាំ១៩៧៦ និងបានបន្តដល់បច្ចុប្បន្ន។ **រូបភាព៖ វីគីភីឌៀ***



*ក្រដាសប្រាក់២ដុល្លារដែលបានចរាចរណ៍ពេលបច្ចុប្បន្ន។ **រូបភាព៖ វីគីភីឌៀ***

អ្នកប្រកបរបរប្តូរប្រាក់នានាក្នុងក្រុងភ្នំពេញបានដឹងយ៉ាងច្បាស់ពីការនិយមរក្សាក្រដាសប្រាក់២ដុល្លារនេះ។ ភិរម្យ អ្នកដូរប្រាក់ម្នាក់នៅផ្សារកណ្តាលអះអាងថា៖ «ខ្ញុំមិនដែលឃើញអ្នកណាមកដូរលុយនេះចាយទេ ឃើញមានតែអ្នកមកទិញយកលុយនេះទៅវិញ»។ អ្នកដូរលុយរូបនេះបានឆ្លៀតឱកាសនេះ ដើម្បីបង្កើនអត្រាដូរលុយយ៉ាងខ្ពស់...៕

*(ដកស្រង់ពីសារព័ត៌មានបរទេស)*

# ក្រសួងបរិស្ថានស្នើប្រជាពលរដ្ឋកុំបំពុលបឹងទន្លេសាបដោយប្លាស្ទីក

*អត្ថបទ៖ អមរិន្ទ្រ ដានុត*

មន្ត្រីជាន់ខ្ពស់នៃក្រសួងបរិស្ថានបានជំរុញនិងអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ កុំដុតសំណល់សំរាមនិងកុំបោះចោលសំណល់ផ្តេសផ្តាសជាពិសេសសំណល់ប្លាស្ទីកចូលទៅក្នុងបឹងទន្លេសាប។ នេះជាការលើកឡើងរបស់លោក នេត្រ ភក្ត្រា អ្នកនាំពាក្យក្រសួងបរិស្ថាន។



*ប្រជាពលរដ្ឋប្រមូលសម្រាមនៅក្នុងទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា។ រូបភាព៖ ក្រសួងបរិស្ថាន*

លោកបានថ្លែងដូចនេះក្នុងទិវាអនាម័យបរិស្ថាន ២៣វិច្ឆិកានិងពិធីបុណ្យទន្លេសាបនារដូវទឹកសម្រកប្រចាំឆ្នាំ២០២០ ក្រោមប្រធានបទ «អនាម័យបរិស្ថានល្អ សុខភាពសហគមន៍ល្អ» ក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាប ដោយលោកសុំឱ្យប្រជាពលរដ្ឋដែលរស់នៅជុំវិញបឹងទន្លេសាប និងប្រជាពលរដ្ឋរស់នៅតាមសហគមន៍នានានៅលើបឹងទន្លេសាបរួមគ្នាការពារនិងអភិរក្សបឹងទន្លេសាប ដែលជាបឹងទឹកសាបធំជាងគេលើពិភពលោកពីការបំពុលដោយប្លាស្ទីក។

លោក នេត្រ ភក្ត្រា បានថ្លែងថា៖ «ទន្លេសាបត្រូវបានបំពុលដោយថង់ប្លាស្ទីកដែលទាំងសហគមន៍រស់នៅលើបឹងទន្លេសាបនេះផង និងការហូរនាំយកប្លាស្ទីក ដែលបងប្អូនប្រជាពលរដ្ឋបោះចោលគ្មានសណ្តាប់ធ្នាប់តាមព្រែក តាមស្ទឹងនានាចាក់ចូលមកក្នុងបឹងទន្លេសាប»។

លោកថា ហេតុផលដែលថាថង់ប្លាស្ទីកត្រូវបានគេចាត់ទុកថាជាការបំពុលដល់បរិស្ថាន ព្រោះថាវាត្រូវការពេលវេលាជាច្រើនរយឆ្នាំ ដើម្បីធ្វើការបំបែកសារធាតុ មានន័យថាសំណល់ប្លាស្ទីកគឺសារធាតុដែលមិនងាយនឹងពុកផុយ ឬរលួយបានដោយងាយឡើយ។

សំណល់ថង់ប្លាស្ទីកបានផ្តល់ផលប៉ះពាល់ដល់សង្គម សុខភាព និងគុណភាពបរិស្ថានរួមមាន៖ ការធ្វើឱ្យស្ទះប្រព័ន្ធបង្ហូរទឹកលូដែលបង្កឱ្យមានទឹកជំនន់នៅរដូវភ្លៀងធ្លាក់ ធ្វើឱ្យបាត់បង់សោភ័ណភាពទីក្រុងនិងទីប្រជុំជន នៅពេលគេបោះចោលថង់ប្លាស្ទីកនៅក្នុងបរិស្ថាន វាបង្កឱ្យមានគ្រោះថ្នាក់ដល់ប្រព័ន្ធអេកូឡូស៊ីជាពិសេសជីវៈចម្រុះនៅក្នុងទឹកពិសេសមច្ឆជាតិអាចទទួលរងពីការធ្វើឱ្យធ្លាក់ដោយសារតែពួកគេគិតថាជាចំណី ហើយបានស៊ីថង់ប្លាស្ទីកទាំងនោះជាជម្រកភ្នាក់ងារចម្លងជំងឺមួយចំនួនធំ និងមួយផ្នែកទៀតផ្ទុកដោយសារធាតុគីមីពុលអាចជ្រាបចូលទៅក្នុងដី និងធ្វើឱ្យប៉ះពាល់ដល់គុណភាពដី ទឹក និងទឹកក្រោមដី ធ្វើឱ្យមានការបំពុលទឹក និងដី។ នៅពេលដែលថង់ប្លាស្ទីកត្រូវបានប្រើប្រាស់សម្រាប់ច្រក ឬខ្ចប់ម្ហូបអាហារជាពិសេសអាហារក្តៅៗ អាចបង្កផលប៉ះពាល់ដល់សុខភាពមនុស្សដោយសារតែសារធាតុគីមីដែលមានផ្ទុកក្នុងថង់ប្លាស្ទីក។

ប្រធានអង្គការមូលនិធិ ទំពាំងស្នងឫស្សី និងក្រុមយុវជនមេត្រីភាពបរិស្ថាន លោក ស៊ា សុផល ក៏បានថ្លែងឱ្យដឹងផងដែរថា យុទ្ធនាការនេះធ្វើឡើងតាមបណ្តាសហគមន៍ជាប់បឹងទន្លេសាប ចាប់ពីតំបន់ឃុំកំពង់ឃ្លាំង កំពង់ភ្លុក ចុងឃ្នៀស ស្ទឹងសៀមរាប និងសហគមន៍មេជ្រៃ។

លោកបានប្រាប់ថា៖ «ទិវានេះ គឺផ្តល់សារអប់រំដល់ប្រជាពលរដ្ឋពីបញ្ហាអនាម័យ ការទុកដាក់និងញែកសំរាមឱ្យបានត្រឹមត្រូវ។ កម្មវិធីបរិស្ថានទាំងមូលនឹងផ្តោតជាសំខាន់ក្នុងការប្រមូលសំរាមយកតែប្លាស្ទីកប៉ុណ្ណោះ។ ប្លាស្ទីក គឺជាសំរាមដែលមានហានិភ័យ និងមានអាយុរាប់រយឆ្នាំ ដែលបង្កហានិភ័យខ្ពស់ទាំងជីវិតមនុស្ស សត្វ»។

យោងតាមរបាយការណ៍កាលពីឆ្នាំ២០១៩ កន្លងទៅសំណល់ប្លាស្ទីកជាង ៤០០០ ការ៉ុង (ទម្ងន់ប្រមាណជិត ២០០ តោន) ត្រូវបានប្រមូលចេញពីទន្លេសាបក្នុងភូមិសាស្ត្រខេត្តសៀមរាប ហើយនៅឆ្នាំ២០២០នេះ សំណល់ប្លាស្ទីកប្រមាណជាង ៥០០០ថង់ (ប្រមាណជិត ២៥០តោន) ត្រូវបានប្រមូលយកទៅកែច្នៃធ្វើជាឥដ្ឋបរិស្ថាន។

តាមការឱ្យដឹងរបស់លោកនេត្រ ភក្ត្រា ក្នុងមួយឆ្នាំៗ កម្ពុជាបានបង្កើតសំរាមប្រមាណ ៤លានតោន ក្នុងនោះ ៦៥% ជាសំណល់សរីរាង្គ ប្រមាណ ២០% ជាសំណល់ប្លាស្ទីក នៅសេសសល់ជាសំណល់រឹង និងសំណល់ផ្សេងៗទៀត។ ក្នុងចំណោមសំរាមទាំងអស់នោះ មានត្រឹមតែប្រមាណ ៥១% ប៉ុណ្ណោះ ដែលត្រូវបានយកទៅចាក់នៅទីលានចាក់សំរាម ក្រៅពីនោះត្រូវគេបោះចោលយ៉ាងអនាធិបតេយ្យតាមដងផ្លូវ ក្នុងប្រភពទឹក និងខ្លះទៀតត្រូវបានដុតចោលជាដើម។ លោកថា កម្ពុជាមិនទាន់មានតួលេខថាក្នុងមួយឆ្នាំប្រើប្រាស់ប្លាស្ទីកប៉ុន្មានតោននៅឡើយ ប៉ុន្តែគ្រាន់តែនៅរាជធានីភ្នំពេញក្នុងមួយថ្ងៃថង់ប្លាស្ទីកជាង ១០ លានថង់ត្រូវបានប្រើប្រាស់។

នៅលើពិភពលោក ក្នុងមួយឆ្នាំបានប្រើប្រាស់ប្លាស្ទីកចន្លោះពី ៤០០ ទៅ៦០០ លានតោន ហើយចាប់តាំងពីបង្កើតប្លាស្ទីក មក សំណល់ប្លាស្ទីកនៅលើភពផែនដីមានប្រមាណ ៩,៣ ប៊ីលានតោន ហើយចំនួននេះនឹងត្រូវបន្តកើនឡើងនៅពេលដែលចាប់ពីឆ្នាំ២០២៥ ពិភពលោកប្រើប្រាស់ប្លាស្ទីកប្រមាណ ៦០០ លានតោនក្នុងមួយឆ្នាំ។

ប្រសិនបើមិនមានវិធានការតឹងរឹងក្នុងការកាត់បន្ថយប្រើប្រាស់ប្លាស្ទីកលើទេ នៅលើពិភពលោកនឹងមានសំណល់ប្លាស្ទីកកើនដល់ ៣៤ប៊ីលានតោន នៅឆ្នាំ២០៥០ ហើយចំនួននេះមាន ច្រើនជាងចំនួនត្រីនៅក្នុងមហាសមុទ្រទៅទៀត៕

## ចំនួននិស្សិតកម្ពុជា កំពុងសិក្សានៅសហរដ្ឋអាមេរិក មានការកើនឡើងខ្ពស់

*អត្ថបទ៖ អមរិន្ទ្រ ដានុត*

យោងតាមរបាយការណ៍ថ្មីមួយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ចំនួននិស្សិតដែលបានសិក្សានៅក្នុងមហាវិទ្យាល័យ និងសាកលវិទ្យាល័យនៅសហរដ្ឋអាមេរិក បានកើនឡើងខ្ពស់នៅឆ្នាំ ២០១៩-២០២០ ដោយមានកំណើន ៨,៣% លើសឆ្នាំមុន។

របាយការណ៍ Open Doors ឆ្នាំ ២០២០ ស្តីពីការផ្លាស់ប្តូរផ្នែកសិក្សាអប់រំអន្តរជាតិ បានបង្ហាញឱ្យឃើញថា និស្សិតកម្ពុជាចំនួន ៧៤២ នាក់បានរៀននៅក្នុងមហាវិទ្យាល័យ និងសាកលវិទ្យាល័យ ក្នុងសហរដ្ឋអាមេរិក ដែលជាកំណើនលើសឆ្នាំ ២០១៨-២០១៩ ដែលមានចំនួន ៦៨៥ នាក់។ ចំនួននេះ បន្តនិន្នាការ វិជ្ជមាន ដែលមាននៅក្នុងរយៈពេល ៦ ឆ្នាំកន្លងមកនេះ។

លោក W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា៖ «នេះជាព័ត៌មានដ៏ប្រពៃ និងគួរឱ្យលើកទឹកចិត្ត។ យើងក៏រីករាយផងដែរ ដែលនិស្សិតកម្ពុជាមើលឃើញពីតម្លៃពិតប្រាកដនៃផ្នែកឧត្តមសិក្សារបស់អាមេរិក។ ការមាននិស្សិតខ្មែរសិក្សានៅក្នុងសហរដ្ឋអាមេរិក គឺជាការល្អសម្រាប់ប្រទេសយើងទាំងពីរ ហើយវាពង្រឹងទំនាក់ទំនងរវាងប្រជាជន និងប្រជាជនរបស់យើង»។

សហរដ្ឋអាមេរិកគឺជាគោលដៅទី១ នៅក្នុងពិភពលោកសម្រាប់និស្សិតអន្តរជាតិ ដោយមាននិស្សិតអន្តរជាតិចំនួនជាង ១ លាននាក់ នៅឆ្នាំ ២០១៩ - ២០២០ ។

ស្ថានទូតនៃសហរដ្ឋអាមេរិកនៅកម្ពុជា ជំរុញឱកាសសម្រាប់ឱ្យនិស្សិតកម្ពុជា បានសិក្សានៅសហរដ្ឋអាមេរិក តាមរយៈមជ្ឈមណ្ឌល EducationUSA របស់ខ្លួន និងសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៅភ្នំពេញ។ ស្ថានទូតថែមទាំងជំរុញឱកាសនេះផងដែរ តាមរយៈសកម្មភាពនៅតាមបណ្ណាល័យរបស់ស្ថានទូត ដែលស្ថិតនៅតាមទីតាំងចំនួន ៤ នៅប្រទេសកម្ពុជា និងនៅតាមសាលានានានៅទូទាំងប្រទេស។

ស្ថានទូតសហរដ្ឋអាមេរិកមានទំនាក់ទំនងជាមួយនិស្សិតកម្ពុជា ពីព្រោះការអប់រំអន្តរជាតិជំរុញទំនាក់ទំនងយូរអង្វែង និងការផ្លាស់ប្តូរចំណេះដឹងគ្នា រវាងសហគមន៍ក្នុងសហរដ្ឋអាមេរិក និងប្រទេសនានា នៅទូទាំងពិភពលោក។ និស្សិតអន្តរជាតិធ្វើឱ្យថ្នាក់រៀន សាលារៀន និងសហគមន៍នានាមានភាពចម្រុះគ្រប់បែបយ៉ាង ដែលនៅតែបន្តផ្តល់លទ្ធផល ទោះបីជាពួកគេត្រឡប់មកមាតុភូមិវិញយូរហើយក្តី។

របាយការណ៍ Open Doors ត្រូវបានចេញផ្សាយប្រចាំឆ្នាំដោយវិទ្យាស្ថានអប់រំអន្តរជាតិ ដោយសហការជាមួយការិយាល័យកិច្ចការអប់រំ និងវប្បធម៌នៃក្រសួងការបរទេសសហរដ្ឋអាមេរិក។ ចំពោះព័ត៌មានលម្អិតបន្ថែមស្តីពីការអង្កេតរបស់របាយការណ៍នេះ និងលទ្ធផលនានា សូមចូលមើលគេហទំព័រ https://www.iie.org/opendoors ៕

## គ.ជ.ប គ្រោងរៀបចំការបោះឆ្នោតតាមអនឡាញនៅឆ្នាំ២០២១ ដើម្បីជាការសាកល្បង

*អត្ថបទ៖ អមរិន្ទ្រ ដានុត*

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហៅកាត់ គ.ជ.ប គ្រោងរៀបចំការបោះឆ្នោតតាមអនឡាញ (Online) នៅឆ្នាំ២០២១ដើម្បីជាការសាកល្បង មុននឹងឈានទៅធ្វើការអនុវត្តជាក់ស្តែង សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នាឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាឆ្នាំ២០២។ នេះបើយោងតាមក្រសួងព័ត៌មាន។

លោក ឱម សុវណ្ណារុំ សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប បានថ្លែងថា នៅឆ្នាំ ២០២១ ខាងមុខនេះ គ.ជ.ប គ្រោងរៀបចំការបោះឆ្នោតសាកល្បងមួយតាមប្រព័ន្ធអនឡាញ ដោយប្រើការគ្រប់គ្រងព័ត៌មានតាមប្រព័ន្ធ បច្ចេកវិទ្យាព័ត៌មានវិទ្យា ទៅលើការចុះបញ្ជីបេក្ខជននិងគណបក្សនយោបាយ និងការបញ្ជូនលទ្ធផលការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោត ដែលមានជាង២ម៉ឺននៅទូទាំងប្រទេស។

ទោះជាយ៉ាងនេះក្តី ការរៀបចំការបោះឆ្នោតបែបនេះ ត្រូវការនូវសម្ភារបច្ចេកទេស និងអ្នកជំនាញការជាច្រើន សម្រាប់ជួយដល់កិច្ចការនេះ។

ប្រភពដដែលបានបញ្ជាក់ថា គ.ជ.បបានដាក់សំណើមួយទៅកាន់ប្រទេសជប៉ុន តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថា CDC និង JICA កាលពីខែសីហា ឆ្នាំ២០២០ ដើម្បីផ្តល់នូវជំនួយជាសម្ភារបច្ចេកទេសមានដូចជាកុំព្យូទ័រយួរដៃចំនួន២.០០០គ្រឿង យូអេសប៊ី និងសម្ភារដែលបម្រើការបោះឆ្នោតផ្សេងទៀត សម្រាប់បម្រើឱ្យការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នាឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាឆ្នាំ២០២៣ ។

លោក ឱម សុវណ្ណារុំ បានមានប្រសាសន៍ថា៖ «សំណើនេះ ត្រូវបានភាគីជប៉ុនទទួលយកហើយ ដោយភាគីជប៉ុនចាប់អារម្មណ៍ខ្លាំងទៅលើការរៀបចំការបោះឆ្នោត ដែលគ.ជ.ប គ្រោងធ្វើតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យានាឆ្នាំខាងមុខ»។

តាមរបាយការណ៍របស់គ.ជ.ប ចាប់តាំងពីឆ្នាំ២០១៥ ដល់បច្ចុប្បន្ន ភាគីជប៉ុនបានជួយទាំងបច្ចេកទេស និងសម្ភារ ព្រមទាំងអ្នកជំនាញការផ្នែកច្បាប់ សម្រាប់ជួយដល់ដំណើរការបោះឆ្នោតនៅកម្ពុជា។ សម្ភារៈ និងបរិក្ខារទាំងនោះ រួមមាន៖ ស៊ើវើ (Server) សម្រាប់ផ្ទុកទិន្នន័យអ្នកបោះឆ្នោត រថយន្តភីកអាប់(Pickup) ចំនួន៤០គ្រឿង សម្រាប់បម្រើឱ្យការ ដឹកជញ្ជូនសម្ភារនិងបរិក្ខារបោះឆ្នោត ហិបឆ្នោតចំនួនជាង១ម៉ឺន និងសម្ភារៈសម្រាប់ការិយាល័យមួយចំនួនទៀត៕





# រាជរដ្ឋាភិបាលនឹងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិលថ្មី ជាង ៦១០០ នាក់នៅឆ្នាំ២០២១



*អត្ថបទ៖ អរិយបុត្រ*

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ភ្លើងខៀវឱ្យស្ថាប័នរដ្ឋជ្រើសរើសមន្ត្រីរាជការថ្មីសរុបជាង៦១០០នាក់ សម្រាប់ឆ្នាំ២០២១ ខាងមុខ ក្រោយពេលដែលបានផ្អាកកាលពីឆ្នាំ២០២០ ដោយសារតែកាត់បន្ថយការចំណាយដើម្បីត្រៀមទប់ទល់នឹងការរីករាលដាលនៃមេរោគកូវីដ១៩។

លោក ព្រុំ សុខា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានចេញលិខិត ជូនដំណឹងដល់ គ្រប់ក្រសួង ស្ថាប័នរដ្ឋ រួចហើយស្តីពី ការផ្តល់ផែនការក្របខណ្ឌជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០២១ ។

យោងទៅតាមលិខិតដែលចុះហត្ថលេខាដោយលោក ព្រុំ សុខា នោះគឺរាជរដ្ឋាភិបាល អនុញ្ញាតឱ្យជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិលថ្មី ចំនួន ៦១០៦នាក់ នៅឆ្នាំ២០២១ សម្រាប់ស្ថាប័នរដ្ឋចំនួន ២២កន្លែង។ ក្នុងនោះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានអនុញ្ញាតឱ្យជ្រើសរើសក្របខណ្ឌមន្ត្រីរាជការថ្មី ច្រើនជាងគេ នៅឆ្នាំ២០២១ រហូតដល់ទៅ ៣៦០០ នាក់។ បន្ទាប់មក គឺក្រសួងសុខាភិបាល ដែលមានចំនួន ១.៣០០នាក់។ រីឯក្របខណ្ឌថ្មីតិចជាងគេ គឺក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន ៥នាក់ និងក្រសួងមុខងារសាធារណៈ ៨នាក់ ស្មើនឹងចំនួនក្របខណ្ឌមន្ត្រីរាជការស៊ីវិលថ្មីរបស់ក្រសួងរ៉ែ និងថាមពល នៅឆ្នាំ២០២១ ដែលត្រូវជ្រើសរើសតែ ៨នាក់ដែរ។

នៅក្នុងចំណោមស្ថាប័នទាំងអស់ គឺមានស្ថាប័នមួយចំនួន មិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិលថ្មី នៅឆ្នាំ២០២១ ទេ រួមមាន រាជបណ្ឌិតសភាកម្ពុជា ដែលស្ថិតក្រោមគណៈរដ្ឋមន្ត្រី, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងការបរទេស, ក្រសួងផែនការ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងធម្មការ និងសាសនា, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើភេរវកម្មជាដើម ។

ក្រោយពេលទទួលភ្លើងខៀវពីរាជរដ្ឋាភិបាល និងសេចក្តីជូនដំណឹងពីក្រសួងមុខងារសាធារណៈភ្លាម ក្រសួងអប់រំយុវជននិងកីឡាបានប្រកាសជូនដំណឹងអំពីការជ្រើសរើស ក្រមខណ្ឌថ្មីភ្លាម បន្ថែមទៀតនៅឆ្នាំក្រោយដើម្បីលើកកម្ពស់គុណភាពអប់រំសាធារណៈនៅក្នុងព្រះរាជាណាចក្រ។

យោងតាមសេចក្តីប្រកាសជាផ្លូវការដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី ១៨ ខែវិច្ឆិកាឆ្នាំ ២០២០ ក្រសួងបានប្រកាសជ្រើសរើសមន្ត្រីសរុបចំនួន ៣៦០០ នាក់ ។

តាមការជូនដំណឹងនោះ ក្រសួងបានជ្រើសរើសមន្ត្រីថ្មីសម្រាប់មុខជំនាញផ្សេងៗគ្នាចំនួន៧ ប៉ុន្តែនៅក្នុងចំណោមមន្ត្រីថ្មីដែលរើសគឺច្រើនបំផុតគឺ គ្រូបឋមសិក្សាថ្មីចំនួន ១.៥៥០ នាក់និងគ្រូវិទ្យាល័យចំនួន ១.១០០ នាក់ ក្រៅពីនោះ ជាគ្រូមត្តេយ្យ ឧត្តមសិក្សា គ្រូកីឡា និងមន្ត្រីគ្រប់គ្រងរដ្ឋបាលជាដើម។ មន្ត្រីនិងគ្រូបង្រៀនថ្មីដែលនឹងត្រូវជ្រើសរើសភាគច្រើនគឺនៅតាមខេត្ត។ រាជធានីភ្នំពេញនឹងត្រូវជ្រើសរើសគ្រូ និងបុគ្គលិកតែ ៣២ នាក់ប៉ុណ្ណោះ។ ខេត្តសៀមរាបនឹងជ្រើសរើស គ្រូបង្រៀនសរុបចំនួន ២៨៧ នាក់ បន្ទាប់មក ខេត្តព្រៃវែង និង ខេត្តបាត់ដំបង។

លោក រស់ សុវាចា អ្នកនាំពាក្យក្រសួងអប់រំ បានប្រាប់អ្នកសារព័ត៌មាន ថាក្រសួងនឹងជ្រើសរើសបុគ្គលិកនៅក្នុងវិស័យ អប់រំថ្មីស្របតាមតម្រូវការជាក់ស្តែងដល់ស្ថាប័នសាធារណៈក្នុង ២៥ រាជធានី - ខេត្ត។

លោកបានបន្តថា ការជ្រើសរើសបុគ្គលិកថ្មីរបស់ក្រសួងនឹងធ្វើឱ្យប្រសើរឡើងនូវការដាក់ពង្រាយគ្រូទៅសាលារៀនស្របតាមស្តង់ដារបុគ្គលិក។ លោកបានបន្ថែមថាគ្រូទាំងអស់នឹងត្រូវជ្រើសរើសពីមូលដ្ឋាន។

យោងតាមស្ថិតិអប់រំនិងសូចនាករស្ថាប័នអប់រំសាធារណៈនិងឯកជនបានបង្ហាញថាប្រទេសកម្ពុជាមានសាលាមត្តេយ្យសរុបចំនួន ៤.៨១០ សាលាបឋមសិក្សា ៧.៧១៦ អនុវិទ្យាល័យ ១.៣២៤ និងអនុវិទ្យាល័យ ៦៣៨ ដែលមានសិស្សសរុប ៣,៤០ លាននាក់និងគ្រូ ៩៣.៧០៣ នាក់។

ក្រៅពីការអប់រំទូទៅប្រទេសកម្ពុជាក៏មានគ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំនួន ៤៤ និង ៧៧ ជាស្ថាប័នឧត្តមសិក្សាឯកជន។

ការសម្រេចជ្រើសរើសមន្ត្រីរាជការថ្មីនេះ គឺត្រូវបានរៀបចំរួចមកហើយនៅក្នុងពង្រាងច្បាប់ថវិការជាតិ សម្រាប់ឆ្នាំ២០២១ ដែលត្រូវបានគណរដ្ឋមន្ត្រីអនុម័តយល់ព្រម កាលពីខែតុលាកន្លងទៅនេះ ។

រឿងនេះត្រូវបានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីថវិកាជាតិឆ្នាំ ២០២១ ដែលមានតម្លៃប្រហែល ៨,១ ពាន់លានដុល្លារ៕

## ក្រសួងអភិវឌ្ឍន៍ជនបទចាប់ផ្តើមស្តារ និងជួសជុលផ្លូវជនបទ ដែលខូចខាតដោយទឹកជំនន់

*អត្ថបទ៖ អមរិន្ទ្រ ដានុត*

គ្រោះទឹកជំនន់ទឹកភ្លៀងពេលថ្មីៗនេះ ធ្វើឱ្យប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធជនបទពីរផ្នែកសំខាន់ៗគឺ ផ្លូវជនបទ និងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកជនបទ ដែលការប៉ះពាល់នេះរាជរដ្ឋាភិបាលត្រូវចំណាយទឹកប្រាក់រាប់លានដុល្លារក្នុងការស្តារ និងជួសជុលឡើងវិញ។

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងអភិវឌ្ឍន៍ជនបទ លោក ចាន់ ដារ៉ុង បានឱ្យដឹងថា គិតត្រឹមថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ខ្សែផ្លូវជនបទដែលរងផលប៉ះពាល់មានចំនួន ៦៧០ ខ្សែ ស្មើនឹងប្រវែង ៥៣៨៩,៥៩ គ.ម ក្នុងនោះ ផ្លូវរងការខូចខាតប្រវែង ៣១៥៤,៤២ គ.ម សំណង់សិល្បការ្យសរុបចំនួន ២២៩ កន្លែង ដោយប៉ាន់ស្មានថវិកាមានចំនួន ៣៦៦,៤៥៨,៦៩០,៧០០ រៀល ឬស្មើនឹង ៩១,៦១៤,៦៧៣ ដុល្លារអាមេរិក។

លោក ចាន់ ដារ៉ុងបានបញ្ជាក់ថា ផ្លូវជនបទដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរមានក្នុងខេត្តចំនួន៩ រួមមាន៖ខេត្តបន្ទាយមានជ័យ មាន ៦៨ខ្សែ ខេត្តពោធិសាត់១០៨ ខ្សែ ខេត្តបាត់ដំបង១៣ ខ្សែ ខេត្តកំពង់ស្ពឺ ៤២ ខ្សែ ខេត្តសៀមរាប៣៤ ខ្សែ ខេត្តប៉ៃលិន ០៩ខ្សែ ខេត្តកណ្តាល៣៧ ខ្សែ ខេត្តកំពង់ឆ្នាំង ០៨ខ្សែ និងខេត្តឧត្តរមានជ័យ១៥ ខ្សែ។

លោក បានមានប្រសាសន៍ថា៖ «ខេត្ត៣ ដែលជាខេត្តអាទិភាពនិងត្រូវស្តារឡើងវិញមុនគេនេះគឺខេត្តបន្ទាយ មានជ័យ ចំណាយទឹកប្រាក់ ៤.៦លានដុល្លារ, ខេត្តពោធិ៍សាត់ ចំណាយ៤.៦លានដុល្លារ និងខេត្តបាត់ដំបងនឹងចំណាយទឹកប្រាក់ចំនួន ៣.៣លានដុល្លារ។ នៅពេលនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទម្លាក់កញ្ចប់ថវិកាចំនួន ១៥លានដុល្លារហើយ ដើម្បីក្រសួងអភិវឌ្ឍន៍ជនបទដោះស្រាយលើបញ្ហានេះ»។

ចំណែកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកជនបទដែលទទួលរងនូវផលប៉ះពាល់ គឺអណ្តូងទឹក ហើយខេត្តដែលទទួលរងនូវផលប៉ះពាល់ រួមមាន៖ ខេត្តបន្ទាយមានជ័យ ចំនួន ១៧៣៥ អណ្តូង ខេត្តបាត់ដំបង ចំនួន ៥១៥អណ្តូង ខេត្តពោធិ៍សាត់ ចំនួន ៤៨៩អណ្តូង ខេត្តប៉ៃលិន ចំនួន ៥៧អណ្តូង និងស្រះចំនួន ០៤ ខេត្តសៀមរាប ចំនួន ៤២៣អណ្តូង ខេត្តព្រះវិហារ ចំនួន ២៩អណ្តូង ខេត្តស្វាយរៀង ចំនួន ៨៣៧អណ្តូង និងខេត្តកំពង់ចាម ចំនួន ៧០អណ្តូង។

លោក ចាន់ ដារ៉ុង បានបញ្ជាក់ថា អណ្តូងដែលទទួលរងការខូចខាតមានចំនួនសរុប ៤ ១៥៥ អណ្តូង ហើយចំពោះការចំណាយក្នុងការជួសជុល និងស្តារអណ្តូងទឹកដែលរងផលប៉ះពាល់ដោយជំនន់ទឹកភ្លៀងទាំងអស់នេះមានចំនួនទឹកប្រាក់សរុបប្រមាណជា ៣,៦១៤,៨៥០,០០០ រៀល ស្មើនឹង ៩០៣,៧១២.៥ ដុល្លារអាមេរិក (ជាង៩០លានដុល្លារ)។

បើតាមមន្ត្រីដដែលនេះបានបញ្ជាក់ថា ក្រសួងបានរៀបចំថ្នាក់ដឹកនាំ និងក្រុមការងារបច្ចេកទេសចុះអន្តរាគមន៍បន្ទាន់តាមមុខព្រួញ សំខាន់ៗ ដែលបានវាយតម្លៃរួច ពិសេសខេត្តគោលដៅដែលបានទទួលរងផលប៉ះពាល់ខ្លាំង។

ក្រសួងបានប្រើប្រាស់លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តទាំង ២៥ ជាសេនាធិការផ្ទាល់នៅថ្នាក់មូលដ្ឋាន ក្នុងការតាមដាននិងវាយតម្លៃផលប៉ះពាល់ហេដ្ឋារចនាសម្ព័ន្ធជនបទដែលបណ្តាលមកពីគ្រោះមហន្តរាយនានាលើវិស័យអភិវឌ្ឍន៍ជនបទនៅជនបទកម្ពុជា៕

## USAID ផ្តល់ជំនួយមនុស្សធម៌បន្ថែមជាការឆ្លើយតបនឹងគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅកម្ពុជា

*អត្ថបទ៖ អមរិន្ទ្រ ដានុត*

សហរដ្ឋអាមេរិក តាមរយៈ ទីភ្នាក់ងារជំនួយ អាមេរិក (USAID) ផ្តល់ជំនួយមនុស្សធម៌បន្ថែមចំនួន ៦០ម៉ឺនដុល្លាអាមេរិក សម្រាប់ជួយដល់ការខិតខំក្នុងការឆ្លើយតបនឹងគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរ នៅកម្ពុជា ដែលបណ្តាលមកពីព្យុះត្រូពិក ដែលមានជាបន្តបន្ទាប់គ្នា និងភ្លៀងខ្លាំងផ្ទួនៗដែលមានរយៈពេលយូរ តាំងពីដើមខែតុលាមក។

លោកឯកអគ្គរដ្ឋទូតអាមេរិក W. Patrick Murphy បានមានប្រសាសន៍ថា៖ «យើងមានការអាណិត ដោយឃើញប្រជាជនកម្ពុជាងាយរងគ្រោះជាច្រើនមានការខ្វះខាត ដោយសារតែគ្រោះទឹកជំនន់នៅឆ្នាំនេះ។ សហរដ្ឋអាមេរិកនឹងផ្តល់ជំនួយសង្គ្រោះជាបន្ថែម ក្នុងស្មារតីសាមគ្គីភាពជាមួយសហគមន៍ដែលរងគ្រោះដោយគ្រោះទឹកជំនន់ទាំងនេះ»។

ជាមួយនឹងថវិកាបន្ថែមនេះផងដែរ ការិយាល័យផ្តល់ជំនួយមនុស្សធម៌ របស់ទីភ្នាក់ងារជំនួយអាមេរិក USAID នឹងជួយដល់អង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) ក្នុងការផ្តល់ជំនួយក្នុងគ្រាបន្ទាន់ ដើម្បីជួយគ្រួសារចំនួន ៣,៧២៥ ដែលរងផលប៉ះពាល់ ដើម្បីឱ្យគេទិញស្បៀងអាហារ

ជំនួយនេះបានបន្ថែមទៅលើទឹកប្រាក់ចំនួន ១០ម៉ឺនដុល្លារ ដែលទីភ្នាក់ងារ USAID បានផ្តល់ឱ្យដំបូង ដល់អង្គការ WFP បន្ទាប់ពីមានគ្រោះទឹកជំនន់ភ្លាម សម្រាប់ជួយក្នុងការចែកចាយស្បៀងជាបន្ទាន់ ដល់គ្រួសារចំនួនជាង ២,៥៦០ នៅក្នុងតំបន់ដែលរងគ្រោះខ្លាំងជាងគេ ក្នុងខេត្តពោធិសាត់។



*លោកស្រី Claire Conan តំណាងនៃអង្គការ WFP (ឆ្វេង) និងលោកឯកអគ្គរដ្ឋទូតអាមេរិក W. Patrick Murphy (កណ្តាល)។ រូបភាព៖ សហការី*

លោកស្រី Claire Conan តំណាងនៃអង្គការ WFP បានមានប្រសាសន៍ថា៖ «យើងសូមអរគុណដល់ទីភ្នាក់ងារ USAID ចំពោះជំនួយបន្ថែមនេះ សម្រាប់គ្រួសារខ្សត់ខ្សោយ ដែលរងគ្រោះដោយទឹកជំនន់។ ជំនួយនេះមានសារៈសំខាន់ណាស់សម្រាប់ស្តារស្ថានភាពរបស់គេ ពិសេសពួកគេក៏ជាជនរងគ្រោះផងដែរ ដោយសារបញ្ហាជំងឺរាតត្បាតជាសាកល។ អង្គការ WFP នឹងធ្វើការជិតស្និទ្ធជាមួយរដ្ឋាភិបាល និងដៃគូ នៅក្នុងដំណាក់កាលថ្មីនេះ នៃការឆ្លើយតបនឹងគ្រោះទឹកជំនន់»៕





ប្រជាជនក្រីក្រ និងប្រជាជនដែលបាត់បង់ឱកាសក្នុងប្រទេសកម្ពុជា ត្រូវបានអង្គការការីតាសកម្ពុជាចដែលចាប់ផ្តើមការងារដំបូងនៅឆ្នាំ១៩៧២ ផ្តល់ជំនួយជាង៣០ឆ្នាំកន្លងមកហើយ។ រូបភាព៖ អង្គការការីតាស

# អង្គការការីតាស ជួយសប្បុរសធម៌និងការអភិវឌ្ឍ ជនក្រីក្រនិងអ្នកខ្វះខាត រយៈពេល៣០ឆ្នាំមកហើយ

*អត្ថបទ៖ ????*

អង្គការការីតាសកម្ពុជាបានចាប់ផ្តើមការងារដំបូងនៅឆ្នាំ១៩៧២ ដើម្បីជួយដល់ជនរងគ្រោះដោយសារសង្គ្រាម ហើយបានបំពេញមុខងាររហូតដល់ឆ្នាំ ១៩៧៥ នៅពេលដែលត្រូវបានបង្ខំឱ្យចាកចេញពីប្រទេស។ បន្ទាប់ពីការអាក់ខានដំណើរការក្នុងកំឡុងឆ្នាំនៃរបបខ្មែរក្រហមនិងឆ្នាំបន្ទាប់នៃការប៉ះទង្គិចគ្នា អង្គការការីតាសកម្ពុជាត្រូវបានបង្កើតឡើងជាថ្មីនៅឆ្នាំ ១៩៩០។

អង្គការការីតាសកម្ពុជា ជាការអភិវឌ្ឍន៍សង្គមមួយរបស់វិហារកាតូលិកនៅកម្ពុជាដែលត្រូវបានកសាងឡើងដោយផ្អែកលើគុណតម្លៃនៃក្តីស្រឡាញ់ ការយកចិត្តទុកដាក់ យុត្តិធម៌ សន្តិភាព ភាពសាមគ្គីភាព ការចែករំលែក និងភាពជាបងប្អូន។

អង្គការការីតាសធ្វើការដោយសាមគ្គីភាពជាមួយមនុស្សទាំងអស់ដែលមានឆន្ទៈល្អនិងចក្ខុវិស័យប្រហាក់ប្រហែលគ្នា និងជួយដល់ជនក្រីក្រផ្អែកលើមូលដ្ឋាននៃតម្រូវការ មិនមែនលើជំនឿ។

អង្គការការីតាសកម្ពុជាបានបំពេញបេសកកម្មរបស់ខ្លួនរយៈពេល៣០ឆ្នាំមកហើយក្នុងការអភិវឌ្ឍជួយប្រជាជនក្រីក្រ និងប្រជាជនដែលបាត់បង់

> យើងប្រាកដថាឱកាសពិសេសនេះជម្រុញនិងបន្តការប្តេជ្ញាចិត្តរបស់អង្គការការីតាសកម្ពុជាដើម្បីបុព្វហេតុនៃភាពក្រីក្រនិងផ្នែកដែលងាយរងគ្រោះនៅក្នុងសង្គម

ឱកាសក្នុងប្រទេសកម្ពុជា។ អង្គការការីតាសប្តេជ្ញាចិត្តធ្វើដំណើរជាមួយអ្នកក្រនិងអ្នកដែលត្រូវបានគេមើលងាយ ក្នុងការពង្រឹងអំណាចសេដ្ឋកិច្ច សង្គម វប្បធម៌ អប់រំ និងសុខភាពហើយដូច្នេះពួកគេនឹងមើលឃើញថាជាសហគមន៍ដែលរឹងមាំ។

ក្នុងអំឡុងពេលនេះអង្គការបានឆ្លងកាត់ការផ្លាស់ប្តូរនិងឆ្ពោះទៅមុខ ដែលដឹកនាំដោយតម្លៃនិងការឆ្លុះបញ្ចាំងពីសកម្មភាពរបស់ខ្លួន។ វាកំពុងលេចចេញជាអង្គការមួយដែលមានលទ្ធភាព និងសកម្មភាពរស់រវើកក្នុងការជួយដោះស្រាយបញ្ហាដល់ប្រជាជនក្រីក្រនិងក្រុមងាយរងគ្រោះបំផុត។

បទពិសោធន៍នៃសមិទ្ធិផលនិងបញ្ហាប្រឈមនាពេលកន្លងមក បានជួយឱ្យអង្គការការីតាសកម្ពុជាឆ្លុះបញ្ចាំងពីទិសដៅនិងអនាគតរបស់ខ្លួន និងបន្តរៀបចំទិសដៅរបស់ខ្លួនដើម្បីឆ្លើយតបឱ្យបានគ្រប់គ្រាន់ទៅនឹងបរិយាកាសផ្លាស់ប្តូរនានា។

«យើងប្រាកដថាឱកាសពិសេសនេះជម្រុញនិងបន្តការប្តេជ្ញាចិត្តរបស់អង្គការការីតាសកម្ពុជាដើម្បីបុព្វហេតុនៃភាពក្រីក្រនិងផ្នែកដែលងាយរងគ្រោះនៅក្នុងសង្គម»។

ដោយមានការប្តេជ្ញាចិត្តពីអ្នកគ្រប់គ្រង នាយកប្រតិបត្តិ នាយកកម្មវិធី បុគ្គលិកគ្រប់ថ្នាក់ អ្នកស្ម័គ្រចិត្ត និងដៃគូ ក៏ដូចជាម្ចាស់ជំនួយ និងជាមួយនឹងរចនាសម្ព័ន្ធដែលបានបង្កើតឡើងយ៉ាងល្អនៅកន្លែងដែលអង្គការឆ្ពោះទៅរកជាមួយនឹងមូលដ្ឋានធនធានចម្រុះ ដែលកិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានពង្រឹងដោយភាពជាដៃគូជាមួយបណ្តាញជាតិ និងអន្តរជាតិ។

អង្គការការីតាសកម្ពុជាមានសមត្ថភាពនិងសក្តានុពលក្នុងការសម្រេចគោលដៅរបស់ខ្លួនក្នុងការបង្កើតសហគមន៍ប្រកបដោយសមធម៌និងការចូលរួម៕

បច្ចុប្បន្ន អង្គការការីតាសកំពុងធ្វើការនៅតាមបណ្តាខេត្តចំនួន១៥ នៃប្រទេសកម្ពុជា និងមានការគាំទ្រដល់សមាគម អភិវឌ្ឍន៍ភូមិ/សហករណ៍កសិករជាង ២០០ភូមិ ផងដែរ។ កម្មវិធីរបស់អង្គការការីតាសរួមមាន៖ ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពរបស់សហគមន៍ និងសន្តិសុខស្បៀងនៅក្នុងខេត្តចំនួន៧ ដែលគាំទ្រដល់សមាគមអភិវឌ្ឍន៍ភូមិចំនួន១៦។ ការអភិវឌ្ឍជំនាញបច្ចេកទេសនៅខេត្តចំនួន២ និងក្នុងពន្ធនាគារចំនួន៧ នៃប្រទេសកម្ពុជា រួមនឹងគម្រោងផ្សេងៗជាច្រើនទៀត៕

## កិច្ចសហការដំបូងលើគម្រោងចែករំលែកវិជ្ជាមេផ្ទះដល់ស្ត្រីខ្មែរនៅប្រទេសកូរ៉េត្រូវចានចុះអនុស្សរណៈ

*អត្ថបទ៖ អមរិន្ទ ដានុត*

អនុស្សរណៈនៃការយោគយល់លើកិច្ចសហប្រតិបត្តិការគាំពារសហគមន៍ខ្មែរ ត្រូវបានចុះហត្ថលេខាវវាងឯកអគ្គរដ្ឋទូតខ្មែរប្រចាំប្រទេសកូរ៉េខាងត្បូង និងមជ្ឈមណ្ឌលគាំពារជនបរទេសទីក្រុងសុងណាំ។

គោលបំណងនៃការចុះអនុស្សរណៈនេះគឺដើម្បីឈានទៅរកកិច្ចសហការដំបូងលើគម្រោងចែករំលែកវិជ្ជាមេផ្ទះដល់បងប្អូនស្ត្រីៗខ្មែរ និងការបង្រៀនភាសា ព្រមទាំងវប្បធម៌ខ្មែរដល់កុមារតូចៗជាកូនខ្មែរកាត់កូរ៉េ។

លោក ឡុង ឌីម៉ង់ ឯកអគ្គរដ្ឋទូតខ្មែរប្រចាំប្រទេសកូរ៉េខាងត្បូងបានឱ្យដឹងថា ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េខាងត្បូងបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយមជ្ឈមណ្ឌលសេវាកម្មសហគមន៍ជនអន្តោប្រវេសន៍សុងណាំ (Seongnam) ស្តីពីការបណ្តុះបណ្តាលការងារផ្ទះ ភាសា និងវប្បធម៌សម្រាប់ស្ត្រីនិងកុមារកម្ពុជាដែលរស់នៅទីនោះ។

លោកបានលើកឡើងថា សព្វថ្ងៃនេះស្ត្រីខ្មែរដែលបានរៀបការជាមួយនឹងប្តីជនជាតិកូរ៉េមានប្រមាណជាជិត១ម៉ឺននាក់ហើយ ដែលពួកគាត់មានកូនជាទូទៅ។ ដូចនេះកុមារដែលជាកូនកាត់ខ្មែរ-កូរ៉េ មានចំនួនប្រមាណជាជាង១ម៉ឺននាក់ដែរ។

ឯកអគ្គរដ្ឋទូតរូបនេះបានបន្តថា ដូចនេះហើយ បានស្ថានទូតបានធ្វើការទំនាក់ទំនង សហការជាមួយនឹងមជ្ឈមណ្ឌលគាំពារជនបរទេសទីក្រុងសុងណាំ ដែលជាទីក្រុងមួយមិនស្ថិតនៅឆ្ងាយប៉ុន្មានពីទីក្រុងសេអ៊ូលទេ។ ទីក្រុងសុងណាំមានប្រជាពលរដ្ឋខ្មែរដែលជាស្ត្រីរៀបការជាមួយនឹងបុរសជនជាតិកូរ៉េរស់នៅទីនោះប្រមាណជាចន្លោះពី៥០ទៅ៦០នាក់ផងដែរ។

លោកបានមានប្រសាសន៍ថា៖ «មូលហេតុដែលស្ថានទូតខ្មែរយើងធ្វើការសហការជាមួយនឹងមជ្ឈមណ្ឌលនេះគឺជាការចូលរួមចំណែកនៅក្នុងការពង្រឹង និងផ្សព្វផ្សាយនូវវប្បធម៌ខ្មែរ ដែលយើងនឹងឈានទៅដល់ការចែកមេរៀនអំពីសីលធម៌ខ្មែរ វប្បធម៌ វិជ្ជាមេផ្ទះ ការធ្វើម្ហូប ការបង្រៀនភាសាខ្មែរដល់កុមារដែលជាកូនកាត់ខ្មែរ-កូរ៉េ ដែលជាការផ្តល់នូវអត្ថប្រយោជន៍ច្រើនណាស់នៅក្នុងការរឹតចំណងកាន់តែស្អិតរមួតថែមទៀតរវាងប្រជាជននិងប្រជាជនរបស់ប្រទេសកម្ពុជានិងប្រទេសកូរ៉េថែមមួយកំរិតទៀត»។

លោកថា មជ្ឈមណ្ឌលនេះនឹងជួយលើកកំពស់បង្ហាញអំពីកិត្យានុភាព កិត្តិយសរបស់ស្ត្រីខ្មែរ ដែលមិនឱ្យបរទេសណាមានការម៉ាក់ងាយដោយស្ថានទូតខ្មែរនឹងនៅជាប់ជាមួយនឹងស្ត្រីខ្មែរ បើទោះបីជារៀបការហើយ ហើយអ្នកខ្លះក៏បានចូលសញ្ជាតិកូរ៉េហើយក្តី ប៉ុន្តែបងប្អូនដែលមានឈាមជ័រជាខ្មែរគឺស្ថិតនៅក្នុងវង្វង់នៃការគាំពារនូវកិច្ចការទាំងអស់ដើម្បីការពារដល់ស្ត្រីខ្មែរទាំងអស់នៅទីនេះ។

លោកឡុង ឌីម៉ង់បានបញ្ជាក់បន្ថែមថា កន្លងមកស្ត្រីខ្មែរខ្លះប្រឈមនឹងបញ្ហាទំនាស់គ្នារវាងប្តីនិងប្រពន្ធ ឬទំនាស់ខាងគ្រួសារស្វាមីក៏មានដែរ ដោយសារកង្វះខាតខាងភាសា ការយល់គ្នាទៅវិញទៅមក ហើយវប្បធម៌ខុសគ្នា មិនស្វែងយល់ពីវប្បធម៌គ្នាទៅវិញទៅមក វាអាចបង្កឱ្យមានជំលោះដែលធ្វើឱ្យមានការលែងគ្នាក៏មានដែរ។

គួរបញ្ជាក់ផងដែរថា រដ្ឋាភិបាលកម្ពុជាបានលុបចោលការកម្រិតអាយុលើបុរសបរទេសដែលមានបំណងរៀបការជាមួយស្ត្រីខ្មែរដែលត្រូវបានណែនាំក្នុងឆ្នាំ ២០១៨។ ចាប់ពីឆ្នាំ ២០១៨ តទៅបុរសបរទេសដែលមានអាយុលើសពី ៥០ ឆ្នាំនិងមានប្រាក់ចំណូលប្រចាំខែយ៉ាងហោចណាស់ ២៥០០ ដុល្លារអាចដាក់ពាក្យសុំរៀបការជាមួយនារីខ្មែរ។

មជ្ឈមណ្ឌលសេវាកម្មសហគមន៍ជនអន្តោប្រវេសន៍ Seongnam ត្រូវបានបង្កើតឡើងដោយមានកិច្ចសហប្រតិបត្តិការឯកជននិងសាធារណៈដើម្បីលើកកម្ពស់សុខមាលភាពរបស់ប្រជាជនបរទេសដោយផ្តល់សេវាកម្មដូចជាការពិគ្រោះយោបល់ ការអប់រំ និងកម្មវិធីសុខភាព និងកម្មវិធីវប្បធម៌។មជ្ឈមណ្ឌលនេះស្វាគមន៍ការពារគាំទ្រនិងភ្ជាប់អ្នកដែលបានមកដល់ប្រទេសកូរ៉េខាងត្បូង ហើយពាក្យស្លោករបស់ពួកគេសរសេរថា "យើងទាំងអស់គ្នាជាជនអន្តោប្រវេសន៍"៕





# យុវជនគួរដឹង! មេរោគនិងជំងឺអេដស៍ នៅមិនទាន់ទៅណាពីសង្គមនៅឡើយទេ

*អត្ថបទ៖ អរិយបុត្រ*

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានប្រកាសថា មកដល់ពេលនេះមេរោគនិងជំងឺអេដស៍នៅតែជាជំងឺដែលមិនទាន់ទៅណាឆ្ងាយពីសង្គមកម្ពុជានៅឡើយទេ សូមបន្តការប្រុងប្រយ័ត្ន និងបន្តចូលរួមបង្ការ និង ទប់ស្កាត់ទាំងអស់គ្នា។



លោក ឈឹម ឃិនដារ៉េត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានប្រាប់សារព័ត៌មានកាលពីពេលថ្មីៗនេះថា ការងារប្រយុទ្ធប្រឆាំងនឹងមេរោគនិងជំងឺអេដស៍គឺត្រូវតែបន្តទៀត ដើម្បីធ្វើយ៉ាងណាឆ្ពោះទៅរក ការបញ្ចប់របស់មេរោគនិងជំងឺនេះ ដែលជាបញ្ហាសុខភាពសាធារណៈនៅកម្ពុជានៅឆ្នាំ២០២៥ខាងមុខ ឱ្យបាន ប៉ុន្តែនៅពេលនេះមេរោគនិងជំងឺនេះនៅតែមាននៅកម្ពុជានៅឡើយទេ។

ពាក់ព័ន្ធនឹងស្ថានភាពក៏ដូចជាការវិវត្តនៃមេរោគនិងជំងឺនេះអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ទើបតែបានចេញនូវរបាយការណ៍ថ្មីមួយអំពីមេរោគនិងជំងឺនេះ នោះគឺរបាយការណ៍ទិន្នន័យឆ្នាំ២០១៩ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។

ប្រភពដដែលបានអះអាងថា ចំនួនប៉ាន់ស្មានអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជាដែលគេបានកត់ត្រានៅក្នុងឆ្នាំ២០១៩ គឺមានចំនួនប្រមាណជា ៧៣.០០០ នាក់ នៅក្នុងនោះភាគច្រើនគឺសុទ្ធតែពួកគេបានទទួលថ្នាំឬសេវាកម្មប្រឆាំងនឹងការវិវត្តនៃមេរោគ។

តួលេខដែលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបង្ហាញ គឺមានចំនួន ប្រមាណជា៦១.១៩៣ នាក់នៃអ្នកដែលផ្ទុកមេរោគ គឺបានទទួលសេវាប្រឆាំងនឹងមេរោគអេដស៍។ ប្រភពដដែលបានបន្តថា ដោយឡែកចំពោះអត្រាប្រេវ៉ាឡង់អ្នកផ្ទុកមេរោគអេដស៍សម្រាប់មនុស្សនៅក្នុងក្រុមអាយុ ពី១៥ ដល់៤៩ ឆ្នាំគឺមានចំនួនប្រមាណជា ០,៥ ភាគរយ ដូច្នេះចំនួនប៉ាន់ប្រមាណនៃអ្នកឆ្លងថ្មី គឺមានចំនួន ប្រមាណជា ៧៨០ នាក់ និងអ្នកស្លាប់គឺមានចំនួនប្រមាណជា ១.៣០០ នាក់។

ប្រភពដដែលបានបន្តថា រហូតមកដល់ពេលនេះ ក្រុមមនុស្សដែលងាយនឹងឆ្លងជំងឺនេះ មានដូចជាស្ត្រីបម្រើនៅក្នុងសេវាកម្មកំសាន្តមានប្រមាណជា ៣,២ភាគរយអ្នកប្រើប្រាស់គ្រឿងញៀនមានប្រមាណជា៥,៧ ភាគរយ អ្នកចាក់គ្រឿងញៀន មានប្រមាណជា ១៥,២ភាគរយ បុរសរួមភេទជាមួយនឹងបុរសមានប្រមាណជា ៤ភាគរយ និង ក្រុមបំប្លែងភេទមានប្រមាណជា ៩,៦ភាគរយឯណោះ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបន្តថា ដើម្បីឈានទៅលុបបំបាត់នូវមេរោគនិងជំងឺសង្គមមួយនេះ ផនៃការយុទ្ធសាស្ត្រជាតិ ដលែជាពហុវិស័យឆ្លើយតបនឹងមេរោគនិងជំងឺនេះ ត្រូវបានដាក់ចេញរួចហើយ តាំងពីឆ្នាំ២០១៩ ហើយនឹងបន្តរហូតដល់ឆ្នាំ២០២៣ ខណៈដែលកម្ពុជាត្រូវបានគេទទួលស្គាល់ថា គឺជា ប្រទេសតែមួយគត់នៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលអាចនឹងលុបបំបាត់មេរោគនិងជំងឺនេះបាននៅក្នុង ឆ្នាំ២០២៥ ខាងមុខ ។

ពាក់ព័ន្ធនឹងជំងឺអេដស៍នេះ ស្ត្រីនៅក្នុងសេវាកម្មកំសាន្តមួយរូបដែលសុំមិនបញ្ចេញឈ្មោះបាននិយាយថា នាងនៅតែភ័យខ្លាចជំងឺអេដស៍នេះ ។

នារីរូបនោះបានបញ្ជាក់ថា៖ «ឃើញសាច់ឈាមគេសថ្លា ស្អាតសង្ហារ មានទ្រព្យសម្បត្តិ ប៉ុន្តែមិនប្រាកដថា គ្មានមេរោគបានទេ»។

នារីរូបនោះបានបញ្ជាក់ថា នាងដឹងអំពីគ្រោះថ្នាក់ហេតុដូចនេះនៅក្នុងនាមជាស្ត្រីដែលស្ថិតនៅក្នុងសេវាកម្ម នេះអ្វីដែលអាចធ្វើបានមានតែប្រុងប្រយ័ត្នខ្លួន និងការពារខ្លួន ប៉ុន្តែភ្ញៀវក៏គេចេះគេយល់ និងគេមាន ការប្រុងប្រយ័ត្នចំពោះយើងផងដែរ។

នារីរូបនោះបាននិយាយលេងថា៖«អាមេរោគកូវីដ អាចមើលដឹងខាងក្រៅខ្លះបាន អាចនាំគ្នាគេចបាន តែអាមេរោគអេដស៍នេះមិនបានទេ ទាល់តែតេស្តឈាមបានដឹង»។

មេរោគនិងជំងឺអេសដ៏នៅកម្ពុជានៅមិនទាន់ផុតរលត់ទៅណានៅឡើយទេ ក្រោយពេលដែលវា បានឆ្លងរីករាលដាលដំបូងមកកាន់កម្ពុជា កាលពីឆ្នាំ១៩៩១ មកដល់ពេលនេះ ប៉ុន្តែរាជរដ្ឋាភិបាលមានគោលដៅលុបបំបាត់វានៅក្នុងឆ្នាំ២០២៥ ៕

# អ្នកជំនាញបង្ហាញហេតុផលមួយចំនួនដែល យុវជនមិនពាក់មួកសុវត្ថិភាព ពេលធ្វើដំណើរ

*អត្ថបទ៖ ផល សុផានិត*

អង្គការមូលនិធិដើម្បីបង្ការរបួសអាស៊ី និងជាសហប្រធានបណ្តាញសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានបង្ហាញហេតុផលចំនួនបីយ៉ាង ដែលយុវជនមួយចំនួនមិនគោរពច្បាប់ចរាចរណ៍ ជាពិសេសមិនពាក់មួកសុវត្ថិភាព។ ខណៈដែលយុវវ័យមួយចំនួន មិនពាក់មួកសុវត្ថិភាព លោក គឹម បញ្ញា ជានាយកប្រចាំប្រទេស នៃអង្គការខាងលើ បង្ហាញហេតុផលចំនួន ៣ រួមមាន កត្តាផ្ទាល់ខ្លួន សំដៅលើការយល់ដឹងរបស់គាត់នៅមានកម្រិត។ ទី២ កត្តាគ្រួសារ និងបរិស្ថានជុំវិញ និងទី៣ ការអនុវត្តច្បាប់មិនទាន់រឹតបន្តឹងខ្លាំង។

លោក គឹម បញ្ញា បានថ្លែងថា ៖«ខ្ញុំគិតថាចំនុចនេះវាពាក់ព័ន្ធនឹងកត្តាបីយ៉ាង ទី១កត្តាខ្លួនគាត់ គឺខ្ញុំគិតថាយើងជាយុវវ័យដែលជាអនាគតសរសរទ្រូងប្រទេសជាតិ ប្រសិនបើសរសរទ្រូងរបស់ប្រទេសជាតិយើងចាប់ផ្តើមពីទង្វើ នៅលើដងផ្លូវគាត់បំពានច្បាប់ តើយើងអាចចាត់ទុកថាជាសរសរទ្រូងប្រទេសជាតិយ៉ាងមិច បើសរសរទ្រូងជាអ្នកបំពានច្បាប់។ ទី២ កត្តាគ្រួសារ និងបរិស្ថានជុំវិញ មានន័យថាឪពុកម្តាយគួរតែ ជំរុញអោយកូន បុត្រាបុត្រីរបស់ខ្លួនជាយុវវ័យត្រូវតែចូលរួម ក្នុងការចូលរួមគោរពច្បាប់ចរាចរណ៍ពាក់មួកសុវត្ថិភាព ព្រោះប្រសិនបើកូនរបស់ខ្លួនមានបញ្ហាគ្រោះថ្នាក់ កើតឡើងអ្នកដែលខាតបង់ធ្ងន់ធ្ងរ គឺគ្រួសារដែលខិតខំ បីបាច់ថែរក្សាតាំងពីតូច ក្រូចឆ្មារមក យើងមិនគួរបណ្តោយអោយគាត់ប្រឈមជាមួយហានិភ័យ។ កត្តាចុងក្រោយគឺការអនុវត្តច្បាប់ ប្រសិនបើបុគ្គលជាយុវជន មាតាបិតារបស់យុវជន គាត់មិនបានជំរុញ មិនបានចូលរួមក្នុងការអនុវត្តច្បាប់ទេ ការអនុវត្តច្បាប់របស់នគរបាលចរាចរណ៍គួរតែធ្វើឡើង គ្រប់ពេលវេលា ព្រោះយើងធ្វើឡើងដើម្បីការពារសរសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិ»។

ជាមួយគ្នានេះ យុវជនមួយក្រុមបានយល់ឃើញបន្ទាប់ពីការបន្តឹងច្បាប់ចរាចរណ៍ផ្លូវគោក ពលរដ្ឋនិងជាពិសេសយុវវ័យ បានគោរពច្បាប់ច្រើនជាងមុន ដោយខ្លាចការផាកពិន័យជាង គ្រោះថ្នាក់ចរាចរណ៍។

កញ្ញា សំរិទ្ធ ស្រស់ ជាយុវជន បានយល់ឃើញថា ៖«បើតាមបទពិសោធរបស់ខ្ញុំ ចំពោះយុវជនសម័យនេះ គាត់មានការយល់ដឹងរឿងច្រើនជាងមុន ដោយសារតែឥលូវនេះ គេបានផ្សព្វផ្សាយអំពីច្បាប់ចរាចរណ៍ ទាំងក្នុងទូរទស្សន៍ទាំងប្រព័ន្ធផ្សព្វផ្សាយ ពួកគាត់មានចំណេះដឹងច្រើនក្នុងការបើកបរ ដូចជានៅតាមសកលវិទ្យាល័យនីមួយៗគាត់បានបញ្ចូល កម្មវិធីអប់រំ ទាក់ទងជាមួយច្បាប់ចរាចរណ៍មុនពេល ឆមាសដំបូងនៃឆ្នាំសិក្សារបស់គាត់»។

លោក សុគន្ធ កក្កដា ជាយុវជនបានយល់ថា យុវវ័យគួរតែស្វែងយល់ពីបញ្ហាសុវត្ថិភាពចរាចរណ៍ ជាជាងខ្លាចនគរបាលចរាចរណ៍ធ្វើការផាកពិន័យដើម្បីសុវត្ថិភាពអ្នកដំណើរ។

លោក សុគន្ធ កក្កដា បានបន្តថា៖ «ទាក់ទងនឹងបញ្ហាសុវត្ថិភាពចរាចរណ៍នេះត្រូវតែគោរពដាច់ខាតព្រោះនេះជាកាតព្វកិច្ច ដែលនេះមិនមែនជាករណីកិច្ច។ យើងត្រូវចងចាំថា ការបើកបរមានសារៈសំខាន់ណាស់ ប្រសិនបើយើងបើកបរដោយធ្វេសប្រហែស យើងនឹងបន្សល់ទុកនូវភាពសោកស្តាយ»។





យុវវ័យមួយចំនួននៅតែមិនពាក់មួកសុវត្ថិភាពក្នុងពេលបើកបរ ដែលអាចបណ្តាលឱ្យពួកគេប្រឈមនឹងមានគ្រោះថ្នាក់ធ្ងន់ធ្ងរ។ រូបភាព៖ ស៊ីអេសស៊ី

ឆ្នាំ២០១៩ អ្នកស្លាប់ដោយសារតែគ្រោះថ្នាក់ចរាចរណ៍មានចំនួន ជិត២០០០ នាក់ ដែលចំនួននេះមានការកើនឡើងជាងឆ្នាំ២០១៨។ ចំណែកអ្នករងរបួសមានរហូតដល់ជាង ១០០០នាក់។ បើគិតជាមធ្យមអ្នកស្លាប់ដោយសារតែគ្រោះថ្នាក់ចរាចរណ៍ អាចមានចន្លោះពី៥ទៅ៦នាក់ក្នុងមួយថ្ងៃ៕

# ផលិតផលស្ករត្នោត ខេត្តកំពង់ស្ពឺ មានតម្រូវការខ្ពស់នៅទីផ្សារក្រៅស្រុក

*អត្ថបទ៖ ផល សុផានិត*



ប្រធានសមាគមលើកកម្ពស់ស្ករត្នោតខេត្តកំពង់ស្ពឺ បានប្រាប់ឱ្យដឹងថា តម្រូវការកុម្ម៉ង់ទិញស្ករត្នោត ក្នុងខេត្តកំពង់ស្ពឺ ដែលទទួលបានការការពារ ជាផលិតផលសំគាល់ភូមិសាស្ត្រ (GI) នៅតែបន្តមានទីផ្សារទាំងក្នុង និងក្រៅប្រទេស ព្រមទាំងកំពុងទទួលបានទីផ្សារថ្មីបន្ថែមសម្រាប់នាំចេញស្ករជាបន្តបន្ទាប់។

លោក សំ សារឿន ប្រធានសមាគមលើកកម្ពស់ស្ករត្នោតខេត្តកំពង់ស្ពឺ កាលពីរសៀលថ្ងៃទី១៧ វិច្ឆិកាថា ការនាំចេញស្ករត្នោតឆ្នាំនេះ នឹងអាចកើនជាងឆ្នាំមុន ដោយសារមានតម្រូវការបន្ថែមពីភាគីឥណ្ឌា។ គិតមកដល់ពេលនេះ សមាគមមានសមាជិកសរុបចំនួន១៧០គ្រួសារ ដែលផលិតស្ករម្សៅ សម្រាប់នាំចេញទៅទីផ្សារចំនួន១៥ប្រទេសនាពេលសព្វថ្ងៃ។ ទាក់ទងនឹងក្រុមហ៊ុនថ្មីដែលចង់បាន និងនាំស្ករចេញទៅឥណ្ឌា លោកបានបញ្ជាក់ថា មូលហេតុដែលគេចាប់អារម្មណ៍ដោយសារស្ករត្នោតគ្មានសារធាតុគីមី ដូច្នេះហើយទើបគេចង់បានចំនួនរហូតដល់១០០តោន ដើម្បីនាំចេញ។

លោក បន្ថែមថា ស្ករត្នោតកំពង់ស្ពឺដែលនាំចេញទៅកាន់ទីផ្សារខាងក្រៅ មាន៥០ភាគរយ ស្មើនិងទីផ្សារក្នុងស្រុក ហើយស្ករត្នោតជាប្រភេទស្ករម្សៅពេញនិយមច្រើននៅប៉ែកអឺរ៉ុប ពិសេសប្រទេសបារាំងដែលថ្មីៗបាននាំចូលប្រមាណ២០តោនសម្រាប់បំពេញតម្រូវការប្រើប្រាស់។

សូមបញ្ជាក់ថា ស្ករត្នោតខេត្តកំពង់ស្ពឺ ត្រូវបានចុះបញ្ជីជាផលិតផលការពារដោយ EU កាលពីដើម ខែមេសា ឆ្នាំ២០១៩ ។ កម្ពុជាបានដាក់សំណើសុំចុះបញ្ជីឈ្មោះស្ករត្នោតកំពង់ស្ពឺ ជាផលិតផលសម្គាល់ភូមិសាស្ត្រ (GI) ដែលមានការការពារទៅគណៈកម្មការអឺរ៉ុប កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧។ នេះជាផលិតផល GI របស់កម្ពុជាទី២ហើយ បន្ទាប់ពីម្រេចខេត្តកំពត ត្រូវបានចុះបញ្ជីការពារកាលពីខែកុម្ភៈ ឆ្នាំ២០១៦ មក។

ក្រោយចុះបញ្ជីសម្គាល់ម៉ាកភូមិសាស្ត្ររួចមក តម្លៃនៃស្ករត្នោត បានឡើងដល់ចន្លោះ ៦,០០០ ទៅ៧,០០០រៀល ក្នុងមួយគីឡូ ខណៈដែលពីមុនអាចលក់បានក្នុងតម្លៃតែ ២,០០០ទៅ២,៥០០រៀល ប៉ុណ្ណោះ។

ក្រៅពីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក បច្ចុប្បន្នមានក្រុមហ៊ុននាំចេញស្ករត្នោត ១០ ដែលនាំចេញផលិតផលនេះទៅ ២០ ប្រទេស ហើយទិសដៅសំខាន់ៗ គឺទីផ្សារជប៉ុន ចិនកោះតៃវ៉ាន់ កូរ៉េខាងត្បូង និង EU៕

# ៨ខែដំបូងឆ្នាំនេះ វិស័យសំណង់ ទទួលបាន ជិត៩ពាន់លាន ដុល្លារអាមេរិក

*អត្ថបទ៖ ផល សុផានិត*

ក្នុងរយៈពេល៨ខែដំបូងឆ្នាំ២០២០នេះ កម្ពុជាទទួលបានការវិនិយោគវិស័យសំណង់គ្រប់ប្រភេទ ចំនួន ៣៣៥០គម្រោង និងទទួលបានជាង ៥០៨១ លានដុល្លារអាមេរិក។ នេះបើតាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញផ្សាយកាលពីពេលថ្មីៗនេះ។

ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩វិញ ឃើញថាវិស័យសំណង់នេះហាក់មានការកើនឡើងចំនួន ៤៥៥គម្រោង ឬប្រហែលជា ១៥ភាគរយ។

ប្រភពបន្ថែមថា ក្នុងចំណោមគម្រោងវិនិយោគទាំង ៣៣៥០គម្រោងនោះ មានប្រហែលជាង ១១,៤ លានក្រឡាផ្ទៃនៅទូទាំងផ្ទៃប្រទេស។ ក្នុងនោះមាន គម្រោងសំណង់លំនៅដ្ឋាន ចំនួន ៣៧៥គម្រោង ឬ ៨៤ភាគរយ។

ប្រភពបន្ថែមទៀតថា ក្នុងចំណោមគម្រោងវិនិយោគទាំងនោះ ភាគច្រើនត្រូវបានវិនិយោគនៅក្នុងរាជធានីភ្នំពេញ៕

# កម្ពុជានៅតែជាគោលដៅ ទេសចរណ៍ល្អបំផុតឆ្នាំ២០២០



*អត្ថបទ៖ ផល សុផានិត*

ក្រសួងទេសចរណ៍បានឱ្យដឹងថា ប្រទេសកម្ពុជា នៅតែជាគោលដៅទេសចរណ៍ល្អ បំផុតរបស់ពិភពលោកនៅឆ្នាំ ២០២០ ដោយសង្កត់ធ្ងន់ថា ស្ថាប័នអន្តរជាតិ និងគេហទំព័រជាច្រើន ដែលមានជំនាញវាយតម្លៃ ចំណាត់ថ្នាក់ កន្លែងទេសចរណ៍ល្អបំផុត នៅជុំវិញពិភពលោក បានចាត់ចំណាត់ថ្នាក់ប្រទេសកម្ពុជា ជាប្រទេសមួយ ក្នុងចំណោមកន្លែងល្អបំផុតសម្រាប់ទស្សនានិងរស់នៅ។

យោងតាមគេហទំព័រ My International Movers ដែលមានមូលដ្ឋាន នៅចក្រភពអង់គ្លេស សហរដ្ឋអាមេរិកនិងអូស្ត្រាលី កាលពីខែមករាឆ្នាំនេះ បានវាយតម្លៃប្រទេសកម្ពុជាលេខ១ ក្នុងចំណោមប្រទេស ដែលមានភាពរួសរាយរាក់ទាក់ខ្ពស់ជាងគេទាំង១០នៅលើពិភពលោក។

ទេសចរណ៍ Outrage នៅថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០២០ បានកំណត់ថា ប្រទេសកម្ពុជា ជាកន្លែងមួយក្នុងចំណោមកន្លែងមានសុវត្ថិភាពបំផុតទាំង ៥ នៅអាស៊ី។ នៅខែមីនាឆ្នាំ ២០២០ ប្រទេសកម្ពុជា ត្រូវបានសមាគមអ្នកនិពន្ធ តំបន់ទេសចរណ៍តំបន់ប៉ាស៊ីហ្វិក ដែលមានមូលដ្ឋាននៅប្រទេសឥណ្ឌា ពិចារណាថាប្រទេសកម្ពុជាគឺជាគោលដៅល្អបំផុត សម្រាប់បេតិកភណ្ឌ។

នៅថ្ងៃទី៩ ខែតុលាឆ្នាំ ២០២០ ការបោះពុម្ពផ្សាយរបស់ Big ៧ Travel បានរំលេចខេត្តសៀមរាប របស់ប្រទេសកម្ពុជា ជាទីតាំងមួយក្នុងចំណោម ទីតាំងលំហែកាយធំបំផុតទាំង ៧ នៅលើពិភពលោក។ ប្រឈមនឹងជំងឺរាតត្បាតកូវីដ១៩ (COVID-១៩) ក្រសួងទេសចរណ៍ បានជំរុញវិធានការ សុវត្ថិភាពលើការធ្វើដំណើរនិងទេសចរណ៍ ហើយក្រសួងក៏កំពុងរៀបចំផែនទីបង្ហាញផ្លូវ ដើម្បីស្តារវិស័យទេសចរណ៍ ឆ្នាំ ២០២១-២០២៥ ផងដែរ។

ការផ្តល់ចំណាត់ថ្នាក់ទាំងនេះ ឆ្លុះបញ្ចាំងពីសន្តិភាពនិងការអភិវឌ្ឍ នៅគ្រប់វិស័យនៃ ប្រទេសកម្ពុជាជាពិសេសភាពរឹងមាំ នៃប្រព័ន្ធសុខាភិបាល និងការចូលរួមរបស់ប្រជាជនកម្ពុជាទាំងអស់ ក្នុងការការពារការរីករាលដាលនៃ ជំងឺកូវីដ១៩ ក៏ដូចជាការចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការទាក់ទាញភ្ញៀវទេសចរ និងវិនិយោគិនអន្តរជាតិ ឱ្យមកទស្សនាកាន់តែច្រើន និងវិនិយោគនៅប្រទេសកម្ពុជាក្នុងអំឡុងពេល និងក្រោយរីកសាយនៃជំងឺកូវីដ១៩ ៕

# កម្ពុជានាំចេញ មាសជាង ២ពាន់ លានដុល្លារក្នុង រយៈពេល៨ខែ ដើមឆ្នាំ

*អត្ថបទ៖ ផល សុផានិត*

ក្នុងរយៈពេល៨ខែដំបូង ឆ្នាំ២០២០នេះ ប្រទេសកម្ពុជានាំចេញមាសកើនជាង ២,២២ ពាន់លានដុល្លារអាមេរិក ឬស្មើ៧១៦,៨ ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៩។

នៅក្នុងរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចេញផ្សាយកាលពីពេលថ្មីៗនេះ បានឱ្យដឹងថាមាសជាទំនិញនាំមុខគេ ក្នុងទំនិញនាំចេញជាច្រើនរបស់ប្រទេសកម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិ។

ដោយឡែកក្នុងរយៈពេល៩ខែដើមឆ្នាំនេះវិញ កម្ពុជាទទួលបានប្រាក់សរុបជាង ១៤,១ ពាន់លានដុល្លារ ឬកើនជិត ២១ ភាគរយ លើទំនិញសំខាន់ៗដែលនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។

ទំនិញរបស់កម្ពុជាកំពូលទាំង១០ ដែលនាំចេញទៅកាន់ទីផ្សារអន្តរជាតិ រួមមាន មាស អង្ករ កង់ គ្រឿងអេឡិចត្រូនិច ផលិតផលកសិកម្ម សណ្តែកដី គ្រាប់ស្វាយចន្ទី និងផ្លែចេកស្រស់៕

# កម្ពុជាទទួលបាន អ្នកដំណើរផ្លូវអាកាសចំនួនត្រឹមតែជាង២លាននាក់

*អត្ថបទ៖ ផល សុផានិត*

អាកាសយានដ្ឋានអន្តរជាតិទាំងបីរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល១០ខែដំបូងឆ្នាំ២០២០នេះ ទទួលបានអ្នកដំណើរសរុប ២,០៩៩,៨១២នាក់។

តាមរបាយការណ៍របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលបានឱ្យដឹងថា អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជាអាកាសយានដ្ឋានដែលទទួលបានអ្នកដំណើរច្រើនជាងគេ រហូតដល់ ១,២៧១,២៤៥ នាក់ ថយចុះ៧៤ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៩ និងតាមពីក្រោយដោយអាកាសយានដ្ឋានអន្តរជាតិ ខេត្តសៀមរាប ក្នុងចំនួន ៦១៨,៤៥៩ នាក់ ថយចុះ ៨១ភាគរយ និងអាកាសយានដ្ឋានអន្តរជាតិ ខេត្តព្រះសីហនុ ទទួលបានចំនួន ២១០ ១០៨ អ្នកដំណើរ ធ្លាក់ចុះ ៨៦ភាគរយ។

ប្រភពដដែលបន្ថែមថា ក្នុងខែតុលាកន្លងទៅ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទទួលបានអ្នកដំណើរសរុបចំនួន ៣៧ ៩០៨ នាក់ ធ្លាក់ចុះ ៩២ភាគរយ និងការដឹកជញ្ជូនតាមផ្លូវអាកាសចំនួន -២៣ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

អាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាបវិញ ទទួលបានអ្នកដំណើរចំនួនត្រឹមតែ២០១នាក់ ប៉ុណ្ណោះក្នុងខែតុលា និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ក៏ទទួលបានកំណើនធ្លាក់ចុះចំនួនអ្នកដំណើររហូតដល់ ៩៦ភាគរយ ឬ៦ ៥២៧ អ្នកដំណើរ។

កាលពីឆ្នាំ២០១៩កន្លងទៅប្រទេសកម្ពុជា ទទួលបានអ្នកដំណើរចំនួនជាង១១លាននាក់ ក្នុងកំណើនខ្ពស់រហូតដល់ ១៣ភាគរយ បើសិនប្រៀបធៀបនឹងឆ្នាំ២០១៨ ។

ការធ្លាក់ចុះនៃអ្នកដំណើរតាមផ្លូវអាកាសនេះ មិនមែនមានត្រឹមតែប្រទេសកម្ពុជានោះទេ គឺនៅទូទាំងពិភពលោកដូចគ្នា ដោយសារតែវិបត្តិដែលបណ្តាលមកពីការរីកសាយភាយនៃជំងឺកូវីដ។ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងស្ថាប័នពាក់ព័ន្ធបានចូលរួមយ៉ាងសកម្ម ក្នុងការជំរុញផ្សព្វផ្សាយនូវវិស័យទេសចរណ៍ ទាំងក្នុងប្រទេសក៏ដូចជាពិភពលោក៕





# ២០២២ ឬ ២០២៣ អ្នករស់នៅជាយរាជធានី ភ្នំពេញ នឹងមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់

*អត្ថបទ៖ ផល សុផានិត*

ប្រជាពលរដ្ឋដែលរស់នៅតំបន់ជាយរាជធានីភ្នំពេញ នឹងទទួលបានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ នៅឆ្នាំ២០២២ ឬ២០២៣ ខាងមុខ ខណៈដែលរោងចក្រប្រព្រឹត្តកម្មផលិតទឹកស្អាតទី៤ជំហានទី១ នៅសង្កាត់បាក់ខែង គ្រោងនឹងបញ្ចប់ នៅឆ្នាំ២០២៣ខាងមុខ ដើម្បីបំពេញសេចក្តីត្រូវការក្នុងការផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋ។

ថ្លែងក្នុងវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញអាណត្តិទី២ នៅព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា នាខណ្ឌពោធិ៍សែនជ័យ លោក ប៉ា សុជាតិវង្ស ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ បានមានប្រសាសន៍ថា អាជ្ញាធររាជធានីភ្នំពេញមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហាតម្រូវការទឹកស្អាតជូនប្រជាពលរដ្ឋដែលរស់នៅតំបន់ជាយក្រុង ដែលការងារនេះត្រូវអនុវត្តន៍ជាជំហានៗ ស្របពេលដែលរាជរដ្ឋាភិបាលកំពុងជំរុញការ បង្កើតស្ថានីយទឹកស្អាតបន្ថែមទៀតដើម្បីបំពេញតំរូវការរបស់ប្រជាពលរដ្ឋ។

លោក ប៉ា សុជាតិវង្ស បន្ថែមថា ការបង្កើតស្ថានីយផលិតទឹកស្អាតនីមួយៗទាមទារឱ្យមានផែនការត្រឹមត្រូវ មានជំហានអនុវត្តន៍ ការចំណាយពេលវេលា និងថវិការច្រើនក្នុងការសាងសង់។

លោកបានបន្តថា រាជរដ្ឋាភិបាលកំពុងកសាងស្ថានីយន៍ផលិតទឹកស្អាតនៅបាក់ខែងដែលនឹងរួចរាល់នៅឆ្នាំ២០២៣ ដូច្នេះវាអាចឆ្លើយតបជាមួយនឹងតំរូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងខណ្ឌពោធិ៍សែនជ័យ ខណ្ឌកំបូល និងខណ្ឌព្រែកព្នៅជាដើម។

ការបង្ហាញផែនការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជាយក្រុងនេះ គឺឆ្លើយតបទៅនឹងសំណើរបស់ប្រជាពលរដ្ឋនៅក្នុងខណ្ឌពោធិ៍សែនជ័យដែលបានលើកឡើងពីបញ្ហាខ្វះខាតទឹកស្អាតប្រើប្រាស់នៅក្នុងសង្កាត់មួយចំនួន ហើយត្រូវទិញទឹកពីភ្នាក់ងារឯកជនក្នុងតម្លៃថ្លៃរហូតដល់៣០០០ រៀលក្នុងមួយគូប។



រូបភាព៖ UNICEF Cambodia/Fani Llaurado

លោក ហេង សុផាន់ណារ៉ាត តំណាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានមានប្រសាសន៍ឆ្លើយតបទៅនឹងសំនួររបស់ប្រជាពលរដ្ឋថា តំបន់ត្រពាំងឈ្នង់ សង្កាត់សំរោងក្រោម បំពង់ទឹករបស់រដ្ឋបានទៅដល់ហើយ ដែលប្រជាពលរដ្ឋអាចតភ្ជាប់បាន ខណៈដែលតំបន់ដាច់ស្រយោលមិនមានហេដ្ឋារចនាសម្ព័ន្ធច្បាស់លាស់ និងជាដីឡូត៍ ប្រជាពលរដ្ឋអាចទៅទំនាក់ទំនងនៅផ្នែកផែនការរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីឱ្យក្រុមការងារពិនិត្យផ្ទាល់ អាចនឹងដាក់ទឹកឱ្យប្រើប្រាស់បាន។

លោកបន្តថា ចំពោះប្រជាពលរដ្ឋនៅម្តុំភូមិចំការឪឡឹក២ គឺមានបំពង់ទឹកស្អាតទៅដល់ផងដែរ នៅតែតំបន់ដីឡូត៍ និងតំបន់មិនទាន់រៀបរយ ជាពិសេសតាមផ្លូវរថភ្លើងតែម្តង ប្រសិនជាប្រជាពលរដ្ឋមិនប៉ះពាល់នៅតំបន់នេះទេ រដ្ឋាករទឹកនឹងដាក់ជូន ប៉ុន្តែជាដំណោះស្រាយចំពោះមុខរដ្ឋាករទឹកនឹងដាក់នាឡិការួមមួយ ដើម្បីបងប្អូនប្រើប្រាស់បណ្តោះអាសន្នរហូតទៅដល់រោងចក្របាក់ខែងសាងសង់រួចរាល់។

លោកបន្តថា ចំពោះប្រជាពលរដ្ឋដែលរស់នៅម្តុំសង្កាត់ត្រពាំងក្រសាំងវិញ សម្ពាធទឹកទៅមិនដល់នោះទេ ដោយសារបញ្ហាផលិតកម្មផលិតមិនទាន់តំរូវការ ដោយរង់ចាំការសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងរួចរាល់។

តាមការព្យាករណ៍របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានឱ្យដឹងថា ការប្រើប្រាស់ទឹកស្អាតនៅរាជធានីភ្នំពេញនឹងមានតម្រូវការរហូតដល់ប្រមាណជាង៩០ពាន់ម៉ែត្រគូបក្នុងមួយថ្ងៃ នៅឆ្នាំ២០២៥ និងជាង១០ម៉ឺនម៉ែត្រគូបក្នុងមួយថ្ងៃ នៅឆ្នាំ២០៣០ ខាងមុខ៕

# GMAC ណែនាំសមាជិកពីប្រព័ន្ធ អនុគ្រោះទូទៅ (GSP) របស់អង់គ្លេស



*បុគ្គលិកកំពុងបំពេញការងារក្នុងរោងចក្រមួយនារាជធានីភ្នំពេញ។ រូបភាព៖ សហការី*

*អត្ថបទ៖ ផល សុផានិត*

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) បានចេញសារណែនាំ សម្រាប់សមាជិកសមាគមស្តីពីកម្ពុជា និងប្រព័ន្ធអនុគ្រោះទូទៅ (GSP) របស់អង់គ្លេសកាលពីខែវិច្ឆិកា កន្លងមកនេះ។

GMAC បានឱ្យដឹងថា យោងទៅលើផ្នែកនៃអន្តរកាល នៃការចាកចេញពីសហភាពអឺរ៉ុបរបស់ប្រទេសអង់គ្លេស (Brexit): វិធានថ្មីសម្រាប់ឆ្នាំ២០២១ ដែលចេញដោយនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិរបស់អង់គ្លេស កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០។ ប្រទេសអង់គ្លេស បានចាកចេញពីសហភាពអឺរ៉ុប ហើយរយៈពេលអន្តរកាលបន្ទាប់ពី Brexit នឹងត្រូវបញ្ចប់នៅចុងឆ្នាំនេះ។

ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១ ប្រទេសដែលមានលក្ខណៈសម្បត្តិជាប្រទេសកំពុងអភិវឌ្ឍន៍ នឹងអាចទទួលបានការអនុគ្រោះពាណិជ្ជកម្មតាមរយៈប្រព័ន្ធ GSP របស់អង់គ្លេស។ ប្រព័ន្ធ GSP របស់អង់គ្លេសនេះ ដំបូងនឹងផ្តល់ការអនុគ្រោះពាណិជ្ជកម្មទៅប្រទេសនានាដូច GSP របស់សហភាពអឺរ៉ុបដែរ។ ប្រព័ន្ធ GSP របស់អង់គ្លេស នឹងមានក្របខ័ណ្ឌចំនួន៣៖ ក្របខ័ណ្ឌប្រទេសអភិវឌ្ឍតិចតួចបំផុត, ក្របខ័ណ្ឌទូទៅ និងក្របខណ្ឌប្រសើរឡើង។

កម្ពុជា ដែលត្រូវបានចាត់ថ្នាក់ ដោយអង្គការសហប្រជាជាតិថា ជាប្រទេសអភិវឌ្ឍតិចតួចបំផុត គឺស្ថិតនៅក្នុងក្របខ័ណ្ឌប្រទេសអភិវឌ្ឍតិចតួចបំផុត។ ហេតុដូច្នេះ កម្ពុជា នឹងទទួលបានការនាំចេញដោយមិនជាប់ពន្ធ និងមិនជាប់ការកំរិតកូតា ទៅកាន់ប្រទេសអង់គ្លេស សម្រាប់ទំនិញទាំងអស់ លើកលែងតែអាវុធ និងគ្រឿងផ្ទុះ។ នេះគឺដូចគ្នានឹងគម្រោង EBA ក្រោមប្រព័ន្ធ GSP របស់សហភាពអឺរ៉ុប។

សមាគម កំពុងធ្វើការងារជាមួយក្រសួងពាណិជ្ជកម្មកម្ពុជា និងសមភាគីអង់គ្លេស ដើម្បីសុំការបំភ្លឺអំពីការផ្លាស់ប្តូរមួយចំនួន នៅក្នុងនីតិវិធីរដ្ឋបាល (ប្រសិនបើមាន) ដូចជាការបញ្ជាក់ប្រភពដើមកំណើតទំនិញ កាលបរិច្ឆេទចូលជាធរមាននៃការអនុវត្ត (ថាតើកាលបរិច្ឆេទនៃការដឹកជញ្ជូន ឬកាលបរិច្ឆេទ នៃការទៅដល់)។ GMAC នឹងផ្តល់ព័ត៌មានបន្ថែមសមាជិក នៅពេលទទួលបានការបំភ្លឺ៕

# ជប៉ុនបើកជើងហោះហើរត្រង់រវាងទីក្រុងតូក្យូ និងរាជធានីភ្នំពេញឡើងវិញ នៅដើមខែធ្នូនេះ

*អត្ថបទ ៖ ផល សុផានិត*

បន្ទាប់ពីផ្អាកប្រតិបត្តិការហោះហើរត្រង់រវាងទីក្រុងតូក្យូ (ណារីតា) និងរាជធានីភ្នំពេញមួយរយៈធំដោយសារវិបត្តិនៃជំងឺកូវីដ១៩ នៅពេលនេះ ក្រុមហ៊ុនអាកាសចរណ៍ All Nippon Airways (ANA) របស់ជប៉ុនបានប្រកាសថា ខ្លួននឹងដំណើរការហោះហើរត្រង់ឡើងវិញនៅដើមខែធ្នូ ឆ្នាំ២០២០នេះ។

ការសម្រេចហោះហើរឡើងវិញនេះ គឺជាដំណឹងល្អមួយដែលបង្ហាញពីការទុកចិត្តពីសំណាក់ក្រុមហ៊ុនអាកាសចរណ៍របស់ជប៉ុន ក៏ដូចជាប្រជាជនជប៉ុនលើរាជរដ្ឋាភិបាលកម្ពុជា ដែលបានធ្វើការគ្រប់គ្រងបញ្ហាជំងឺកូវីដ១៩ យ៉ាងល្អប្រសើរ រហូតដល់អន្តរជាតិ វាយតម្លៃថាកម្ពុជាជាប្រទេសលេខ១ ក្នុងអាស៊ី និងលេខ៣ លើពិភពលោកលើការងារគ្រប់គ្រងបញ្ហាកូវីដ១៩ បានល្អប្រសើរ។

ដំណឹងនៃការហោះហើរឡើងវិញនេះ ត្រូវបានស្ថានទូតជប៉ុនប្រចាំកម្ពុជា បង្ហោះលើគេហទំព័រផ្លូវការរបស់ខ្លួនថា «នៅថ្ងៃទី២៥ ខែវិច្ឆិកា ក្រុមហ៊ុនអាកាសចរណ៍ All Nippon Airways (ANA) បានប្រកាសថា ក្រុមហ៊ុននឹងដំណើរការជើងហោះហើរត្រង់រវាងទីក្រុងតូក្យូ (ណារីតា) និងភ្នំពេញ នៅថ្ងៃទី២ ទី៥ ទី៩ ទី១២ ទី១៦ ទី១៩ ខែធ្នូ ឆ្នាំ២០២០ និងថ្ងៃទី៩ និងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១»។

យ៉ាងណាមិញមានការបារម្ភពីប្រតិបត្តិការហោះហើរឡើងវិញរបស់ក្រុមហ៊ុននេះ ប្រសិនបើមិនអាចទ្រទ្រង់សុខភាពសេដ្ឋកិច្ចរបស់ខ្លួនបាន ក្រុមហ៊ុននេះប្រហែលជាអាចនឹងពិចារណាឡើងវិញលើប្រតិបត្តិការហោះហើរនេះ។

ចំពោះដំណឹងការហោះហើរនេះ លោក ស៊ិន ចាន់សិរីវុត្ថា អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលកម្ពុជា បានថ្លែងនូវការស្វាគមន៍ចំពោះការវិលត្រឡប់ហោះហើរត្រង់ឡើងវិញនេះ តែលោកបារម្ភថា វិធានការសុខាភិបាលជាសាកល អាចនៅតែជាបញ្ហាប្រឈមទៅនឹងប្រតិបត្តិការហោះហើរជាប្រក្រតីឡើងវិញ៕



*ក្នុងមួយថ្ងៃស្រូវសរុបមានចំនួន ២២.១៣១ តោនត្រូវបាននាំចេញទៅប្រទេសវៀតណាម ខណៈការនាំចេញតាមច្រកព្រំដែននៃខេត្តព្រៃវែងតែមួយ គឺមានចំនួនសរុប ១០.៥២៤ តោនក្នុងមួយថ្ងៃ។* ***រូបភាព៖ អង្គការអុកស្វាមប្រចាំនៅកម្ពុជា***

# ជំងឺកូវីដ១៩ ប៉ះពាល់ដល់វិស័យធំៗជាច្រើន ប៉ុន្តែសម្រាប់កសិកម្មមិនរងសំពាធឡើយ

*អត្ថបទ៖ អរិយបុត្រ*

ដោយសារតែកូវីដ១៩សរសរស្តម្ភផ្សេងៗនៃវិស័យសេដ្ឋកិច្ចគឺសុទ្ធតែរងនូវសំពាធនិងផលប៉ះពាល់ ប៉ុន្តែវិស័យកសិកម្មនៅតែមានរបាយការណ៍និងសេចក្តីរាយការណ៍អំពីភាពវិជ្ជមានជាបន្តបន្ទាប់ ។

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរាយការណ៍ជាបន្តបន្ទាប់អំពីស្ថានភាពវិជ្ជមាននៃវិស័យកសិកម្ម ទោះបីជាវិស័យនេះបានរងគ្រោះរយៈពេលខ្លីដោយសារតែគ្រោះទឹកជំនន់ កាលពីខែតុលាកន្លងទៅនេះក៏ដោយ។

ក្រោយពេលទឹកជំនន់និងកូវីដ១៩កំពុងតែរាតត្បាតនៅលើពិភពលោក ផលិតផលស្រូវរបស់ប្រទេសកម្ពុជាកំពុងហូរទៅកាន់ទីផ្សារក្នុងប្រទេសវៀតណាម ខណៈដែលកសិករក្នុងស្រុកកំពុងតែប្រមូលផលស្រូវនារដូវប្រមូលផលឆ្នាំថ្មី។

លោក វេង សាខុន បានមានប្រសាសន៍ថា៖ «ក្នុងមួយថ្ងៃស្រូវសរុបមានចំនួន ២២,១៣១ តោនត្រូវបាននាំចេញទៅប្រទេសវៀតណាម»។ លោកបានអះអាងថា ការនាំចេញតាមច្រកព្រំដែន នៃខេត្តព្រៃវែងតែមួយ គឺមានចំនួនសរុប ១០,៥២៤ តោនក្នុងមួយថ្ងៃ ប៉ុន្តែជាទូទៅបើបើកនឹងការនាំចេញនៅតាមច្រកផ្សេងៗទៀត ក្នុងមួយថ្ងៃមានបរិមាណសរុបប្រមាណជា ២២,១៣១ តោន ។



*លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម។* ***រូបភាព៖ ក្រសួងកសិកម្ម***

ខេត្តព្រៃវែងមិនមែនជាច្រកនាំចេញស្រូវទៅកាន់ប្រទេសវៀតណាមតែមួយនោះទេ ក្រៅពីខេត្តនេះកម្ពុជានៅមានច្រកនាំចេញ ទៅកាន់ខេត្តមួយចំនួនទៀត ដូចជាស្វាយរៀង តាកែវ កំពង់ចាម កំពតជាដើម។

បើតាមលោករដ្ឋមន្ត្រី វេង សាខុន រហូតដល់ថ្ងៃទី ១២ ខែវិច្ឆិកា មានស្រូវសរុបចំនួន ១,៥៣៦,៣៥០ តោនត្រូវបាននាំចេញទៅប្រទេសវៀតណាមក្នុងតម្លៃខុសគ្នាអាស្រ័យលើគុណភាពនិងពូជស្រូវ ស្រូវដូចជា រំដួលមានតម្លៃ ១,១៣០ រៀលក្នុងមួយគីឡូក្រាម អ៊ីអ៊ែ ៥០៤ គឺ ៩២០ រៀល និងអូអឹម ៥៤៥១ គឺ ៩១០ រៀល ក្នុង ១គីឡូក្រាម។

លោក យ៉ាន មុត ប្រធានសហគមន៍មានជ័យ នៅស្រុកបាភ្នំខេត្តព្រៃវែងបានឱ្យដឹង ថាឈ្មួញកណ្តាល បានចុះមកទិញស្រូវពីកសិករនៅក្នុងសហគមន៍របស់គាត់សម្រាប់នាំចេញទៅប្រទេសវៀតណាម អស់រយៈពេលជិតមួយខែមកហើយ។

លោកបានគូសបញ្ជាក់ថា៖ «ឈ្មួញកណ្តាលបានមកទិញផ្ទាល់ពីកសិកររបស់យើងហើយបាននាំចេញទៅវៀតណាមប្រហែល ៤ ទៅ ៥ ឡានក្នុងមួយថ្ងៃ»។

លោក សេង វ៉ាន់ ប្រធានសហគមន៍ព្រៃក្រាំងមានរិទ្ធិ នៅស្រុកដងទង់ ខេត្តកំពតក៏បានចែករំលែកដំណឹងល្អអំពីតម្លៃស្រូវផងដែរ។

កាលពីឆ្នាំមុនតម្លៃរបស់វាបានធ្លាក់ចុះដល់ ៧០០រៀល ដល់ ៨០០រៀលក្នុងមួយគីឡូក្រាម ហើយពេលខ្លះឈ្មួញកណ្តាលមិនបានមកទិញទេ ប៉ុន្តែឆ្នាំនេះតម្លៃនៅតែល្អខ្លះ ១០០០រៀល ក្នុងមួយគីឡូក្រាម។

លោកបន្ថែមថា៖ «កាលពីខែតុលា ឆ្នាំ២០២០ យើងលក់បានត្រឹមតែ ៩៥០រៀល ហើយថ្ងៃនេះយើងអាចលក់បានក្នុងតម្លៃ ១,០១០រៀលក្នុងមួយគីឡូក្រាម»។

បច្ចុប្បន្នប្រទេសវៀតណាមគឺជាប្រទេសមួយក្នុងចំណោមអ្នកទិញស្រូវអង្កររបស់ប្រទេសកម្ពុជា ប៉ុន្តែការនាំចេញភាគច្រើនមិនមានកំណត់ត្រាច្បាស់លាស់ទេហើយខ្លះទៀតត្រូវបានធ្វើដោយសារការរត់ពន្ធ។











> ការនាំចេញតាមច្រកព្រំដែន នៃខេត្តព្រៃវែងតែមួយ គឺមានចំនួនសរុប ១០.៥២៤ តោនក្នុងមួយថ្ងៃ ប៉ុន្តែជាទូទៅបើបើកនឹងការនាំចេញនៅតាមច្រកផ្សេងៗទៀត ក្នុងមួយថ្ងៃមានបរិមាណសរុបប្រមាណជា ២២.១៣១ តោន





*ព្រះរាជាណាចក្រកម្ពុជាទទួលបានចំណូលសរុបពីការនាំចេញអង្ករសរុបចំនួន ៣៦៦,៤លានដុល្លារក្នុងរយៈពេលពីខែមករាដល់ខែតុលា។ រីឯចំណិតដំឡូងមីក្រៀម សម្រេចបាន ១.២០២.៦៤៤,៨១តោន បាននាំចេញទៅកាន់ប្រទេសថៃ និងវៀតណាម* ***រូបភាព៖ សហការី***

ក្រៅពីនាំចេញទៅប្រទេសជិតខាងប្រទេសកម្ពុជាក៏បាននាំចេញអង្ករដោយផ្ទាល់ទៅទីផ្សារអន្តរជាតិផងដែរ។

យោងតាមសហព័ន្ធស្រូវអង្ករកម្ពុជា ប្រទេសកម្ពុជាបាននាំចេញអង្ករចំនួន ៥៣៦,៣០៥ តោនក្នុងរយៈពេល ១០ ខែដំបូងនៃឆ្នាំ ២០២០ ដែលជាការកើនឡើង ១៧,១១ ភាគរយ ។

ប្រទេសចិននៅតែជាទីផ្សារធំបំផុតសម្រាប់អង្ករកម្ពុជា។ ក្នុងរយៈពេល១០ខែនេះប្រទេសចិននិងដែនដីស្វយ័តផ្សេងទៀត ដូចជា (ហុងកុង ម៉ាកាវ និងកោះផ្តាច់ខ្លួនតៃវ៉ាន់) ទទួលបាន ៣៦ ភាគរយនៃការនាំចេញសរុប ។ ដោយឡែក២៧ ប្រទេសនៅអឺរ៉ុបគឺមានចំណែកទីផ្សារ ៣២ ភាគរយ ក្រៅពីនោះនៅមាន អាស៊ាន អាហ្វ្រិក និងអូសេអានី ថែមទៀតផង ។

តួលេខពីសហព័ន្ធស្រូវអង្ករកម្ពុជាបានបង្ហាញថា ព្រះរាជាណាចក្រកម្ពុជាទទួលបានចំណូលសរុបពីការនាំចេញអង្ករសរុបចំនួន ៣៦៦,៤លានដុល្លារក្នុងរយៈពេលពីខែមករាដល់ខែតុលា។

លោក ងួន ឡាយ ប្រធានសមាគមលើកកម្ពស់ម្រេចកំពតបាននិយាយថា កូវីដ ១៩ មិនបានប៉ះពាល់ដល់ទីផ្សារបរទេសរបស់ម្រេចកំពតនៅឡើយទេ ខណៈទិសដៅនាំចេញរបស់ម្រេច នៅតែខ្លាំងសម្រាប់ឆ្នាំក្រោយ។

ទិន្នផលដែលមានគុណភាពខ្ពស់និងសក្តានុពលរបស់ ម្រេចកំពតក្នុងមួយឆ្នាំៗមានប្រហែល ៧០ ទៅ ៨០ តោនហើយភាគច្រើនត្រូវបាននាំចេញទៅទីផ្សារបរទេសផ្សេងៗគ្នារួមមានសហភាពអឺរ៉ុប អាមេរិក ជប៉ុន កូរ៉េខាងត្បូង ហុងកុង និង តៃវ៉ាន់។

លោក ងួន ឡាយ បានមានប្រសាសន៍ថា៖ «ម្រេចកំពតត្រូវបាននាំចេញច្រើនជាង ៥០ តោន ក្នុងឆ្នាំនេះហើយសង្ឃឹមថាវានឹងមានច្រើនសម្រាប់ឆ្នាំក្រោយពីព្រោះការបញ្ជាទិញពីដៃគូបរទេសត្រូវបានបញ្ជាក់ថានៅតែល្អ»។

> ...ក្រៅពី ៥០ តោន (ម្រេច) សម្រាប់នាំចេញយើងមានប្រហែល ២០ ទៅ ៣០ តោនសម្រាប់ភ្ញៀវទេសចរបរទេស ដែលមកលេងប្រទេសកម្ពុជា...



*លោក ងួន ឡាយ ប្រធានសមាគមលើកកម្ពស់ម្រេចកំពត។* ***រូបភាព៖ សមាគមលើកកម្ពស់ម្រេចកំពត***

លោក ងួន ឡាយ ក៏បានមានប្រសាសន៍ថា កូវីដ-១៩ បានជះឥទ្ធិពលដល់វិស័យទេសចរណ៍ សេវាកម្ម និងឧស្សាហកម្មកាត់ដេរ ប៉ុន្តែមិនជះឥទ្ធិពលច្រើន ទៅលើវិស័យកសិកម្មទេពីព្រោះមនុស្សម្នាក់ៗត្រូវការអាហារនិងគ្រឿងផ្សំ។

លោកបានបន្ថែមថា រហូតមកដល់ពេលនេះ កូវីដ១៩ បានជះឥទ្ធិពលដល់វិស័យទេសចរណ៍ ដូច្នេះយើងបានបាត់បង់ចំណែក ទីផ្សារក្នុងស្រុកមួយចំនួន។

លោកបានបន្ថែមថា៖ «ក្រៅពី ៥០ តោន សម្រាប់នាំចេញយើងមានប្រហែល ២០ ទៅ ៣០ តោនសម្រាប់ភ្ញៀវទេសចរបរទេសដែលមកលេងប្រទេសកម្ពុជា ប៉ុន្តែនៅពេលប្រទេសរបស់យើងមិនមានភ្ញៀវទេសចរបរទេសយើងអាចប្តូរទៅរកទីផ្សារផ្សេងទៀតរួមទាំងប្រទេសវៀតណាមផងដែរ»។

ម្រេចកំពតគឺជាផលិតផលសម្គាល់ភូមិសាស្ត្រ (GI) ហើយមាន ៣ ប្រភេទ គឺម្រេចខ្មៅ ក្រហមនិងស ដោយតម្លៃវិញគឺត្រូវបាន លក់ក្នុងតម្លៃប្រហែល ១៥ ដុល្លារ ២៥ ដុល្លារនិង ២៨ ដុល្លារក្នុងមួយគីឡូក្រាម។

ក្រៅពីស្រូវ អង្ករ និងម្រេច កម្ពុជានៅមានផលិតផលកសិកម្មផ្សេងៗទៀត ហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គឺបានរាយការណ៍ថា សុទ្ធតែមានស្ថានភាពវិជ្ជមាន ។

ចំពោះការនាំចេញផលិតផលកសិកម្ម ក្នុងរយៈពេល ៩ខែ ឆ្នាំ២០២០ ក្រសួងបានពិនិត្យឃើញថាមានការកើនឡើងល្អប្រសើរ គឺមានបរិមាណសរុប ចំនួនជាង ៥,៨ លាន តោន ដែលក្នុងនេះមានផលិតផលសំខាន់ៗមួយចំនួន ដូចជា គ្រាប់ស្វាយចន្ទី សម្រេចបាន ២០៤,២០៨ តោន មានកំណើន ២០,៥%, នាំចេញទៅកាន់ប្រទេស វៀតណាម, ជប៉ុន, រុស្ស៊ី, ចិន, ហុងកុង, បារាំង, កូរ៉េ, តួគី, បង់ក្លាដេស និងថៃ ។ គ្រាប់ពោត សម្រេចបាន ១៩៣,៩៥០ តោន បាននាំចេញទៅកាន់ប្រទេសថៃ, កូរ៉េ និងកោះតៃវ៉ាន់។ ចេកស្រស់ សម្រេចបាន ២៣៥,១៧១,៦៣ តោន មានកំណើន ២២៥,៦៩% បាននាំចេញទៅកាន់ប្រទេស ចិន វៀតណាម និងជប៉ុន។ ក្រូចថ្លុង សម្រេចបាន ១៥,១៥០ តោន ទៅកាន់ប្រទេសថៃ។ ដំណាប់ស្វាយ សម្រេចបាន ៤,៩៩៨,៦៤ តោន បាននាំចេញទៅកាន់ប្រទេស ចិន, ជប៉ុន, ថៃ, កូរ៉េ, ហ្វីលីពីន និងវៀតណាម។ ដំឡូងមីស្រស់ សម្រេចបាន ១,៧៨០,៤៩៦ តោន បាននាំចេញទៅកាន់ប្រទេស វៀតណាម និងថៃ ទាំងផ្លូវការ និងក្រៅផ្លូវការ។ ចំណិតដំឡូងមីក្រៀម សម្រេចបាន ១,២០២,៦៤៤,៨១ តោន បាននាំចេញទៅកាន់ប្រទេសថៃ និងវៀតណាម (ផ្លូវការ)។ ម្សៅដំឡូងមី សម្រេចបាន ១២,០០២ តោន បានថយចុះ ៥៦,៧២%, បាននាំចេញទៅកាន់ប្រទេស ឥណ្ឌា, ចិន, ប៊ែលហ្ស៊ិក, ហូឡង់, ប៉ាគីស្ថាន, ឆេក, ក្រូអាត និងអ៊ីតាលី។ ស្វាយស្រស់ សម្រេចបាន ៦២,៩២០,៥៦ តោន មានកំណើន ១៥៨,៨៣%, បាននាំចេញទៅកាន់ប្រទេស ថៃ, វៀតណាម, បារាំង, រុស្ស៊ី, កូរ៉េ និងហុងកុង។ បន្លែ សម្រេចបាន ៨៧,៥៧ តោន នាំចេញទៅកាន់ប្រទេសបារាំង, ឆេក និងប្រទេសហូឡង់។ ទន្ទឹមនឹងនេះកម្ពុជាក៏មានផលិតផលកសិកម្មជាច្រើនមុខដទៃទៀតដែលបាននាំចេញ៕

# រដ្ឋាភិបាលកម្ពុជា ចេញសារាចរណែនាំ ៧ចំណុចស្តីពីការពង្រឹងការអនុវត្តវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន

*អត្ថបទ៖ ផល សុផានិត*

រាជរដ្ឋាភិបាលកម្ពុជា បានចេញសារាចរណែនាំ ៧ចំណុច ដើម្បីពង្រឹងការអនុវត្តវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

ដោយកត់សម្គាល់ឃើញថា សកម្មភាពលបលួចនាំចូល ដឹកជញ្ជូនគ្រឿងញៀនឆ្លងកាត់ ការលួចលាក់កែច្នៃសារធាតុញៀន នៅតែកើតមានឡើងជាបន្តបន្ទាប់ និងមានរូបភាពកាន់តែធំ ហើយការជួញដូរ និងការប្រើប្រាស់សារធាតុញៀនបាននិងកំពុងរីករាលដាលដល់តំបន់ជនបទមួយចំនួន។

រាជរដ្ឋាភិបាលកម្ពុជា បានឱ្យដឹងទៀតថា ក្នុងគោលបំណងធានាប្រសិទ្ធភាពអនុវត្តន៍កម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ក៏ដូចជាការបញ្ចៀសឱ្យបាននូវហានិភ័យដែលបណ្តាលមកពីគ្រឿងញៀន ព្រមទាំង ដោះស្រាយនូវការព្រួយបារម្ភ និងការពារសុខុមាលភាពជូនប្រជាពលរដ្ឋ ធានាបាននូវស្ថិរភាព សន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម។





*សារាចរណែនាំរបស់រាជរដ្ឋាភិបាល និងរូបភាពជនល្មើស និងគ្រឿងញៀនដែលប៉ូលីសរឹបអូសបាន កាលពីពេលកន្លងទៅ។* ***រូបភាព៖ សហការី***

រាជរដ្ឋាភិបាល សូមធ្វើការ ណែនាំដល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសគណៈបញ្ជាការឯកភាពរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងសារាចរណែនាំបានបន្តថា បន្តខិតខំចាត់តាំងអនុវត្តឱ្យបានម៉ឺងម៉ាត់តាមបទបញ្ជាលេខ ០១ប.ប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

បង្កើនសកម្មភាពអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥ ឱ្យបានសកម្មភាពផុលផុស និងត្រូវបន្តកសាងផែនការយុទ្ធនាការជាបន្តបន្ទាប់ ប្រកបដោយនិរន្តរភាព។ លើសពីនេះ លើកកម្ពស់ស្មារតីផ្សព្វផ្សាយ អប់រំឱ្យបានទូលំទូលាយ ស៊ីជម្រៅចំគោលដៅ និងមុខសញ្ញាគ្រប់ទីកន្លែងទាំងក្នុងសហគមន៍ ទាំងក្នុងស្ថាប័នរដ្ឋ ឯកជន និងក្នុងជួរកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយត្រូវអនុវត្តន៍ផ្សារភ្ជាប់ជាមួយខ្លឹមសារទិសស្លោក «បីកុំ មួយរាយការណ៍» គឺ កុំពាក់ព័ន្ធ កុំអន្តរាគមន៍ កុំលើកលែង និងត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចគ្រប់ករណីបទល្មើសគ្រឿងញៀន។

រាជរដ្ឋាភិបាល ក៏បានអំពាវនាវអោយ យកចិត្តទុកដាក់ចាត់វិធានការក្នុងការបង្ការ ទប់ស្កាត់ការនាំចូល ការដឹកជញ្ជូនឆ្លងកាត់ការលួចលាក់កែច្នៃ-ផលិតសារធាតុញៀន និងការជួញដូរ ប្រើប្រាស់សារ ធាតុញៀន ជាពិសេសនៅតាមគោលដៅនានា។

ត្រូវពង្រឹងវិធានការគ្រប់គ្រង ត្រួតពិនិត្យការនាំចូល និងការប្រើប្រាស់សារធាតុគីមីផ្សំ ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់បំផុតទៅតាមវិធានបច្ចេកទេស និងត្រូវដកពិសោធន៍ធ្វើបច្ចុប្បន្នភាពជាប្រចាំ សំដៅបង្ការមិនឱ្យសារធាតុគីមីផ្សំធ្លាក់ក្នុងដៃឧក្រិដ្ឋជនយកទៅកែច្នៃធ្វើជាសារធាតុញៀនជាដាច់ខាត។

ប្រភពដដែលបន្ថែមថា ការលើកកម្ពស់គុណភាពក្នុងការអនុវត្តវិធានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម ដោយខិតខំឱ្យអស់ពីលទ្ធភាពលើកកម្ពស់សមត្ថភាពព្យាបាល ស្តារនីតិសម្បទា និងរៀបចំបន្ថែមនូវមណ្ឌលបណ្តោះអាសន្ននៅតាមរាជធានី ខេត្ត ស្របតាមភូមិសាស្រ្ត និងសំណូមពរជាក់ស្តែង។ លើកកម្ពស់គុណភាព សមត្ថភាពមន្រ្តីអនុវត្តច្បាប់ តាមរយៈការបណ្តុះបណ្តាលជំនាញប្រតិបត្តិការ និងចំណេះដឹងផ្នែកច្បាប់។

ទន្ទឹមនេះ ត្រូវពង្រឹងការអនុវត្តវិន័យ សីលធម៌ មនសិការ វិជ្ជាជីវៈដល់កងកម្លាំងអនុវត្តច្បាប់ប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យបានល្អប្រសើរព្រមទាំងបន្តការគាំទ្រ សរសើរជូនរង្វាន់ លើកទឹកចិត្តដល់អង្គភាព និងមន្រ្តីដែលមានស្នាដៃ៕

# យុវជនហាត់ល្ខោនស្បែកធំ ដោយមិនគិតលើកម្រៃ ព្រោះតែក្តីស្រឡាញ់

*អត្ថបទ៖ ផល សុផានិត*

យុវជនដែលទទួលបានការបណ្តុះបណ្តាលជំនាញល្ខោនស្បែកធំក្នុងរយៈពេលជិត១០ឆ្នាំមកនេះ លើកឡើងថាខ្លួនហាត់របាំនេះ ដោយសារចិត្តស្រឡាញ់សម្បត្តិវប្បធម៌ជាតិ និងមិនដែលគិតថារកប្រាក់ចំណូលពីល្ខោននេះនោះទេ។

ការលើកឡើងនេះ ក្នុងឱកាសគម្រប់ខួបទី១៥ឆ្នាំនៃការដាក់បញ្ចូលល្ខោនស្បែកធំចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០២០នេះ។

យុវជនដែលទទួលបានការបណ្តុះបណ្តាលនៅសាលាមធ្យមសិក្សាវិចិត្រសិល្បៈ បានលើកឡើងថា ក្នុងឱកាសនៃខួប១៥ឆ្នាំនៃល្ខោនស្បែកធំចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនេះ ថាខ្លួនហ្វឹកហាត់ល្ខោននេះ ចេញពីចិត្តស្រឡាញ់ និងមិនដែលគិតថារកប្រាក់ចំណូលពីល្ខោននេះនោះទេ ព្រោះពួកគេមើលឃើញថាល្ខោនស្រមោលស្បែកធំ ពុំសូវទទួលបានការអញ្ជើញសម្តែងដូចល្ខោន ឬរបាំផ្សេងៗនោះទេ។

លោក សំ តុលា ជាសិល្បករជំនាញល្ខោនស្រមោលស្បែកធំ បានលើកឡើងថា៖ «ខ្ញុំនិយាយចេញពីចិត្ត ខ្ញុំមិនដែលគិតពីលុយកាក់នោះទេ ព្រោះណាមួយគ្រូក៏បានប្រាប់ដែរថា បើសិនជាយើងចង់ធ្វើសិល្បៈ បើយើងចង់មានកុំមករកសិល្បៈ។ ចិត្តខ្ញុំគិតបែបនេះ ខ្ញុំធ្វើនេះគឺចេញពីចិត្ត មិនមែនយើងស្រឡាញ់តែមាត់»។

ចំណែកសិល្បករមួយរូបទៀត លោក សុចិត្រ បុតា បានឱ្យដឹងថា៖«ការហាត់រៀនរបាំនេះដោយសារចិត្តស្រឡាញ់ ល្ខោនស្បែកមិនសូវមានទីផ្សារនោះទេ ល្ខោនស្បែកមានតែក្នុងកម្មវិធីធំៗ លុះត្រាតែមេដឹកនាំធំៗចង់បាន ទៅសម្តែង»។

ក្រោយរយៈពេល១៥ឆ្នាំនៃល្ខោនស្រមោលស្បែកធំត្រូវបានចុះបញ្ជីជាបេតិកភណ្ឌពិភពលោក លោក ម៉ាន កុសល ជាសាស្ត្រាចារ្យល្ខោនស្រមោលស្បែកធំ បានលើកឡើងផងដែរថា ការផ្សព្វផ្សាយនិងការចាប់អារម្មណ៍របស់សិស្សក្នុងការហ្វឹកហាត់គឺមានភាពប្រសើរជាងមុន។ សម្រាប់ក្រុមធំដើម្បីសម្តែងតែម្តង នៅមានចំនួនតិចតួចនៅឡើយ។

លោក ម៉ាន កុសល បានឱ្យដឹងថា៖ «តុល្យភាពនៃរយៈពេល១៥ឆ្នាំនេះ យើងឃើញថាការផ្សព្វផ្សាយឱ្យមានភាពទូលំទូលាយ មានកម្រិតមួយខ្ពស់ជាងមុន។ បច្ចុប្បន្ននេះអ្វីដែលយើងបាននោះគឺយើងមានសិស្សច្រើនជាងមុន កាលពីមុនសិស្សានុសិស្សមិនសូវចាប់អារម្មណ៍នោះទេ ព្រោះស្បែកនេះត្រូវចំណាយលុយច្រើនណាស់ ដើម្បីផលិត»។

ថ្ងៃទី២៥ ខែវិច្ឆិកា ដែលជាថ្ងៃគម្រប់ខួប១៥ឆ្នាំនៃការចុះក្នុងបញ្ជីអរូបិយរបស់អង្គការយូណេស្កូ គឺមិនមានការសម្តែងល្ខោនស្រមោលស្បែកធំ ផ្ទាល់នោះទេ ដោយសារតែជំងឺកូវីដ១៩ បើទោះបីជាមិនមានការសម្តែងផ្ទាល់ក្តី តែក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏បានរៀបចំថតការសម្តែងល្ខោនស្រមោលស្បែកធំ ហើយនឹងមានការចាក់ផ្សាយ ក្នុងគេហទំព័រហ្វេសប៊ុកផ្លូវការ របស់ក្រសួងផ្ទាល់។

ជាមួយគ្នានេះដែរ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានព្រះរាជឧបត្ថម្ភដ៏ឧត្តុង្គឧត្តមវិសេសវិសាលបំផុត ចំពោះការចម្លងឡើងវិញនូវស្បែកធំមួយឈុត ចំនួន៩០ផ្ទាំង សម្រាប់តម្កល់បម្រើជាឧត្តមប្រយោជន៍របស់ជាតិកម្ពុជា៕





*ការសម្តែងល្ខោនស្បែកធំ។ យុវជនដែលទទួលបានការបណ្តុះបណ្តាល ជំនាញល្ខោនស្បែកធំ មិនរំពឹងអំពីការរកប្រាក់ចំណូលពីល្ខោននេះនោះទេ។* ***រូបភាព៖ សហការី***





# គម្រោងទប់ស្កាត់នឹងសំណល់ប្លាស្ទិកក្នុងសមុទ្រនៅកម្ពុជា ត្រូវបានចុះហត្ថលេខា



*ប្លាស្ទិកនៅក្នុងសមុទ្រ ពិតជាកំពុងបង្កគ្រោះថ្នាក់ខ្លាំងបំផុតដល់ជីវិតសត្វ និងមនុស្ស។* ***រូបភាព៖ បរទេស***

*អត្ថបទ៖ ផល សុផានិត*

ស្ថានទូតជប៉ុន និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តន៍ «គម្រោងទប់ស្កាត់នឹងសំណល់ប្លាស្ទិកក្នុងសមុទ្រនៅកម្ពុជា» កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ កន្លងមកនេះ។

គម្រោងនេះនឹងត្រូវបានអនុវត្តន៍ដោយក្រសួងបរិស្ថាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និង UNDP ដោយមានគោលបំណងទប់ស្កាត់ និងកាត់បន្ថយឱ្យបានជាអតិបរមានូវការបំពុលដោយសំណល់ប្លាស្ទិកលើដី និងក្នុងសមុទ្រ តាមរយៈការជំរុញឱ្យមានការអនុវត្តតាមគោលការណ៍ 4Rs (កុំប្រើ-Refuse កាត់បន្ថយ-Reduce ប្រើឡើងវិញ-Reuse និងកែច្នៃយកមកប្រើប្រាស់-Recycle)។

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសជប៉ុនប្រចាំកម្ពុជា



*ពិធីចុះហត្ថលេខលើឯកសារស្តីពីការទប់ស្កាត់សំណល់ប្លាស្ទិកសមុទ្រ។* ***រូបភាព៖ ក្រសួងបរិស្ថាន***

លោក Mikami Masahiro មានប្រសាសន៍ថា៖ «ការបំពុលប្លាស្ទិកនៅតាមសមុទ្របានក្លាយជាវិបត្តិបរិស្ថានដ៏ធំបំផុតមួយនៅក្នុងពិភពលោក»។

លោកថា ក្នុងកិច្ចប្រជុំកំពូលប្រទេស G២០ដែលធ្វើឡើងនៅទីក្រុងអូសាកា កាលពីឆ្នាំ២០១៩ រដ្ឋាភិបាលជប៉ុនបានប្រកាសអនុវត្តគំនិតផ្តួចផ្តើមថ្មីមួយ ដើម្បីជំរុញឱ្យមានការចាត់វិធានការប្រកបដោយប្រសិទ្ធភាព ប្រឆាំងទៅនឹងការបំពុលប្លាស្ទិកនៅតាមសមុទ្រ។

ការកើនឡើងនូវសំណល់ប្លាស្ទិកបានក្លាយជាបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមធំៗជាងគេក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ។ សម្ភារៈប្រើប្រាស់ដែលធ្វើពីប្លាស្ទិកដូចជាថង់ដប និងប្រដាប់ដាក់វត្ថុនានា បច្ចុប្បន្ននេះមានវត្តមាននៅគ្រប់ទិសទី ក្នុងផ្ទះ ក្នុងសាលារៀន និងក្នុងកន្លែងធ្វើការ ប៉ុន្តែការប្រើប្រាស់ឥតសំចៃបែបនេះ បានបង្កនូវផលប៉ះពាល់ដ៏ធ្ងន់ធ្ងរ។

យោងតាមក្រសួងបរិស្ថានបាន ឱ្យដឹងថា បរិមាណប្លាស្ទិកសរុបក្នុងសកលលោកទាំងមូលបានកើនឡើងដល់ ៨,៣ ពាន់លានតោន។ ជារៀងរាល់ឆ្នាំ មានប្លាស្ទិក ១៣ លានតោន ហូរចូលទៅក្នុងសមុទ្រ ដែលស្មើនឹងការចាក់សំរាមមួយឡានដឹកសំរាមពេញ រៀងរាល់មួយនាទីម្តង។ សំណល់ប្លាស្ទិកប្រមាណ ៩០% ដែលហូរចូលទៅក្នុងសមុទ្រមានប្រភពពីទន្លេធំៗចំនួន ១០ ដែលក្នុងនោះមានទន្លេមេគង្គមួយផងដែរ។

បច្ចុប្បន្ននេះ មានប្រទេស និងទីក្រុងជាង ១០០ ក្នុងនោះមានកម្ពុជាផងដែរ កំពុងដាក់ឱ្យអនុវត្តវិធានការថ្មីៗជុំវិញសំណល់ប្លាស្ទិក។ នៅកម្ពុជា ចាប់តាំងពីឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានជំរុញឱ្យមានការអនុវត្តក្របខ័ណ្ឌ 4Rs ដើម្បីផ្តល់នូវដំណោះស្រាយចំពោះបញ្ហាប្លាស្ទិកនៅក្នុងប្រទេស ដូចជា ការចេញនូវអនុក្រឹត្យ ដើម្បីគិតថ្លៃសេវាបន្ថែមលើការប្រើប្រាស់ថង់ប្លាស្ទិកជាដើម។

តំបន់គោលដៅ រួមមានក្រុងធំៗ និងខេត្តដែលនៅតាមតំបន់ឆ្នេរ ដូចជា៖ សៀមរាប ព្រះសីហនុ ភ្នំពេញ កែប កំពត និងកោះកុង ដើម្បីកាត់បន្ថយការបំពុលប្លាស្ទិកនៅតាមសមុទ្រឱ្យមានប្រសិទ្ធភាពនៅតាមតំបន់ប្រភពសំណល់តែម្តង។

បើរដ្ឋមន្ត្រីក្រសួងបរិស្ថាន លោក សាយ សំអាល់ បានថ្លែងឱ្យដឹងថា៖ «ការកាត់បន្ថយសំណល់ប្លាស្ទិកឱ្យមានប្រសិទ្ធភាពទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមពីគ្រប់គ្នា»។

លោក សាយ សំអាល់ បន្ថែមថា តាមរយៈគម្រោងនេះ អាចបង្ហាញឱ្យឃើញពីឧត្តមានុវត្តន៍នៃអន្តរាគមន៍កាត់បន្ថយប្លាស្ទិកដែលអាចជួយឱ្យបណ្តាប្រទេសនានានៅអាស៊ានយកគំរូតាមកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងទៅនឹងការបំពុលប្លាស្ទិកនៅតាមសមុទ្រ។

ចំណែកលោក Nick Beresford អ្នកតំណាងនិវាសនដ្ឋាននៃ UNDP ប្រចាំកម្ពុជា ក៏បានលើកឡើងផងដែរថា៖ «ការប្រយុទ្ធប្រឆាំងនឹងការបំពុលប្លាស្ទិកគឺជាការកិច្ចការដ៏សែនពិបាកមួយ ប៉ុន្តែគម្រោងនេះនឹងនាំមកនូវការផ្លាស់ប្តូរ និងបង្ហាញឱ្យឃើញពីអនុភាពនៃការងាកទៅរកសេដ្ឋកិច្ចវិលជុំបែបបៃតង»៕

# ដើមឈើថ្មីជិតផុតពូជពីរប្រភេទ នៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ត្រូវបានរកឃើញ

*អត្ថបទ៖ ផល សុផានិត*

ដែនជម្រកសត្វព្រៃកែវសីមា ត្រូវបានគេស្គាល់ថាជាទីជម្រកសម្រាប់រុក្ខជាតិតូចៗនិងដើមឈើសរុបជាង ២៦០ប្រភេទ ក្នុងនោះមាន ២០ប្រភេទកំពុងឈានទៅរកការផុតពូជជាសកល និង ៥៣ប្រភេទទៀត ត្រូវបានរដ្ឋបាលព្រៃឈើចាត់ចំណាត់ថ្នាក់ជាប្រភេទឈើប្រណិត ឬប្រភេទឈើលេខ១ លេខ២ ឬលេខ៣។ នេះបើតាមការចុះផ្សាយរបស់ អង្គការ WCS នៅរសៀលនេះ។



*រុក្ខជាតិ ម៉ាឈីលូស សីមេនស៊ីស (Machilus seimensis)។* ***រូបភាព៖ អង្គការសមាគមន៍អភិរក្សសត្វព្រៃកម្ពុជា***

ក្រុមអ្នកស្រាវជ្រាវមកពីប្រទេសជប៉ុន សហការជាមួយមន្ត្រីរដ្ឋបាលព្រៃឈើកម្ពុជា បានរកឃើញនិងបានដាក់ឈ្មោះប្រភេទដើមឈើថ្មីទាំងពីរប្រភេទដែលរកឃើញនៅ ក្នុងតំបន់ការពារធម្មជាតិនេះ ដោយមួយប្រភេទបានដាក់ឈ្មោះវិទ្យាសាស្រ្តថា «ម៉ាឈីលូស កាំបូឌីយ៉ាណា (Machilus cambodiana) » ដោយឈ្មោះខាងចុងយកតាមឈ្មោះប្រទេសកម្ពុជា និងមួយប្រភេទទៀតបានដាក់ឈ្មោះវិទ្យាសាស្រ្តថា «ម៉ាឈីលូស សីមេនស៊ីស (Machilus seimensis)» ដោយឈ្មោះខាងចុងយកតាមឈ្មោះដែនជម្រកសត្វព្រៃកែវសីមា។

ប្រភពបន្ថែមថា ទោះបីជាអង្គការ IUCN មិនទាន់បានដាក់បញ្ចូលរុក្ខជាតិថ្មីទាំងពីរប្រភេទនេះចូលទៅក្នុងបញ្ជីក្រហមរបស់ខ្លួនក្តី ក៏ក្រុមអ្នកស្រាវជ្រាវជឿថាដើមឈើរកឃើញថ្មីទាំងពីរប្រភេទនេះកំពុងរងការគំរាមកំហែងជិតផុតពូជ ដោយសារប្រភេទរុក្ខជាតិទាំងពីរប្រភេទនេះមានចំនួនតិចតួចនៅក្នុងព្រៃស្រោង ហើយក្រុមអ្នកស្រាវជ្រាវបានរកឃើញដើមឈើប្រភេទនេះតែពីរបីដើមប៉ុណ្ណោះក្នុងអំឡុងពេលធ្វើការសិក្សាស្រាវជ្រាវរបស់ខ្លួន។

ក្រុមអ្នកស្រាវជ្រាវក៏បានពិពណ៌នាផងដែរ អំពីប្រភេទរុក្ខជាតិថ្មីៗនៅឧទ្យានជាតិបូកគោ ខេត្តកំពត និងដែនជម្រកសត្វព្រៃភ្នំដងរែកភាគកណ្តាល។ សំណាកនៃប្រភេទ រុក្ខជាតិថ្មីៗទាំងអស់បានរក្សាទុកនៅឯបន្ទប់រក្សាសំណាកជីវៈចម្រុះរបស់រដ្ឋបាលព្រៃឈើ៕

# កូរ៉េនៅតែទទួលពលករខ្មែរ ទោះស្ថិតក្នុងការលំបាកដោយកូវីដក៏ដោយ

*អត្ថបទ៖ ផល សុផានិត*

ទោះបីស្ថិតក្នុងដំណាក់កាលពិបាកដោយសារជំងឺកូវីដ១៩ក៏ដោយ ក៏សាធារណរដ្ឋកូរ៉េនៅតែព្រមទទួលយកពលករកម្ពុជាឱ្យធ្វើការនៅប្រទេសខ្លួន។ នេះបើតាមការថ្លែងឱ្យដឹងរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង។

លោកបានថ្លែង ថា ដោយសារនិយោជកពេញចិត្តនឹងសមត្ថភាព ភាពស្មោះត្រង់របស់ពលករកម្ពុជា ខណៈពេលបច្ចុប្បន្នពលករកម្ពុជាប្រមាណជិត ៥០,០០០ នាក់កំពុងបម្រើការងារលើវិស័យនានានៅប្រទេសកូរ៉េខាងត្បូង។

ការលើកឡើងនេះធ្វើឡើងក្នុងជំនួបពិភាក្សាការងាររវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយលោក Park Heung Kyeong ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា នាព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ នៅទីស្តីការក្រសួងការងារ។

លោកអ៊ិត សំហេង បានលើកឡើងថា កម្ពុជានិងកូរ៉េកំពុងចចារកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដើម្បីឈានទៅចុះហត្ថលេខាដាក់ឱ្យដំណើរការជាធរមាន នាពេលឆាប់ៗនេះ។ កិច្ចព្រមព្រៀងនេះនឹងជំរុញឱ្យទំហំពាណិជ្ជកម្ម និងការវិនិយោគកាន់តែមានការកើនឡើង ហើយវិនិយោគិនកូរ៉េ ក៏នឹងមកកម្ពុជាបន្ថែម ដើម្បីស្វែងរកឱកាសវិនិយោគក្នុងវិស័យជាច្រើនទៀត។

ពាក់ព័ន្ធនឹងការបញ្ជូន-ទទួលពលករកម្ពុជាធ្វើការនៅប្រទេសកូរ៉េ លោករដ្ឋមន្ត្រីបានលើកឡើងថា បន្ទាប់ពីស្ថានភាពកូវីដ-១៩ នៅប្រទេសកូរ៉េមានភាពធូរស្រាល ដែលអាចទទួលយកកម្លាំងពលកម្មបរទេសបាន កម្ពុជារំពឹងថានឹងក្លាយជាប្រទេសអាទិភាពមួយក្នុងចំណោមប្រទេសចំនួន ១៥ ផ្សេងទៀត ដោយសារកម្ពុជាមានស្ថានភាពកូវីដល្អប្រសើរ មានជើងហោះហើរច្រើន។

ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ លោក Park Heung Kyeong បានលើកឡើងនាឱកាសនោះផងដែរថា នៅក្នុងឆ្នាំ២០១៩ ពលករកម្ពុជាមានចំនួនច្រើនជាងគេក្នុងចំណោមពលករដែលធ្វើការនៅប្រទេសកូរ៉េ ហើយក្នុងដំណាក់កាលជំងឺកូវីដ-១៩ ឆ្នាំ២០២០នេះ រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េនៅតែអនុញ្ញាតទទួលពលករកម្ពុជាដដែល។

លោកថា៖ «មូលហេតុដែលកូរ៉េអនុញ្ញាតទទួលពលករកម្ពុជាយ៉ាងដូច្នេះ គឺដោយសារនិយោជកមានការពេញចិត្តនឹងសមត្ថភាពខ្ពស់របស់ពលករកម្ពុជា មានភាពស្មោះត្រង់នឹងការងារ និងអនុវត្តតាមការណែនាំរបស់ផ្នែកសុខាភិបាលរបស់រដ្ឋាភិបាលកូរ៉េបានយ៉ាងហ្មត់ចត់»។

សូមជម្រាបថា ចាប់ពីឆ្នាំ២០០៧មក កម្ពុជាបានបញ្ជូនពលករសរុប ៦៨,២៩៤ នាក់ (ស្រី ១៤,២៥៥ នាក់) ឱ្យទៅធ្វើការនៅប្រទេសកូរ៉េ ដែលរួមមានវិស័យឧស្សាហកម្ម កសិកម្ម និងសំណង់ ដែលអាណត្តិការងារមានរយៈពេល ៤ឆ្នាំ ១០ ខែ៕

# ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ជ្រើសយក សន្តអន់ដ្រេ ជាឧបការី






សកម្មភាពក្នុងពិធីបុណ្យគោរពសន្តអន់ដ្រេជាគ្រីស្តទូតរបស់ព្រះហគមន៍កាតូលិកភូមិភាគកំពង់ចាម។ **លី សុវណ្ណា**

*អត្ថបទ៖ កែវ កញ្ញា*

នៅថ្ងៃបុណ្យគោរពសន្តអន់ដ្រេជាគ្រីស្តទូត លោកអភិបាលប្រ៊ុយណូ កូសម៍ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម បានប្រកាសយកសន្តរូបនេះ ជាសន្តឧបការីសម្រាប់ព្រះសហគមន៍នៃភូមិភាគកំពង់ចាម កាលថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០កន្លងទៅ នៅព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង។

ដោយសារអំឡុងពេលនៃការរីករាលដាលនៃកូវីដ១៩ មានបូជាចារ្យ បងស្រី និងគ្រីស្តបរិស័ទមួយចំនួនមិនត្រូវបានអនុញ្ញាតឱ្យចូលរួម ច្រើននោះឡើយ។ អ្នកចូលរួមត្រូវអង្គុយដោយរក្សាគម្លាត ពាក់ម៉ាស់ វាស់កំដៅ និងលាងដៃជាមួយអាល់កុលជានិច្ច។

លោកអភិបាលប្រ៊ុយណូ មានប្រសាសន៍ថា៖ «ព្រះសហគមន៍កំពង់ចាមបាន ជ្រើសរើសសន្តអន់ដ្រេជាគ្រីស្តទូត ជាឧបការីនៃភូមិភាគកំពង់ចាម»។

លោកអភិបាលពន្យល់ថា តាមទំនៀមទំលាប់ព្រះសហគមន៍កាតូលិកនៅពេលយើងទទួលពិធីជ្រមុជទឹក យើងទទួលឈ្មោះថ្មីជាឈ្មោះរបស់សន្តបុគ្គលណាម្នាក់ គឺដើម្បីឱ្យសន្តរូបនោះជួយយើងឱ្យយល់អំពីបេសកកម្មរបស់យើង ហើយព្រះវិហារក៏ដូច្នេះដែរ មានឈ្មោះសន្តបុគ្គលនានា។

លោកអភិបាលបន្ថែមថា៖ «ថ្ងៃនេះ ... គឺយើងយក យើងទទួលសន្តអន់ដ្រេធ្វើជាគំរូដែលណែនាំយើងក្នុងភូមិភាគ មិនមែនតែនៅកន្លែងណាមួយ ឬកន្លែងនេះ កន្លែងនោះ ប៉ុន្តែសម្រាប់ភូមិភាគ»។

ក្នុងនោះដែរលោកសង្កត់ធ្ងន់ថា៖ «តាំងពីថ្ងៃនេះតទៅ សន្តអន់ដ្រេនឹងទៅជាមនុស្សម្នាក់ពិសេសក្នុងភូមិភាគកំពង់ចាម ធ្វើជាគំរូសម្រាប់ព្រះសហគមន៍ទាំងអស់(ក្នុងភូមិភាគនេះ) និងសម្រាប់គ្រីស្តបរិស័ទទាំងអស់»។

សន្តអន់ដ្រេជាសាវ័កដំបូងដែលព្រះយេស៊ូបានត្រាស់ហៅមុនគេ ឬជាសាវ័កដែលដើរតាមព្រះអង្គមុនគេបង្អស់។ ព្រះសហគមន៍រំលឹកនិងគោរពលោកជាគ្រីស្តទូត និងជាមរណសាក្សីអំពីជំនឿលើព្រះយេស៊ូ ដោយសារលោកបានស្លាប់ដោយសារជំនឿ។

រួមជាមួយគ្នានេះដែរ តាមប្រវត្តិរបស់ព្រះសហគមន៍នៅភូមិភាគកំពង់ចាម ក្នុងឆ្នាំ១៩៦៨ សន្តអាសនៈបានបែងចែកព្រះសហគមន៍នៅកម្ពុជាជាបីភូមិភាគ ដែលមានភ្នំពេញ បាត់ដំបង និងកំពង់ចាម។ លោកអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម ដំបូងគេមាន ឈ្មោះអន់ដ្រេ ឡឺស្វែប។

លោកអភិបាល ប្រ៊ុយណូ បានបន្ថែមថា ដោយនឹកដល់កិច្ចការជាគង្វាលរបស់លោកអភិបាល អន់ដ្រេ ដែលបានប្រមែប្រមូលគ្រីស្តបរិស័ទ កសាងព្រះសហគមន៍នៅកំពងចាមឡើងវិញ ក្រោយពេលសង្គ្រាមស៊ីវិលបានបញ្ចប់នៅដើមទស្សវត្សទី៩០ ទើបព្រះសហគមន៍ភូមិភាគកំពង់ចាមសម្រេចយកសន្តអន់ដ្រេជាឧបការី។

ក្នុងពិធីបុណ្យគោរពនិងជ្រើសរើសសន្តអន់ដ្រេជាឧបការីនេះ លោកអភិបាលបានប្រកាសផ្លាស់ប្តូរកិច្ចការងារបេសកកម្មរបស់ក្រុមបងស្រីស្រឡាញ់ឈើឆ្កាងព្រះយេស៊ូមួយចំនួន ដូចជា បងស្រីក្លារ៉ាពេនហ៊ីល ត្រូវទៅបម្រើការងារនៅព្រះសហគមន៍ព្រៃវែងជាមួយបងស្រីអាងសង្វាត បងស្រីតេរេសាចាន់រដ្ឋា ត្រូវបម្រើការងារនៅព្រះសហគមន៍កំពង់ចាមក្រុងជាមួយបងស្រីស្រីសុជាតិ បងស្រីសួនប៊ុនថារីនទៅបម្រើការងារនៅព្រះសហគមន៍ ស្ទឹងត្រែង និងរតនគិរីជាមួយបងស្រីញឹប សុខនី។ ការចាត់តាំងនេះនឹងចូលជាធរមាននៅថ្ងៃទី១ខែមករា ឆ្នាំ២០២១៕

# បូជាចារ្យភូមិភាគភ្នំពេញរិះគិតអំពីបញ្ហាប្រឈមរបស់ភូមិភាគ



*លោក អូលីវីយេ ជ្មីតអឺស្លែរ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ។ **រូបភាព៖ ស៊ីអេសស៊ី***

*អត្ថបទ៖ ដាលីស*

អស់លោកបូជាចារ្យទាំងអស់ដែលបម្រើព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ បានចូលរួមនៅក្នុងអង្គប្រជុំអំពីរដូវរង់ចាំនាពេលខាងមុខនេះ ដែលដឹកនាំដោយលោក អូលីវីយេ ជ្មីតអឺស្លែរ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ នាព្រឹកថ្ងៃទី ១៧ រហូតដល់ថ្ងៃទី ១៨ វិច្ឆិកា ២០២០ នៅព្រះវិហារសន្តសិលា និងសន្តប៉ូលភ្នំពេញថ្មី។

ក្នុងអង្គប្រជុំនេះដែរ លោកអភិបាលបានរំឭកអំពីស្ថានភាពកូវីដ១៩ ដែលកំពុងរាលដាលក្នុងពិភពលោកយើងនេះ ក៏ដូចជាការប្រឈមរបស់ព្រះសហគមន៍នៅកម្ពុជាផងដែរ។

ក្នុងឱកាសនេះ លោកអភិបាលបានសូមឱ្យលោកបូជាចារ្យ រិះគិតរួមគ្នា អំពីស្ថានភាពកូវីដ១៩ នៅក្នុងសង្គម និងព្រះសហគមន៍បច្ចុប្បន្ននេះ អំពីការប្រឈមរបស់យុវជន និងអំពីមូលដ្ឋានគ្រឹះរបស់ព្រះសហគមន៍ភូមិភាគភ្នំពេញ។ និយាយអំពីយុវជន លោកអភិបាលសូមឱ្យលោកបូជាចារ្យ ជួយយុវជនឱ្យអភិវឌ្ឍខ្លួន ព្រោះពួកគាត់ជាអ្នកប្រកាសដំណឹងល្អរួមជាមួយព្រះសហគមន៍។

លោកមានប្រសាសន៍ថា៖ «យើងមិនអាចមានត្រឹមតែគ្រីស្តបរិស័ទដែលយើងមានស្រាប់ហើយ ប៉ុន្តែត្រូវការបន្ថែមទៀតដើម្បីឱ្យអ្នកទាំងអស់នោះចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយឱ្យយុវជនដឹងថា ពួកគេមានតួនាទីមួយក្នុងព្រះសហគមន៍ ដើម្បីប្រកាសដំណឹងល្អ»។

លោកមានប្រសាសន៍បន្តថា នេះជាការថែរក្សារបស់យើងនៅក្នុងព្រះកាយព្រះគ្រីស្តសម្រាប់ពិភពលោកដោយសារសម្តេចប៉ាបដឹកនាំព្រះសហគមន៍ទាំងមូលនៅក្នុងធម៌មេត្តាករុណា។

ដូច្នេះសូមគិតបន្ថែមទៀតដល់មូលដ្ឋាននៃព្រះសហគមន៍របស់យើងនៅក្នុងភូមិភាគភ្នំពេញនិងគិតអំពីក្តីសុបិន្តរបស់យើងបន្ថែមទៀតផងដែរ។

ក្រោយពីការរៀនគិតនេះ អស់លោកបូជាចារ្យទាំងអស់បានចែកគ្នាជាក្រុមតូចចំនួនបួនក្រុម ដើម្បីរិះគិតអំពីការជម្នះការប្រឈមរបស់ព្រះសហគមន៍ភូមិភាគភ្នំពេញសព្វថ្ងៃ៕





# លោកអភិបាល អូលីវីយេ ស្នើឱ្យគ្រីស្តបរិស័ទត្រៀមខ្លួនជានិច្ច



*លោក អូលីវីយេ ជ្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ **ព្រះសហគមន៍***

*អត្ថបទ៖ ស៊ីអេសស៊ី*

«ជីវិតរបស់យើងត្រូវត្រៀមជានិច្ច ដូចស្ត្រីមានប្រាជ្ញា គឺត្រូវពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំយើងឱ្យមានជំនឿ មានសេចក្តីស្រឡាញ់ ដឹងខុសដឹងត្រូវ ស្គាល់សេចក្តីពិត មានចិត្តស្លូតបូត ចេះលើកលែងទោស និងគោរពកោតខ្លាចព្រះជាម្ចាស់ជានិច្ច»។

នេះជាប្រសាសន៍លើកឡើងរបស់លោក អូលីវីយេ ជ្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានថ្លែងនៅក្នុងធម្មទេសនារបស់លោកក្នុងអភិបូជានៅព្រះវិហារសន្តីម៉ារី ម៉ាដាឡានៃមណ្ឌលសកម្មភាពភ្នំពេញខាងជើង កាលពីថ្ងៃទី៨ វិច្ឆិកា ២០២០នេះ។

លោកអូលីវីយេបញ្ជាក់ទៀតថា អត្ថបទគម្ពីរណែនាំឱ្យយើងប្រុងស្មារតីនឹងស្ថានភាពបច្ចុប្បន្ន។ តាមពិតជីវិតរបស់យើងត្រូវរៀបចំជានិច្ច។ ក្នុងរដូវកាលកូវីដ១៩នេះ ណែនាំឱ្យយើងភ្ញាក់ស្មារតីផងដែរ ដែលជាហេតុនាំឱ្យយើងប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ធ្វើតាមការណែនាំរបស់ក្រសួងសុខាភិបាល។

លោកបន្តថា យើងជាគ្រីស្តបរិស័ទយើងត្រូវរៀបចំជីវិតរបស់យើងជានិច្ចត្រៀមខ្លួនជានិច្ច ដើម្បីស្វាគមន៍ព្រះយេស៊ូដែលចង់ជួបយើងនៅថ្ងៃណាមួយ។ លោកបន្ថែមថា កូវីដ១៩ នាំឱ្យសេដ្ឋកិច្ចធ្លាក់ចុះ ដែលជាពេលវេលាមួយដើម្បីឱ្យយើងភ្ញាក់ស្មារតី ធ្វើដូចម្តេចដើម្បីអាចចូលរួមយ៉ាងសកម្មនៅក្នុងជីវិតរបស់យើង នៅក្នុងនយោបាយ សេដ្ឋកិច្ច វប្បធម៌ ដើម្បីឱ្យជីវិតរបស់យើងអាចបំភ្លឺបងប្អូនឯទៀត។

ក្នុងពេលនេះដែរ លោកអភិបាល អូលីវីយេ ក៏បានលើកឡើងផងដែរអំពីបន្ទូលរបស់សម្តេចប៉ាបថា «នៅលើផែនដីនេះ យើងជាបងប្អូន ជាគ្រួសារតែមួយ ជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់តែមួយ»។ ក្នុងអត្ថន័យនេះ លោកអភិបាអូលីវីយេ បានក្រើនរំឭកដល់គ្រីស្តបរិស័ទកាតូលិកក្នុងប្រទេសកម្ពុជាទាំងអស់គួរធ្វើដើម្បីក្លាយជាគ្រួសារតែមួយគឺ៖ សុខចិត្តសាមគ្គី សន្ទនាដោយផ្ទាល់ ដើម្បីសម្រុះសម្រួលបញ្ហា និងនិយាយពីបញ្ហាជាមួយគ្នាដោយផ្ទាល់មាត់។

សព្វថ្ងៃយើងមានការភ័យខ្លាចជំងឺកូវីដ ប៉ុន្តែសូមកុំឱ្យការភ័យខ្លាចរបស់យើងទៅជាវប្បធម៌ថ្មី តែយើងត្រូវប្រុងប្រយ័ត្នដោយរក្សាអនាម័យ ដោយមិនបិទដួងចិត្តរបស់យើងឡើយ។ លោកបញ្ជាក់ថា កុំឱ្យវប្បធម៌ថ្មីធ្វើឱ្យយើងមានចិត្តចង្អៀតចង្អល់ មានភាពអាត្មានិយម ប៉ុន្តែសូមឱ្យយើងមានចិត្តសាមគ្គីដើម្បីណែនាំយើងមានជីវិតថ្មីនៅក្នុងពិភពថ្មីដែលពោរពេញដោយក្តីសង្ឃឹម៕

## សិស្សនៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសសន្តហ្វ្រង់ស្វ័រប្រឡងជាប់សញ្ញាបត្រទុតិយភូមិ១០០%

*អត្ថបទ៖ ដាលីស*

សិស្សានុសិស្សថ្នាក់អប់រំបច្ចេកទេសជំនាញក្បេត្រសាស្ត្រជំនាន់ទី៣ នៃវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជនសន្តហ្វ្រង់ស្វ័រ ទទួលបានលទ្ធផលយ៉ាងល្អប្រសើរក្នុងការប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ (សញ្ញាបត្រទុតិយភូមិបច្ចេកទេស) ១០០% នាសម័យប្រឡងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ កន្លងទៅ។

ក្នុងនាមជានាយក ក៏ដូចជាគណៈគ្រប់គ្រងនៃវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជនសន្តហ្វ្រង់ស្វ័រ លោក យ៉ុន សំអាត បានឱ្យដឹងថា លទ្ធផលប្រឡងមធ្យមសិក្សាទុតិយភូមិនេះ គឺមានសិស្ស៣នាក់បាននិទ្ទេសB ១០នាក់បាននិទ្ទេសC ៣នាក់បាន D និងម្នាក់ទទួលបាននិទ្ទេស E។

លោកប្រាប់ថា៖ «ការទទួលបានលទ្ធផលល្អបែបនេះ ពិតជាធ្វើឱ្យយើងមានមោទនភាព និងមានក្តីអំណរសប្បាយយ៉ាងខ្លាំង ដែលបានឃើញសិស្សទាំងអស់បានយកចិត្តទុកដាក់ចំពោះអនាគតរបស់ពួកគេ»។ លោកយ៉ុន សំអាត ថា ទោះបីជាមានការផ្ទុះឡើងនូវជំងឺកូវីដ រហូតដល់ក្រសួងអប់រំយុវជននិងកីឡា ធ្វើការពន្យារនិងដាក់វិស្សមកាលមុនពេលកំណត់ ប៉ុន្តែសាលា នៅតែបន្តសកម្មភាពដោយមានយុទ្ធសាស្ត្រ និងផែនការណ៍ជាច្រើន ដើម្បីអនុវត្តន៍ដោយមានសិស្សានុសិស្សចូលរួមសហការយ៉ាងសកម្មផងដេរ។

នៅក្នុងឱកាសនេះផងដែរ លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងជាស្ថាបនិកនៃវិទ្យាល័យចំណេះទូទៅ និងឯកទេសវិជ្ជាជីវៈសន្តហ្វ្រង់ស្វ័រ បានថ្លែងនៅក្នុងសារលិខិតរបស់លោក ដោយចូលរួមអបអរសាទរដល់សិស្សទាំងអស់ដែលបានតស៊ូ និងយកចិត្តទុកដាក់រៀបចំអនាគតដ៏ភ្លឺស្វាងរបស់ពួកគេ។ លោកក៏បានថ្លែងអំណរគុណដល់លោកនាយកនាយិការង និងលោកគ្រូអ្នកគ្រូបុគ្គលិកសិក្សាទាំងអស់ ដែលបានយកចិត្តទុកដាក់បង្រៀនតាមអនឡាញ(online) នៅកំឡុងពេលជួបវិបត្តិកូវីដ១៩ ក៏ដូចជាការខិតខំយកចិត្តទុកដាក់បង្រៀនបំប៉នបន្ថែមដល់សិស្ស រហូតទទួលបានជោគជ័យជាស្ថាពរ៕

## បេក្ខជន៣១រូប ទទួលអគ្គសញ្ញាលាបថ្ងាសនៅព្រះសហគមន៍មណ្ឌលសកម្មភាពទន្លេចាសាក់

*អត្ថបទ៖ ដាលីស*

បេក្ខជន៣១នាក់ មកពីព្រះសហគមន៍ជ្រៃធំកោះទាវ និងសំប៉ាន ទទួលអគ្គសញ្ញាលាបថ្ងាសដើម្បីធ្វើជាគ្រីស្តបរិស័ទពេញលក្ខណៈ។

ពិធីនេះប្រព្រឹត្តនៅព្រះវិហារសន្តយ៉ូសែបជ្រៃធំ ក្នុងឱកាសបុណ្យព្រះយេស៊ូជាព្រះមហាក្សត្រ នាថ្ងៃទី២២ខែវិច្ឆិកា ក្រោមអធិបតីភាពលោក អូលីវីយេ ជ្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដោយមានគ្រូអប់រំជំនឿ និងគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ។ មុននឹងប្រទានអគ្គសញ្ញាលាបថ្ងាស លោកអភិបាលអូលីវីយេ បានណែនាំដល់បេក្ខជន អស់លោកអ្នកដែលមានបន្ទុកដឹកនាំព្រះសហគមន៍ទាំងអស់ឱ្យយកចិត្តទុកដាក់ចំពោះទីតាំងនៃបេះដូងរបស់យើងនៅក្នុងសង្គម ដោយពឹងផ្អែកលើកិច្ចការធម៌មេត្តាករុណាទាំង៧ទាំងរូបកាយ និងវិញ្ញាណ។

លោកបន្ថែមថា នៅពេលយើងស្លាប់ យើងសង្ឃឹមថានឹងបានទៅស្ថានបរមសុខចូបព្រះយេស៊ូដែលសួរយើងថា «ប្អូនអើយ! មានបានយកចិត្តទុកដាក់ស្រឡាញ់មនុស្សនៅលើផែនដីនេះទេ?»។ លោកអភិបាលបានបន្តទៀតថា អាយុមិនសំខាន់ទេ សំខាន់ត្រូវយកចិត្តទុកដាក់ស្រឡាញ់មនុស្សនៅលើផែនដីនេះ ដូចព្រះយេស៊ូទន្ទឹងរង់ចាំសេចក្តីស្រឡាញ់ចេញពីចិត្តរបស់យើង។ ជាពិសេសជាងនេះទៅទៀតលោកអភិបាលបញ្ជាក់ទៀតថា យើងត្រូវយកចិត្តទុកដាក់ស្រឡាញ់ព្រះជាម្ចាស់ និងបងប្អូនឯទៀតៗ តាមព្រះយេស៊ូបង្រៀនយើង។

លោកថា លើសពីនេះទៅទៀត ត្រូវយកចិត្តទុកដាក់លើកិច្ចការទាំង៧ខាងផ្លូវវិញ្ញាណ៖ ១) ផ្តល់យោបល់ដល់អ្នកកំពុងសង្ស័យ។ ២) បង្រៀនអប់រំដល់អ្នកខ្វះចំណេះដឹង។ ៣) លើកទឹកចិត្តបង្ហាញផ្លូវដល់អ្នកដែលកំពុងធ្វើបាប។ ៤) ធ្វើដំណើរលើកទឹកចិត្តអ្នកដែលអស់សង្ឃឹម។ ៥) លើកលែងទោសដល់អ្នកធ្វើបាបយើង។ ៦) តស៊ូជាមួយអ្នកដែលរំខានយើង។ ៧) អធិដ្ឋានសម្រាប់មនុស្សទាំងរស់ ទាំងស្លាប់។

នៅក្នុងពិធីនេះដែរ លោកអភិបាលបានសួរបញ្ជាក់ជំនឿទាំងបេក្ខជន ទាំងបងធម៌ និងទាំងគ្រូអប់រំជំនឿរួមជាមួយគ្រីស្តបរិស័ទទាំងអស់ ដោយសុខចិត្តជៀសវាងប្រព្រឹត្តអំពើអ្វីៗដែលនាំឱ្យប្រព្រឹត្តអំពើបាប៕

## ក្រុមអនាថាជូនសម្ភារដល់អ្នករើសសំរាម






សកម្មភាពចែកសម្ភារដល់អ្នករើសសំរាម។ **រូបភាព៖ ស្រីរ័ត្ន**

*អត្ថបទ៖ ស្រីរ័ត្ន ស៊ីអេសស៊ីបាត់ដំបង*

កាលពីពេលថ្មីៗនេះ ក្រុមគ្រីស្តបរិស័ទកាតូលិកមួយ ឈ្មោះអនាថា ដែលជាគម្រោងមួយរបស់អង្គការករុណាបាត់ដំបង បានចុះចែកសម្ភារ និងគ្រឿងឧបភោគបរិភោគមួយចំនួនដល់អ្នករើសសំរាមនៅទីលានចាក់សំរាមក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង។

សម្ភារទាំងនោះត្រូវបានប្រគល់ជូនគ្រួសារចំនួន ៤០គ្រួសារ ដែលកំពុងរស់នៅជាមួយគំនរសំរាម ដើម្បីប្រកបរបរចិញ្ចឹមជីវិត។

ក្នុងមួយគ្រួសារ ទទួលបានគ្រឿងឧបភោគបរិភោគរួមមាន អង្ករ១០គីឡូ ត្រីខ៣កំប៉ុង ទឹកត្រី១ដប ខ្លាញ់១ដប សៀង១ដបតូច ស្ករស១គីឡូ អំបិល១ថង់ មី៥កញ្ចប់ និង ស្រោមដៃ១គូ។

ក្រុមអនាថានៃអង្គការករុណាបាត់ដំបងតែងតែចុះទៅសួរសុខទុក្ខ និងអប់រំប្រជាជននៅទីនោះ ជារៀងរាល់មួយខែម្តង។

ចំពោះអំណោយដែលបានចែកជូននៅថ្ងៃទី០៣ ខែធ្នូ នេះ គឺបានមកពីសប្បុរសជនខ្មែររស់នៅប្រទេសបារាំង៕

# ព្រះសហគមន៍ពាក់ស្នែង ជាវត្តមានរបស់ព្រះយេស៊ូក្នុងទីដាច់ស្រយាល

*អត្ថបទ៖ ស៊ីអេសស៊ី*

ព្រះសហគមន៍កាតូលិកព្រះវិហារ សន្តអ៊ីញ៉ាស៊ីយ៉ូ ស្ថិតក្នុងភូមិពាក់ស្នែងថ្មី ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប។ ព្រះសហគមន៍នេះមានចំងាយ ប្រមាណ ៣០គីឡូម៉ែត្រភាគខាងជើងនៃក្រុងសៀមរាប។

តាមលោក ធឹម ធន់ តំណាងគណៈកម្មការ ព្រះសហគមន៍ពាក់ស្នែង នៃព្រះវិហារ សន្ត អ៊ីញ៉ាស៊ីយ៉ូ បានឱ្យដឹងថា ព្រះវិហារក្នុងភូមិពាក់ស្នែងថ្មី និងចាស់មាន គ្រីស្តបរិស័ទ ចំនួន៨គ្រួសារ ដែលមានសមាជិកប្រមាណ៣០នាក់ អ្នកស្វែងរកយល់អំពីព្រះយេស៊ូ កុមារប្រមាណ៤០នាក់ ជំហានទី១ ចំនួន៤០នាក់ និងមនុស្សពេញវ័យ៨នាក់។




*តំណាងគណៈកម្មការ ព្រះសហគមន៍ពាក់ស្នែង នៃព្រះវិហារ សន្ត អ៊ីញ៉ាស៊ីយ៉ូ សំណេះសំណាល និងចែកអំណោយដល់ប្រជាជនក្នុងសហគមន៍។ **រូបភាព៖ ព្រះសហគមន៍ពាក់ស្នែង***

តាមលោកធឹម ធន់ បានឱ្យដឹងទៀតថា ព្រះសហគមន៍កាតូលិកមានសកម្មភាពជាក់ស្តែងក្នុងតំបន់នេះក្នុងឆ្នាំ២០០៧ ដែលផ្តោតលើវិស័យអប់រំ មានសាលាមត្តេយ្យកំរិតទាបនិងកំរិតខ្ពស់ ថ្នាក់ភាសាអង់គ្លេស មានកម្មវិធីអប់រំសម្រាប់ស្រ្តីជាមាតា អំពីអនាម័យ អំពីរបៀបថែរក្សាកូន អំពីក្រុមគ្រួសារ។ ក្នុងនោះក៏មានកម្មវិធីអាហារបំប៉នផងដែរ។

ព្រះសហគមន៍បានខិតខំជួយដល់យុវជន និងកុមារឱ្យគេមានឱកាសទទួលបានការអប់រំ អភិវឌ្ឍចំណេះដឹង ផ្នត់គំនិត ដើម្បីឱ្យគេក្នុងពេលអនាគតអាចជួយសង្គម និងក្រុមគ្រួសាររបស់គេបាន។ លោកធឹម ធន់ បន្តថា យុវសិស្សភាគច្រើនណាស់បានឈប់រៀនមុនបញ្ចប់ថ្នាក់ទី១២ ព្រោះសាលាឆ្ងាយ ហើយពួកគេភាគច្រើនទៅរកការងារធ្វើនៅក្រុងសៀមរាប ឬទៅប្រទេសថៃ ឬធ្វើចម្ការជាដើម។

អ្វីសំខាន់អរគុណព្រះជាម្ចាស់ដែលបានប្រទានឱ្យយើងមានកន្លែងដើម្បីជួយដល់កុមារាកុមារី និងក្រុមគ្រួសារនៅក្នុងភូមិនេះ។





*អ្នកគ្រូធីតា (ខាងលើ) គ្រូអប់រំជំនឿ និងលោក ធឹម ធន់ តំណាងគណៈកម្មការ ព្រះសហគមន៍ពាក់ស្នែង នៃព្រះវិហារ សន្ត អ៊ីញ៉ាស៊ីយ៉ូ។ **រូបភាព៖ ព្រះសហគមន៍ពាក់ស្នែង***

លោកធឹម ធន់ បានរំលឹកអំពីដើមចម ដែលព្រះសហគមន៍ មានសកម្មភាព ក្នុងតំបន់នេះថា ក្នុង១៩៩៧ ឬ១៩៩៨ លោកផ្ទាល់ជាបុគ្គលិកអង្គការការីតាស ផ្នែកសុខភាព និងអភិវឌ្ឍសហគមន៍។ ក្នុង២០០០ លោកចប់ជាមួយការីតាស នៅតែបន្តមកសួរសុខទុក្ខ អប់រំកុមារអំពីអនាម័យ។ ក្រោយមកមានគេចាប់អារម្មណ៍អំពីសកម្មភាពនេះ លោកក៏ខ្ចីដីអ្នកភូមិ ដើម្បីធ្វើកន្លែងតូចមួយសម្រាប់ជួបជុំគ្នា និងអប់រំកុមារ។ ក្រោយមក មានកម្មវិធីបង្រៀនបំប៉នកុមារថ្នាក់ទី១ ទី២ លើមុខវិទ្យា គណិតវិទ្យា និងភាសាខ្មែរ។ ហើយក៏បន្តមកដល់សព្វថ្ងៃ។ ក្នុងក្តីស្រមៃដើម្បីកសាងព្រះសហគមន៍ដោយគិតអំពីចម្ការ ព្រះសហគមន៍ក៏បានទិញដីចម្ការ ចំនួន១៦ហិតា ដាក់ឈ្មោះថាចំការព្រះយេស៊ូនៅភូមិពាក់ស្នែងថ្មី។

ពេលនេះជាព្រះវិហារសន្តអ៊ីញ៉ាស៊ីយ៉ូ មានគ្រីស្តបរិស័ទចំនួន៨គ្រួសារ ស្មើនឹង៣០នាក់ ទាំងពាក់ស្នែងចាស់ និងថ្មី។ នៅពាក់ស្នែងថ្មីមានមនុស្សពេញវ័យចំនួន៧នាក់កំពុងទទួលអប់រំជនឿ។ ព្រះវិហានេះមានអភិបូជារៀងរាល់ថ្ងៃអាទិត្យ វេលាម៉ោង១០ព្រឹក។

យុវនារី ចន្ថា ដែលស្ម័គ្រចិត្តមកបង្រៀនភាសាអង់គ្លេសដល់កុមារក្នុងភូមិពាក់ស្នែងចាស់ បានឱ្យដឹងថា នាងមកបង្រៀនភាសាអង់គ្លេសដល់កុមារក្នុងរយៈខ្លី ពេលវិស្សមកាលប៉ុណ្ណោះ។ ចន្ថាបន្តថា៖ «មូលហេតុដែលស្ម័គ្រចិត្តមកបង្រៀន ដោយសារកុមារក្នុងភូមិនេះគេចាប់អារម្មណ៍យកចិត្តទុកដាក់ចង់ចេះ និងគួឱ្យស្រលាញ់។ ម្យ៉ាងទៀតកុមារនៅទីនេះ ពុំសូវមានឱកាសបានរៀនភាសាអង់គ្លេសទេ»។

នាងបន្តថា ការបង្រៀនមានការលំបាកដែរ ពេលគេមិនចេះសរសេរ។ ចំណុចណនេះកាន់តែមានទឹកចិត្តវិញទេព្រោះកាន់តែអាណិតពួកគេទ្វេរដង។

មិនសូវខុសគ្នាប៉ុន្មានយុវនារី សុខ ខៃ ដែលជាមិត្តភក្តិរបស់ចន្ថា ជាអ្នកស្ម័គ្រចិត្តទៅបង្រៀននៅពាក់ស្នែងដែរ បានរៀបរាប់ថា នាងរីករាយ ក្នុងការបង្រៀនកុមារនៅក្នុងភូមិនេះ។

អ្នកគ្រូធីតា គ្រូអប់រំជំនឿ នៅព្រះវិហារសន្តអ៊ីញ៉ាស៊ីយ៉ូ ដែលបានធ្វើសកម្មភាពជាមួយព្រះសហគមន៍នេះចំនួន៩ឆ្នាំហើយ។ អ្នកគ្រូមានដើមកំណើតនៅខេត្តកំពង់ចាម និងបានទទួលអគ្គសញ្ញាជ្រមុជទឹកក្លាយជាគ្រីស្តបរិស័ទក្នុងឆ្នាំ២០០។ អ្នកគ្រូឱ្យដឹងថា អ្នកគ្រូស្ម័គ្រចិត្តមកស្នាក់នៅ និងបង្រៀនអប់រំជំនឿដល់បងប្អូនក្នុងតំបន់ដាច់ស្រយាល ព្រោះអ្នកគ្រូជឿថា ព្រះយេស៊ូបានចាត់សាវ័កឱ្យទៅដើម្បីប្រកាសដំណឹងល្អ ដល់ទីដាច់ស្រយាលនៃផែនដី។

អ្នកគ្រូស្ម័គ្រចិត្តមក ដូចព្រះបន្ទូលព្រះយេស៊ូ ដើម្បីឱ្យបងប្អូនបានទទួលការសង្គ្រោះ។ ធីតាបានប្រាប់ដូច្នេះថា៖ «អ្វីៗទាំងអស់ ព្រះជាម្ចាស់ជាអ្នករៀបចំសម្រាប់ជីវិតរបស់ខ្ញុំ។ ព្រះអង្គជ្រាបពីជម្រៅចិត្តរបស់ខ្ញុំ ព្រះអង្គចាត់ខ្ញុំមក ស្របតាមលក្ខណៈជីវិតរបស់ខ្ញុំដែរ»។

អ្នកគ្រូបន្ថែមថា ៖ «ខ្ញុំសប្បាយចិត្តមែន នេះជាបេសកកម្មព្រះយេស៊ូឱ្យខ្ញុំធ្វើមែន។ មកតំបន់ដាច់ស្រយាល ព្រះអង្គការពារខ្ញុំពិត»។ គ្រូអប់រំជំនឿរូបនេះបន្តថា បងប្អូននៅតំបន់នេះ គេមានជំនឿដើមមាំណាស់ដែលជាជំនឿចាស់ពីដូនតាមក។ គេចាប់អារម្មណ៍អំពីយើង ដោយសារសកម្មភាពមេត្តាករុណារបស់ព្រះសហគមន៍។ បន្តិចម្តងៗ បងប្អូនប្រជាជនក្នុងភូមិបានបើកចិត្តទទួលយើង និងមិនរើសអើងយើងឡើយ។

ព្រះសហគមន៍ពាក់ស្នែង មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន រួមជាមួយប្រជាជនក្នុងមូលដ្ឋាននោះផងដែរ ព្រមទាំងមានសកម្មភាពជាច្រើនទៀតក្នុងការបម្រើ និងជួយដល់បងប្អូនក្រីក្រ និងយុវជនយុវនារីឱ្យមានការអប់រំល្អ សម្រាប់ធនធានរបស់សង្គមកម្ពុជាដែលមានគុណភាពពិតៗ ព្រមទាំងបាននាំដំណឹងល្អដល់ប្រជាជនដល់ទីដាច់ស្រយាល។ ព្រះវិហារនេះមានលោកឪពុកតូតែត ជាបូជាចារ្យទទួលខុសត្រូវ៕



*ព្រះសហគមន៍ពាក់ស្នែង ចែករំលែកក្តីសង្ឃឹមនិងក្តីស្រលាញ់។ **រូបភាព៖ ព្រះសហគមន៍ពាក់ស្នែង***





# អបអរសាទរ ព្រះគ្រីស្តយាងមក

គ្រីស្តបរិស័ទនាំគ្នាប្រារព្ធ **“រដូវអបអរសាទរព្រះគ្រីស្តយាងមក”**
ដើម្បីប្រកាសជំនឿរបស់ខ្លួនចំពោះព្រះជាម្ចាស់យាងមករួមសាមគ្គីជាមួយមនុស្សលោក គឺព្រះអង្គប្រទានឱ្យជីវិតមនុស្សមានតម្លៃ។
ព្រះគ្រីស្តបានយាងមកជាស្ពាន គឺនាំឱ្យគេមានទំនាក់ទំនងជាមួយព្រះបិតា។ សម័យឥឡូវនេះជាសម័យព្រះសហគមន៍ គឺសម័យរបស់យើងជាគ្រីស្តបរិស័ទ។ យើងមានភារៈកិច្ចដ៏សំខាន់ គឺនាំការសង្គ្រោះរបស់ព្រះគ្រីស្តដល់មនុស្សគ្រប់ជាតិសាសន៍ ជាពិសេសយកចិត្តទុកដាក់រួមគ្នាបំបាត់មូលហេតុទាំងឡាយ ដែលបណ្តាលឱ្យមនុស្សកើតទុក្ខ មានចិត្តលោភលន់ ស្អប់គ្នា សង្គ្រាម ហិង្សា និងអយុត្តិធម៌ជាដើម។ យើងជាគ្រីស្តបរិស័ទសម្តែងសេចក្តីសង្ឃឹមរបស់ខ្លួន និងទទួលស្គាល់វត្តមានរបស់ព្រះគ្រីស្តដែលយាងមកសព្វថ្ងៃដែរ។

ក្នុងរដូវអបអរសាទរព្រះគ្រីស្តយាងមកនេះ គឺក្នុងរយៈពេល៤អាទិត្យមុនបុណ្យព្រះយេស៊ូប្រសូត គ្រីស្តបរិស័ទបង្ហាញជំនឿរបស់ខ្លួនចំពោះព្រះគ្រីស្ត ដែលបានសង្គ្រោះមនុស្សលោក រួចហើយលាតសន្ធឹងការសង្គ្រោះរបស់ព្រះអង្គ រហូតដល់ពេលព្រះអង្គយាងមកនៅគ្រាចុងក្រោយបំផុត។

## អាទិត្យទី ១

### “ចូរប្រុងស្មារតី”

### ពាក្យអធិដ្ឋាន

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ។ តាំងពីដើមព្រះអង្គសព្វព្រះហឫទ័យសង្គ្រោះមនុស្សលោក។ សូមព្រះអង្គមេត្តាដាស់តឿនចិត្តគំនិតយើងខ្ញុំ ឱ្យយកចិត្តទុកដាក់ទទួលព្រះបុត្រាព្រះអង្គ ដែលកំពុងយាងមក។ សូមព្រះអង្គប្រោសឱ្យយើងខ្ញុំព្យាយាមអធិដ្ឋាន ព្រមទាំងប្រុងស្មារតីទទួលព្រះគ្រីស្ត នៅថ្ងៃដែលព្រះអង្គគោះទ្វារនៃដួងចិត្តយើងខ្ញុំផង។

ព្រះគម្ពីរដំណឹងល្អតាមសន្តម៉ាកុស ១៣,៣៣-៣៧

អ្នករាល់គ្នាមិនដឹងថា ពេលណាជាពេលកំណត់ទេ ដូច្នេះចូរប្រុងប្រយ័ត្ន ប្រុងស្មារតីឱ្យមែនទែន ដ្បិតពេលកំណត់នោះប្រៀបបាននឹងបុរសម្នាក់ ដែលចេញដំណើរពីផ្ទះទៅ គាត់ទុកឱ្យពួកអ្នកបម្រើមើលខុសត្រូវក្នុងផ្ទះ ដោយចែកមុខងារឱ្យរៀងៗខ្លួន ព្រមទាំងបង្គាប់ឱ្យអ្នកយាមផ្ទះប្រុងស្មារតីផង។ អ្នករាល់គ្នាក៏ត្រូវប្រុងស្មារតីដូច្នោះដែរ ដ្បិតអ្នករាល់គ្នាពុំដឹងថា ម្ចាស់ផ្ទះនឹងវិលមកវិញនៅពេលណាឡើយ មិនដឹងជាយប់ពាក់កណ្តាលអធ្រាត្រ ពេលមាន់រងាវ ឬពេលព្រលឹមទេ ក្រែងលោកត្រឡប់មកវិញ ដោយមិនបានឱ្យដំណឹងមុន ហើយឃើញអ្នករាល់គ្នាកំពុងតែដេកលក់។ ពាក្យដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នានេះ ខ្ញុំក៏ចង់និយាយប្រាប់អ្នកឯទៀតៗគ្រប់គ្នាដែរ គឺថា **«ចូរប្រុងស្មារតី!»**។

**ការរិះគិត**

- ❖ ព្រះយេស៊ូដាស់តឿនយើងឱ្យប្រុងស្មារតី ដើម្បីរង់ចាំព្រះអង្គយាងមក។ នេះមានន័យថាក្នុងនាមជាគ្រីស្តបរិស័ទយើងត្រូវទទួលស្គាល់ព្រះអង្គក្នុងព្រឹត្តិការណ៍ទាំងប៉ុន្មានដែលកើតឡើង ឬក្នុងការរស់នៅរបស់ខ្លួន។
- ❖ ព្រះយេស៊ូយាងមករកយើងដើម្បីបង្វែរចិត្តរបស់យើង និងដើម្បីប្រទានដួងចិត្តថ្មីឱ្យអ្នកដែលផ្ញើជីវិតលើព្រះអង្គ។

**តើយើងប្រុងស្មារតីយ៉ាងដូចម្តេច?**
**តើយើងរង់ចាំព្រះជាម្ចាស់ប្រទានអ្វីដល់យើង?**

*ពាក្យអង្វរសកលតាមចិត្តរៀងៗខ្លួន*

### ពាក្យអធិដ្ឋាន

បពិត្រព្រះជាម្ចាស់ជាព្រះបិតាយើងខ្ញុំ។ ព្រះអង្គត្រាស់ហៅយើងខ្ញុំឱ្យមកជួបជុំគ្នានៅទីនេះដើម្បីរង់ចាំព្រះបុត្រាយាងមក។ សូមព្រះអង្គមេត្តាតម្រង់ចិត្តគំនិតរបស់យើងឱ្យបានស្អាត ដើម្បីចូលរួមជាមួយព្រះគ្រីស្តដែលយាងមក។



# អាទិត្យទី ២

## “ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់»

### ពាក្យអធិដ្ឋាន

បពិត្រព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ! ព្រះអង្គមានព្រះបន្ទូលសន្យាថានឹងប្រែផ្ទៃមេឃ និងផែនដីឱ្យបានថ្មីល្អឥតខ្ចោះ។ សូមព្រះអង្គមេត្តាប្រោសឱ្យយើងខ្ញុំយកចិត្តទុកដាក់នឹងសញ្ញាសម្គាល់ ដែលបង្ហាញពីព្រះបុត្រាព្រះអង្គកំពុងយាងមក។ សូមប្រោសឱ្យយើងខ្ញុំមានសេចក្តីក្លាហាន និងប្រុងស្មារតីជានិច្ចក្នុងការកសាងពិភពលោកថ្មីស្របតាមព្រះហឫទ័យព្រះអង្គ។

**ព្រះគម្ពីរដំណឹងល្អតាមសន្តម៉ាកុស ១,១-៨**

ដំណឹងល្អអំពីព្រះយេស៊ូគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់ចាប់ផ្តើមដូចតទៅ: ក្នុងគម្ពីរព្យាការីអេសាយមានចែងទុកមកថា៖ «យើងចាត់ទូតយើងឱ្យទៅមុនព្រះអង្គ ដើម្បីរៀបចំផ្លូវថ្វាយព្រះអង្គ។ មានសម្លេងបុរសម្នាក់ស្រែកនៅវាលរហោស្ថានថា: ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់ ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ»។ ពេលនោះលោកយ៉ូហានមកដល់ ស្របតាមបទគម្ពីរនេះមែន ហើយធ្វើពិធីជ្រមុជទឹកនៅវាលរហោស្ថាន។ លោកប្រកាសឱ្យមនុស្សម្នាក់ប្រែចិត្តគំនិត ដោយទទួលពិធីជ្រមុជទឹក ដើម្បីព្រះជាម្ចាស់លើកលែងទោសឱ្យរួចពីបាប។ អ្នកស្រុកយូដាទាំងអស់ និងអ្នកក្រុងយេរូសាឡឹមទាំងមូល នាំគ្នាចេញទៅរកលោក។ គេទទួលសារភាពអំពើបាបរបស់ខ្លួន ហើយលោកក៏ធ្វើពិធីជ្រមុជទឹកឱ្យគេក្នុងទន្លេយ័រដាន់។ លោកយ៉ូហានស្លៀកសម្លៀកបំពាក់ធ្វើពីរោមអូដ្ឋ ពាក់ខ្សែក្រវាត់ធ្វើពីស្បែក ហើយបរិភោគកណ្តូប និងទឹកឃ្មុំ។ លោកប្រកាសប្រាប់បណ្តាជនថា៖ «លោកដែលមានកម្លាំងខ្លាំងជាងខ្ញុំ នឹងមកតាមក្រោយខ្ញុំ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែឱនស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង។ ខ្ញុំបានធ្វើពិធីជ្រមុជឱ្យអ្នករាល់គ្នាក្នុងទឹក រីឯលោកវិញ លោកនឹងធ្វើពិធីជ្រមុជឱ្យអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ»។

**ការរិះគិត**

- ❖ លោកម៉ាកុសមានបំណងចង់ពន្យល់ថា ព្រះយេស៊ូយាងមកស្របតាមព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់។ តាមពិតព្រះយេស៊ូណែនាំអស់អ្នកដែលជឿឱ្យទុកចិត្តលើព្រះអង្គ ដែលសម្រាលទុក្ខមនុស្សលោក ដែលសម្តែងអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ និងដែលថែរក្សាយើងជានិច្ច។ នេះគឺជាដំណឹងល្អ។
- ❖ លោកយ៉ូហានបាទីស្តជាអ្នកដែលរៀបចំផ្លូវថ្វាយព្រះយេស៊ូដោយទូន្មានយើងឱ្យប្រែចិត្តគំនិត។ លោកជួយយើងឱ្យលែងប្រព្រឹត្តអំពើអាក្រក់ទៀត។ ជួយយើងឱ្យមានជំនឿស្របតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ។ ជួយយើងឱ្យមានចិត្តសង្ឃឹមលើព្រះអង្គ និងជួយយើងឱ្យស្រឡាញ់អ្នកដទៃដោយចិត្តសប្បុរស។ នេះជារបៀបដែលយើងរង់ចាំព្រះគ្រីស្ត។

**តើដំណឹងល្អមានតម្លៃអ្វីសម្រាប់ជីវិតរបស់យើង? ក្នុងការរស់នៅរបស់ខ្ញុំជារៀងរាល់ថ្ងៃ តើខ្ញុំសម្រេចចិត្តរៀបចំផ្លូវថ្វាយព្រះយេស៊ូយ៉ាងដូចម្តេច?**

*ពាក្យអង្វរសេកលតាមចិត្តរៀងៗខ្លួន*

### ពាក្យអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ! យើងខ្ញុំសូមលើកតម្កើងព្រះអង្គដែលជាទីពឹងដ៏មាំមួនការពារយើងខ្ញុំជានិច្ច។ សូមព្រះអង្គបង្ហាញឫទ្ធានុភាពរបស់ព្រះអង្គ និងគាំទ្រយើងខ្ញុំ ហើយសង្គ្រោះយើងខ្ញុំ នៅពេលខាងមុខនេះ សូមកុំឱ្យអំពើបាបរបស់យើងខ្ញុំរារាំងផ្លូវព្រះអង្គឡើយ។



# អាទិត្យទី ៣

## «ខ្ញុំជាសម្លេង»



### ពាក្យអធិដ្ឋាន

ឱ ព្រះបិតាជាអម្ចាស់យើងខ្ញុំអើយ! ព្រះអង្គមានព្រះបន្ទូលសន្យាថានឹងចាត់ព្រះគ្រីស្តឱ្យយាងមកសង្គ្រោះមនុស្សគ្រប់ជាតិសាសន៍។ ព្រះគ្រីស្តបានយាងមកតាមព្រះបន្ទូលសន្យារបស់ព្រះអង្គមែន សូមព្រះអង្គប្រោសឱ្យយើងខ្ញុំប្រុងស្មារតីទទួលព្រះគ្រីស្តដែលកំពុងយាងមក។ សូមប្រោសឱ្យយើងខ្ញុំយកចិត្តទុកដាក់ប្រកាសអំពីការសង្គ្រោះនេះនៅកន្លែងដែលយើងខ្ញុំរស់នៅ។

**ព្រះគម្ពីរដំណឹងល្អតាមសន្តយ៉ូហាន ១,៦-៨.១៩-២៨**

ព្រះជាម្ចាស់បានចាត់បុរសម្នាក់ឈ្មោះយ៉ូហានឱ្យមក។ លោកបានមកធ្វើជាបន្ទាល់ផ្តល់សក្ខីភាពអំពីពន្លឺ ដើម្បីឱ្យមនុស្សទាំងអស់ជឿដោយសារលោក។ លោកយ៉ូហានមិនមែនជាពន្លឺទេ គឺលោកគ្រាន់តែមកផ្តល់សក្ខីភាពអំពីពន្លឺប៉ុណ្ណោះ។ ជនជាតិយូដាចាត់ពួកបូជាចារ្យនិងពួកលេវីពីក្រុងយេរូសាឡឹមឱ្យទៅជួបលោកយ៉ូហានដើម្បីសួរថា៖ «លោកជានរណា?»។ លោកយ៉ូហានប្រកាសប្រាប់គេដោយពុំលាក់លៀមអ្វីឡើយ គឺលោកបានបញ្ជាក់យ៉ាងច្បាស់ថា៖ «ខ្ញុំមិនមែនជាព្រះគ្រីស្តទេ»។ ពួកគេសួរលោកថា៖ «ដូច្នេះ តើលោកជានរណា? តើលោកជាព្យាការីអេលីឬ?»។ លោកឆ្លើយថា៖ «ទេ មិនមែនទេ!»។ គេក៏សួរទៀតថា៖ «តើលោកជាព្យាការីដែលយើងរង់ចាំនោះឬ?»។ លោកឆ្លើយថា៖ «មិនមែនទេ!»។ គេសួរលោកទៀតថា៖ «តើលោកជានរណា? ដ្បិតយើងខ្ញុំចង់បានចម្លើយយកទៅជម្រាបអស់លោក ដែលចាត់យើងខ្ញុំឱ្យមក តើលោកថាខ្លួនលោកជានរណា!»។ លោកយ៉ូហានមានប្រសាសន៍ថា៖ «ខ្ញុំជាសម្លេងបុរសម្នាក់ដែលស្រែកនៅវាលរហោស្ថានថា: ចូរតម្រង់ផ្លូវថ្វាយព្រះអម្ចាស់” ត្រូវនឹងសេចក្តីដែលព្យាការីអេសាយបានថ្លែងទុកមក»។ អ្នកដែលគេចាត់ឱ្យមកនោះ ជាពួកខាងគណៈផារីស៊ី។ គេសួរលោកយ៉ូហានទៀតថា៖ «បើលោកមិនមែនជាព្រះគ្រីស្ត មិនមែនជាព្យាការីអេលី ហើយក៏មិនមែនជាព្យាការីដែលយើងរង់ចាំនោះទេ ហេតុដូចម្តេចបានជាលោកធ្វើពិធីជ្រមុជទឹកដូច្នេះ?»។ លោកយ៉ូហានឆ្លើយទៅគេថា៖ «ខ្ញុំធ្វើពិធីជ្រមុជក្នុងទឹកមែន ប៉ុន្តែក្នុងចំណោមអ្នករាល់គ្នា មានម្នាក់ដែលអ្នករាល់គ្នាពុំស្គាល់ លោកមកក្រោយខ្ញុំ លោកមានឋានៈខ្ពង់ខ្ពស់ណាស់ សូម្បីតែឱ្យខ្ញុំស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈរបស់លោកផង»។ ហេតុការណ៍នេះកើតមាននៅភូមិបេតថានី ខាងនាយទន្លេយ័រដាន់ ត្រង់កន្លែងលោកយ៉ូហានធ្វើពិធីជ្រមុជទឹក។

**ការរិះគិត**

- ❖ លោកយ៉ូហានបញ្ជាក់ថាលោកមិនមែនជាព្រះគ្រីស្តទេ លោកមិនមែនជាពន្លឺទេ ហើយលោកក៏មិនមែនជាព្យាការីដែរ គឺលោកជាសាក្សីរបស់ព្រះគ្រីស្ត។
- ❖ ក្នុងនាមជាគ្រីស្តបរិស័ទ យើងក៏ជាសាក្សីរបស់ព្រះយេស៊ូគ្រីស្ត ដែលលើកទឹកចិត្តអស់អ្នកដែលខកចិត្ត អស់អ្នកដែលអស់សង្ឃឹមឱ្យមានទីពឹងលើព្រះអង្គដូចលោកយ៉ូហាន។ យើងជាសម្លេងដើម្បីបង្ហាញអំពីវត្តមានរបស់ព្រះគ្រីស្ត។

**តើខ្ញុំផ្តល់សក្ខីភាពអំពីព្រះយេស៊ូយ៉ាងដូចម្តេច?**

*ពាក្យអង្វរសេកលតាមចិត្តរៀងៗខ្លួន*

### ពាក្យអធិដ្ឋាន

ឱ ព្រះជាអម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការអើយ! ព្រះអង្គចាត់ព្រះបុត្រាឱ្យយាងមកសង្គ្រោះយើងខ្ញុំ។ សូមព្រះអង្គមេត្តាកែប្រែចិត្តគំនិតរបស់យើងខ្ញុំឱ្យស្ម័គ្រចិត្តរៀបចំផ្លូវថ្វាយព្រះគ្រីស្តដែលកំពុងយាងមក។ សូមប្រោសឱ្យយើងខ្ញុំយកចិត្តទុកដាក់បម្រើព្រះអង្គដោយសេចក្តីស្រឡាញ់ និងជួយដល់អ្នកកម្សត់ទុគ៌តផង។

# អាទិត្យទី ៤

## «ខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់»

### ពាក្យអធិដ្ឋាន

បពិត្រព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ! ព្រះអង្គបានសង្គ្រោះយើងខ្ញុំដោយសារព្រះយេស៊ូគ្រីស្ត។ សូមព្រះអង្គមេត្តាបំភ្លឺចិត្តគំនិតយើងខ្ញុំឱ្យប្រុងស្មារតី ក្នុងពេលយើងខ្ញុំទទួលព្រះគ្រីស្តយាងមក។ សូមប្រោសឱ្យយើងខ្ញុំឃើញព្រះភក្ត្រព្រះអង្គក្នុងមនុស្សគ្រប់ៗរូប ដែលយើងខ្ញុំជួបជារៀងរាល់ថ្ងៃ។

**ព្រះគម្ពីរដំណឹងល្អតាមសន្តលូកា ១,២៦-៣៨**

ប្រាំមួយខែក្រោយមក ព្រះជាម្ចាស់បានចាត់ទេវទូតកាព្រីអែលឱ្យទៅភូមិណាសារ៉ែតក្នុងស្រុកកាលីឡេ ដើម្បីជួបនឹងស្ត្រីក្រមុំព្រហ្មចារីម្នាក់ជាគូដណ្តឹងរបស់កំលោះម្នាក់ ឈ្មោះយ៉ូសែប ដែលត្រូវជាញាតិវង្សព្រះបាទដាវីឌ ស្ត្រីក្រមុំនោះឈ្មោះ នាងម៉ារី។ ទេវទូតចូលទៅក្នុងផ្ទះនាងម៉ារី ហើយពោលទៅកាន់នាងថា៖ «ចូរមានអំណរសប្បាយឡើង! ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងនាងហើយ ព្រះអង្គគង់ជាមួយនាង»។ ពេលឮពាក្យនេះ នាងម៉ារីរន្ធត់យ៉ាងខ្លាំង នាងរិះគិតក្នុងចិត្តថា តើពាក្យជម្រាបសួរនេះមានន័យដូចម្តេច? ទេវទូតពោលទៅកាន់នាងថា៖ «កុំខ្លាចអី ម៉ារីអើយ! ដ្បិតព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងនាងហើយ។ នាងនឹងមានគភ៌ សម្រាលបានបុត្រមួយ ដែលនាងត្រូវថ្វាយព្រះនាមថា"យេស៊ូ។ បុត្រនោះនឹងមានឋានៈដ៏ប្រសើរឧត្តម ហើយគេនឹងថ្វាយព្រះនាមថា "ព្រះបុត្រានៃព្រះដ៏ខ្ពង់ខ្ពស់បំផុត។ ព្រះជាម្ចាស់នឹងតាំងបុត្រនោះឱ្យគ្រងរាជ្យលើបល្ល័ង្ករបស់ព្រះបាទដាវីឌ ជាព្រះអយ្យកោរបស់ព្រះអង្គ ព្រះអង្គនឹងគ្រងរាជ្យលើប្រជារាស្ត្រអ៊ីស្រាអែល អស់កល្បជានិច្ច ហើយរាជ្យរបស់ព្រះអង្គនឹងនៅស្ថិតស្ថេរ ឥតមានទីបញ្ចប់ឡើយ»។ នាងម៉ារីសួរទៅទេវទូតថា៖ «តើធ្វើដូចម្តេចនឹងឱ្យការណ៍នេះកើតឡើងបាន បើនាងខ្ញុំមិនរួមរស់ជាមួយបុរសណាផងដូច្នេះ?»។ ទេវទូតឆ្លើយទៅនាងវិញថា៖ «ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកសណ្ឋិតលើនាង គឺឫទ្ធានុភាពរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុតនឹងគ្របបាំងនាង។ ហេតុនេះ គេនឹងថ្វាយព្រះនាមដល់បុត្រដ៏វិសុទ្ធ ដែលត្រូវប្រសូតមកនោះថា "ព្រះបុត្រារបស់ព្រះជាម្ចាស់។ ម្យ៉ាងទៀត នាងអេលីសាបិត ជាញាតិរបស់នាង មានផ្ទៃពោះប្រាំមួយខែហើយ ថ្វីដ្បិតតែគាត់មានវ័យចាស់ ថែមទាំងជាស្ត្រីអារទៀតផងក៏ដោយ ព្រោះគ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតនោះឡើយ»។ នាងម៉ារីពោលទៅទេវទូតថា៖ «នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់ សូមឱ្យបានសម្រេចតាមពាក្យរបស់លោកចុះ!»។ បន្ទាប់មក ទេវទូតចាកចេញពីនាងទៅ។

**ការរិះគិត**

- ❖ ព្រះជាម្ចាស់បានសម្តែងព្រះហឫទ័យមេត្តាករុណាដ៏លើសលុបរបស់ព្រះអង្គដោយប្រោសប្រទានឱ្យព្រះបុត្រាប្រសូតជាមនុស្ស។ នេះជាការអស្ចារ្យដែលយើងរកគិតមិនដល់។
- ❖ ព្រះជាម្ចាស់បានជ្រើសរើសនាងម៉ារីឱ្យធ្វើជាព្រះមាតារបស់ព្រះបុត្រា។ ព្រះនាងគឺជាអ្នកបម្រើរបស់ព្រះជាម្ចាស់ គឺជាគំរូរបស់អ្នកជឿ និងរបស់អ្នកដែលប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអង្គ។

*ពាក្យអង្វរសេកលតាមចិត្តរៀងៗខ្លួន*

### ពាក្យអធិដ្ឋាន

បពិត្រព្រះអម្ចាស់ជាព្រះបិតា ! ព្រះអង្គបង្ហាញធម៌មេត្តាករុណាដ៏លើសលប់ឱ្យមនុស្សលោកស្គាល់ ដោយប្រោសឱ្យស្ត្រីព្រហ្មចារីម្នាក់អាចបង្កើតព្រះបុត្រារបស់ព្រះអង្គបាន។ សូមព្រះអង្គមេត្តាប្រោសឱ្យយើងខ្ញុំមានជំនឿមាំមួនដូចព្រះនាងម៉ារី និងលោកយ៉ូសែប។ សូមព្រះអង្គបំភ្លឺចិត្តគំនិតរបស់យើងខ្ញុំឱ្យយល់ពីទីសម្គាល់នានាដែលបង្ហាញថា ព្រះអង្គគង់នៅជាមួយយើងខ្ញុំសព្វថ្ងៃនេះ។





# រីករាយថ្ងៃបុណ្យ

# ព្រះយេស៊ូ ប្រសូត

## MERRY CHRISTMAS

ព្រះបន្ទូលបានកើតជាមនុស្ស!

យើងខ្ញុំសូមក្រាបថ្វាយបង្គំ និងទូលអង្វរព្រះជាម្ចាស់ ជាព្រះបិតា

សូមព្រះអង្គប្រោសប្រទានពរ ដល់ប្រទេសកម្ពុជា និងសូមឲ្យប្រជាជនទាំងអស់

បានប្រកបដោយសេចក្ដីសុខសាន្ត សុភមង្គល យ៉ាងបរិបូរណ៍

និង បានប្រកបដោយសេចក្ដីស្រលាញ់ដែលបានមកពីព្រះអង្គផង។

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

RADIO VERITAS ASIA
Khmer